ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

# សទ្ទានុក្រម
# ទស្សនវិជ្ជា
## ខ្មែរ-អង់គ្លេស-បារាំង

# LEXICON
# OF
# PHILOSOPHY
## Khmer-English-French


ក្រុមប្រឹក្សាជាតិភាសាខ្មែរ

គណៈកម្មការទស្សនវិជ្ជា



២០១៩

**បោះពុម្ពលើកទី១** ចំនួន២ ៤០០ច្បាប់
នៅរោងពុម្ព ជី.អ៊ី.ធី.ប៊ីហ្សនេស
ផ្ទះលេខ២៣២០ ផ្លូវ៤៥ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.)
អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរសព្ទដៃ : ០១២ ៨៦៣ ៩២០, ០១២ ៥៨៩ ៥៤៩, ០៩២ ៨៩២ ៣៤៣
អ៊ីមែល : ncklofrac@gmail.com
វេបសាយ : www.nckl.gov.kh

# សមាសភាព

## គណៈកម្មការទស្សនវិជ្ជា

| | | |
|---|---|---|
| ១- | លោកជំទាវ បណ្ឌិតសភាចារ្យ ខ្លូត ធីតា | ទីប្រឹក្សា |
| ២- | លោកបណ្ឌិត ឈត ប៊ុនថង | ប្រធាន |
| ៣- | លោកបណ្ឌិត ជា មុនីឫទ្ធិ | អនុប្រធាន |
| ៤- | លោកបណ្ឌិត ក្ដាន់ ធុល | សមាជិក |
| ៥- | លោកបណ្ឌិត ហ៊ឹម ញាណារិទ្ធ | សមាជិក |
| ៦- | លោកបណ្ឌិត ហែម ឡាច | សមាជិក |
| ៧- | លោកបណ្ឌិត ប៉ាន់ វុត្ថា | សមាជិក |
| ៨- | លោក ប៊ុត សុម៉េត | សមាជិក |
| ៩- | លោកស្រី សរ សិលា | សមាជិក |
| ១០- | លោកស្រី ម៉ិល វាសនា | សមាជិក |
| ១១- | លោក ធន ឆាយពិសិដ្ឋ | សមាជិក |
| ១២- | លោក លី ពិចិត្រ | សមាជិក |
| ១៣- | លោកស្រី កែវ សុជាតិ | សមាជិក |
| ១៤- | លោកស្រី អ៊ួន សុភាព | សមាជិក |
| ១៥- | លោក ឈុន ផារ៉េង | សមាជិក |
| ១៦- | លោក ហួត រ៉ា | សមាជិក |
| ១៧- | លោកវ៉ាន់ ម៉ូន | ជំនួយការខាងភាសា |
| ១៨- | លោក អែម ឧត្តម | ជំនួយការខាងភាសា |

# បុព្វកថា

ក្រុមប្រឹក្សាជាតិភាសាខ្មែរ(ក.ជ.ភ.ខ.)នៃរាជបណ្ឌិត្យសភាកម្ពុជាមានភារកិច្ចស្វែងរកឯកភាពជូនភាសាខ្មែរ ទាំងអក្ខរាវិរុទ្ធ ទាំងអំណាន និងពាក្យពេចន៍។ ទន្ទឹមនឹងការស្វែងរកឯកភាពនេះ ក្រុមប្រឹក្សាជាតិភាសាខ្មែរក៏មានតួនាទីបង្កើតបច្ចេកសព្ទថ្មីៗទាក់ទងនឹងជំនាញផ្សេងៗផងដែរ។

ទស្សនវិជ្ជាដែលជាប្រព័ន្ធនៃការគិតរបស់មនុស្ស មានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍគំនិត សីលធម៌ ក្រមសីលធម៌វិជ្ជាជីវៈ មនោគមវិជ្ជា គោលនយោបាយ ការគ្រប់គ្រង ដែលជាមាគ៌ានៃការអភិវឌ្ឍសង្គម។ ដើម្បីឆ្លើយតបនឹងការរីកចម្រើននៃសង្គមនាពេលបច្ចុប្បន្ន បច្ចេកសព្ទថ្មីៗត្រូវបានឥស្សរជនដែលមានចំណេះដឹងនិងជំនាញខាងវិស័យនេះ បង្កើតនិងប្រើប្រាស់ទៅតាមតម្រូវការ។

បច្ចេកសព្ទទស្សនវិជ្ជាដែលគណៈកម្មការទស្សនវិជ្ជានៃក្រុមប្រឹក្សាជាតិភាសាខ្មែរបានស្នើឡើង ហើយដែលបានអនុម័តនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែររហូតឈានដល់ការបោះពុម្ពជាសទ្ទានុក្រមនេះ មានសារៈសំខាន់ណាស់ក្នុងការរួមចំណែកអភិវឌ្ឍ និងស្វែងរកឯកភាពជូនភាសាខ្មែរ។

សូមអ្នកស្រឡាញ់ភាសាជាតិទទួលយកសទ្ទានុក្រមនេះទៅប្រើប្រាស់ក្នុងជំនាញរបស់ខ្លួនដើម្បីឱ្យភាសាយើងសម្បូរពាក្យពេចន៍ដូចភាសានៃប្រទេសជឿនលឿនក្នុងលោក។

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩
**ប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

បណ្ឌិតសភាចារ្យ **សុខ ទូច**

# អារម្ភកថា

គណៈកម្មការបច្ចេកទេសទាំង១៧ នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.) មានភារកិច្ចស្រាវជ្រាវ ចងក្រង និងបង្កើតពាក្យទៅតាមជំនាញរៀងៗខ្លួន។ គណៈកម្មការបច្ចេកទេសនីមួយៗបានស្នើបច្ចេកសព្ទរបស់ខ្លួននៅក្នុងការប្រជុំអនុម័តពាក្យរបស់ ក.ជ.ភ.ខ.។ ពាក្យដែលបានអនុម័តរួច ត្រូវបោះផ្សាយក្នុងព្រឹត្តិបត្ររបស់ ក.ជ.ភ.ខ. ហើយបន្ទាប់មកពាក្យទាំងនោះត្រូវប្រមូលចងក្រងដើម្បីបោះពុម្ពជាសទ្ទានុក្រម។

នៅឆ្នាំ២០១៤ គណៈកម្មការទស្សនវិជ្ជាបានស្នើអនុម័តបច្ចេកសព្ទលើកទី១ បានចំនួន៩០ពាក្យ ហើយនៅឆ្នាំ២០១៨ គណៈកម្មការទស្សនវិជ្ជាបានស្នើអនុម័តបច្ចេកសព្ទលើកទី២ បានចំនួន១០៩ពាក្យ។ លេខាធិការដ្ឋាននៃ ក.ជ.ភ.ខ. បានប្រមូលបច្ចេកសព្ទដែលបានអនុម័តទាំងពីរលើក សរុបចំនួន១៩៩ពាក្យ ដើម្បីរៀបចំបោះពុម្ពនិងផ្សព្វផ្សាយក្នុងសទ្ទានុក្រមនេះ។

ក.ជ.ភ.ខ. សង្ឃឹមថា សទ្ទានុក្រមទស្សនវិជ្ជានេះ ជាវិភាគទានមួយដ៏សំខាន់សម្រាប់សាធារណជនយកទៅប្រើប្រាស់តាមតម្រូវការដើម្បីអភិវឌ្ឍចំណេះដឹង និងជួយសម្រួលដល់ការប្រើប្រាស់បច្ចេកសព្ទក្នុងជំនាញនេះឱ្យឯកភាពគ្នាទាំងអក្ខរាវិរុទ្ធនិងន័យរបស់វាផងដែរ។

ក.ជ.ភ.ខ. មិនអាចដំណើរការបានទេ បើគ្មានការគាំទ្រនិងការលើកទឹកចិត្តពីសំណាក់រាជរដ្ឋាភិបាល។ អាស្រ័យហេតុនេះ ក្នុងនាម ក.ជ.ភ.ខ. ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំរាជរដ្ឋាភិបាលដែលបានឧបត្ថម្ភគាំទ្រដល់ ក.ជ.ភ.ខ. យើង ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។

ថ្ងៃចន្ទ ៧រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩
**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

បណ្ឌិត **ហ៊ាន សុខុម**

# ក

**កម្ម / កម៌**
អ. karma
បារ. karma (m.)

ច្បាប់ធម្មជាតិសកលនៃហេតុនិងផលដែលប្រើចំពោះអំពើប្រកបដោយចេតនារបស់មនុស្សនៅក្នុងទស្សនវិជ្ជារបស់ឥណ្ឌា។ អំពើល្អឬអាក្រក់ជាអ្នកកំណត់វាសនារបស់សត្វលោក។ ការទទួលផលពីអំពើអាចចំណាយពេលលើសពីមួយជីវិតដោយចងអ្នកធ្វើអំពើទៅនឹងវដ្តសង្សារ។ មានតែអំពើដែលរួចផុតពីចំណង់កិលេសនិងជំនឿខុសទេ ទើបគ្មានវិបាកនៅក្នុងសង្សារវដ្ត។

ឧ. ប្រជាជនខ្មែរភាគច្រើនជឿលើច្បាប់កម្មផល។

**កម្មវត្ថុ**
អ. object
បារ. objet (m.)

មនុស្សណាម្នាក់ ក្រុមណាមួយ ឬ អ្វីមួយ ទាំងរូបីទាំងអរូបី ដែលទទួលរងអំពើ (ផ្លូវកាយឬផ្លូវចិត្ត) ពីប្រធានឬអ្នកធ្វើអំពើ។

ឧ១- លោក «ក» ត្រូវបានលោក «ខ» ប្រើប្រាស់ដើម្បីសម្រេចបំណងរបស់ខ្លួន។ ក្នុងករណីនេះ លោក «ក» គឺជា**កម្មវត្ថុ** ឯលោក «ខ» គឺជាប្រធាន (អ្នកធ្វើអំពើ)។

ឧ២- សច្ចភាពដែលក្រុមណាមួយកំពុងស្វែងរកដើម្បីដោះស្រាយជម្លោះឬបញ្ហាណាមួយដែលកំពុងកើតឡើង គឺជា**កម្មវត្ថុ**។

**ករុណា**
អ. mercy /
compassion
បារ. merci /
compassion (f.)

ការតម្រូវខាងសីលធម៌ឱ្យមនុស្សម្នាក់ៗគួរប្រឹងប្រែងអស់ពីលទ្ធភាពដើម្បីកាត់បន្ថយការលំបាកខាងផ្លូវកាយឬផ្លូវចិត្តនិងខាងសម្ភារៈរបស់អ្នកដទៃ។

**កាតាឡិបស៊ីស**
អ. katalepsis
បារ. katalepsis (m.)

តាមទស្សនវិទូអត់ធ្មត់និយម មានន័យថា មូលបដិញ្ញាចម្បងបែបមនោគមវិជ្ជាដោយចាត់ទុកថាសភាពចិត្តរបស់អ្នកណាម្នាក់ជាប់ពាក់ព័ន្ធទៅនឹងការយល់ដឹងនិងការទទួលយកបញ្ញត្តិទស្សនវិជ្ជាមូលដ្ឋាននានា។ តាមភាសាក្រិក ពាក្យ *កាតាឡិបស៊ីស* មានន័យថា ការចាប់យក។

**កាល់វ៉ាំងនិយម**
អ. calvinism
បារ. calvinisme (m.)

លទ្ធិជាប់ទាក់ទងនឹងការបង្រៀនគ្រិស្តសាសនារបស់លោក ហ្សង់ កាល់វ៉ាំង (Jean Calvin) ជាពិសេសទាក់ទងនឹងជំនឿថា ព្រះគ្រប់គ្រងអ្វីៗដែលកើតនៅលើភពផែនដី។ លទ្ធិនេះជាទម្រង់តឹងរ៉ឹងនៃប្រូតេស្តង់និយម ដែលគេស្គាល់ច្បាស់តាមរយៈជំនឿនៅក្នុងគម្ពីរគ្រិស្តសាសនាដែលគេចាត់ទុកថាជាច្បាប់នៃជំនឿ (ការបដិសេធសេរីភាពរបស់មនុស្សតាំងពីអំពើបាបរបស់អាដាំនិងនាងអេវ)។

**កាឡាម**
អ. kalam
បារ. kalam (m.)

(**kalam** ជាភាសាអារ៉ាប់) ការស្វែងរកពុទ្ធិខាងទេវវិជ្ជាតាមរយៈការពិភាក្សា ការជជែក និង ការដេញដោល។ នៅក្នុងទស្សនវិជ្ជាអ៊ិស្លាម **កាឡាម** ជាដំណើរនៃការលើកហេតុផលបែបទស្សនវិជ្ជា ដើម្បីផ្ទៀងផ្ទាត់សមាសភាគនានានៃលទ្ធិសាសនា។ **កាឡាម**មានតួនាទីសម្របសម្រួលនៅក្នុងសាសនាអ៊ិស្លាមនូវអ្វីដែលទស្សនវិជ្ជាស្កូឡាស្ទិកយកមកប្រើក្នុងការអភិវឌ្ឍគ្រិស្តសាសនា។

ឧ. **កាឡាម**បានក្លាយទៅជាប្រព័ន្ធទស្សនវិជ្ជាសាសនាមួយដ៏ល្បីល្បាញនៅសតវត្សរ៍ទី១១។

**ការកុហក**
អ. lying
បារ. mentir (m.)

ការនិយាយ ការសរសេរ ឬ ការសម្តែងដោយកាយវិការនូវអ្វីមួយដែលអ្នកណាម្នាក់ដឹងឬជឿថាមិនពិតដោយចេតនាដើម្បីបំភាន់មនុស្សម្នាក់ ឬច្រើននាក់។ អ្នកកុហកមានអ្វីមួយនៅក្នុងចិត្តរបស់ខ្លួន ហើយបានបញ្ជាក់ដោយការអះអាងផ្ទុយពីនេះ ក្នុងបំណងបញ្ឆោត ឬយ៉ាងហោចណាស់ដើម្បីបិទបាំងលទ្ធភាពនៃការបញ្ឆោត។

(ពាក្យនេះ គេប្រើក្នុងសីលវិជ្ជា)

**ការបង្កើតថ្មី**
អ. creativity
បារ. créativité (f.)

ជាទូទៅ ការបង្កើតថ្មីសំដៅយកការបង្កើតអ្វីមួយដែលថ្មី ដែលរួមទាំងវត្ថុរូបីនិងគំនិត។ ការបង្កើតថ្មីត្រូវបានគេប្រើយ៉ាងទូលំទូលាយនៅក្នុងសកម្មភាព

របស់មនុស្ស ប៉ុន្តែវាមានសារៈសំខាន់ដោយឡែក នៅក្នុងការបង្កើតសិល្បៈ។ ការបង្កើតថ្មីបង្ហាញនូវ ភាពថ្មី និងពាក់ព័ន្ធជាមួយការបង្កើតអ្វីមួយដែល ខុសពីអ្វីដែលបានបង្កើតពីមុន ប៉ុន្តែវាក៏ពង្រីកទៅ ហួសពីអ្វីដែលគ្រាន់តែជាភាពថ្មី។

(ពាក្យនេះ គេប្រើនៅក្នុងសោភណវិជ្ជា)

**ការបាត់ស្វ័យគ្រប់គ្រង**
អ. ecstasy
បារ. extase (f.)

សភាពមួយដែលការទទួលដឹងដោយញាណធម្មតា ឈប់ដំណើរការមួយរយៈ ហើយប្រធានបែរជាដឹងពី ភាពអស្ចារ្យជាងមុនប្រកបដោយភាពសប្បាយរីករាយ ប៉ុន្តែបន្ទាប់មក អ្វីដែលប្រធានដឹងនោះមិនអាចទទួល ដឹងបានជាធម្មតានោះទេ។ ម្យ៉ាងទៀត ការបាត់ស្វ័យ គ្រប់គ្រងជាសភាពខាងខួរក្បាល ជាធម្មតាបង្កដោយ ការឆ្លងកាត់បទពិសោធន៍គម្ពីរនិយមជ្រុលខាង សាសនា ការត្រេកត្រអាលផ្លូវភេទ ឬ ការញៀន គ្រឿងញៀន ... ក្នុងនោះ ពេលខ្លះ បុគ្គលបានបាត់ ស្វ័យគ្រប់គ្រងនិងសម្បជញ្ញៈ ដោយសារតែការ គ្របដណ្តប់ពីវេទនារម្មណ៍យ៉ាងខ្លាំង។

**ការយល់សប្តិ/សុបិន**
អ. dream

ស៊េរី(ដំណើរបន្តគ្នា) នៃរូបភាព គំនិត វេទនារម្មណ៍ និងឥន្ទ្រីយារម្មណ៍ ដែលជាធម្មតា កើតឡើងដោយ

អចេតនានៅក្នុងចិត្ត ក្នុងរយៈពេលនៃដំណាក់កាលណាមួយនៃដំណេក។ ថ្វីបើខ្លឹមសារនិងគោលបំណងនៃការយល់សប្តិមិនត្រូវបានគេយល់ដឹងពេញលេញក៏ដោយ ក៏ការយល់សប្តិបានក្លាយទៅជាប្រធានបទនៃការសន្មតបែបវិទ្យាសាស្ត្រហើយវាក៏ជាប្រធានបទនៃចំណាប់អារម្មណ៍ខាងទស្សនវិជ្ជានិងសាសនាតាំងពីមានការកត់ត្រានៅក្នុងប្រវត្តិសាស្ត្រ។ ការសិក្សាបែបវិទ្យាសាស្ត្រអំពីការយល់សប្តិត្រូវបានគេហៅថាសុបិនវិទ្យា ( Oneirology )។

**ការសម្រុះសម្រួល**
អ. compromise
បារ. compromis (m.)

ការព្រមព្រៀងមួយដែលសម្រេចឡើងដោយភាគីពាក់ព័ន្ធតាមរយៈការចរចារួមគ្នា បន្ទាប់ពីភាគីនីមួយៗបានធ្វើសម្បទានមួយចំនួនចេញពីការទាមទារដំបូងៗរបស់ខ្លួន ដើម្បីអាចទទួលយកបានទាំងអស់គ្នា។ ការសម្រុះសម្រួលផ្អែកលើមូលដ្ឋានដែលភាគីនីមួយៗធ្វើសហប្រតិបត្តិការក្នុងការដោះស្រាយបញ្ហាជាជាងការធ្វើឱ្យខូចទំនាក់ទំនង។

( ពាក្យនេះ គេប្រើនៅក្នុងសីលវិជ្ជានិងទស្សនវិជ្ជានយោបាយ )

**ការុញ្ញហេតុ**
អ. pathos
បារ. pathos ( m. )

អំណាចនៃស្ថានភាព ឬស្នាដៃនិពន្ធ ឬស្នាដៃសិល្បៈ ឬក៏វោហារសាស្ត្រ ដែលជំរុញឱ្យមនុស្សមានភាពទុក្ខព្រួយ និង អាណិតអាសូរ។

( ពាក្យនេះ គេប្រើនៅក្នុងទស្សនវិជ្ជាបុរាណក្រិក និងទស្សនវិជ្ជាអំពីចិត្ត )

**កុសលចុងក្រោយ**
អ. final good
បារ. bien final

កុសលទោលដែលជាកុសលចុងក្រោយ ( ល្អបំផុតខ្ពង់ខ្ពស់បំផុត ) ឬហៅថា បំណងចុងក្រោយ។ សញ្ញាណនៃកុសលចុងក្រោយមានមូលដ្ឋានគ្រឹះនៅក្នុងប្រព័ន្ធសីលវិជ្ជាបុរាណសម័យ។ រាល់អំពើត្រូវបានជំរុញដើម្បីបំណងមួយ ហើយបំណងនោះល្អសម្រាប់អ្នកធ្វើ។ កុសលមួយចំនួនត្រូវបានធ្វើដើម្បីឆ្ពោះទៅរកកុសលខ្ពស់ជាង ហេតុដូច្នេះកុសលមានឋានានុក្រម។ ក្នុងន័យនេះ ត្រូវតែមានកុសលទោលមួយដែលត្រូវបានស្វែងរកសម្រាប់បំណងចុងក្រោយ ចំណែកកុសលផ្សេងទាំងអស់ត្រូវបានស្វែងរកសម្រាប់ឈានទៅដល់កុសលទោលនោះ។ កុសលចុងក្រោយគួរតែនៅចុងក្រោយបំផុតទូលំទូលាយ និងស្វ័យគ្រប់គ្រាន់ ទោះបីលក្ខខណ្ឌចុងក្រោយនេះស្ថិតនៅក្នុងវិវាទក៏ដោយ។ នៅក្នុងទស្សនវិជ្ជាក្រិកបុរាណ និកាយសីលវិជ្ជានីមួយៗ

យល់ស្របថា កុសលចុងក្រោយនេះគឺសុខុមាលភាព ឬសុភមង្គល ប៉ុន្តែ និកាយទាំងនោះយល់ខុសៗគ្នា ទៅតាមនិយមន័យសុភមង្គលរៀងៗខ្លួន ដោយ កំណត់និយមន័យសុភមង្គល ថាជាកិត្តិយស ភាព រីករាយ គុណធម៌ ការសញ្ជឹងគិត ឬភាពស្ងប់។

(ពាក្យនេះ គេប្រើក្នុងសីលវិជ្ជានិងទស្សនវិជ្ជាអំពី សកម្មភាព)

**កំណត់និយម**
អ. determinism
បារ. déterminisme (m.)

លទ្ធិទស្សនវិជ្ជាដែលយល់ថា ព្រឹត្តិការណ៍ទាំងអស់ ជាពិសេសអំពើទាំងឡាយរបស់មនុស្សមានចំណង ទាក់ទងគ្នា ហើយកំណត់ដោយខ្សែច្រវាក់នៃ ព្រឹត្តិការណ៍ដែលមានពីមុន។

# ខ

**ខុងជឺនិយម**

អ. confucianism

បារ. confucianisme (m.)

ប្រព័ន្ធគំនិតសំខាន់នៅក្នុងទស្សនវិជ្ជាចិន ដែលបានរីកចម្រើនចន្លោះឆ្នាំ៥៥១ដល់៤៧៩ មុនគ្រិស្តសករាជ ចេញពីការបង្រៀនរបស់ខុងជឺ និងសាវ័ករបស់គាត់ ដែលបានយកចិត្តទុកដាក់ចំពោះគោលការណ៍ស្តីពីចរិយាត្រឹមត្រូវ ជំនាញនៃការគ្រប់គ្រងរដ្ឋ គតិបណ្ឌិតស័ក្តិសិទ្ធិ និងទំនាក់ទំនងសង្គមត្រឹមត្រូវ។ ខុងជឺនិយមបានជះឥទ្ធិពលលើឥរិយាបថប្រជាជនចិន ចំពោះជីវិតគំរូនៃការរស់នៅ និងគំរូនៃតម្លៃសង្គម ព្រមទាំងបានផ្តល់មូលដ្ឋានខាងបញ្ញាសម្រាប់ទ្រឹស្តី និងស្ថាប័ននយោបាយចិនទៀតផង។ ខុងជឺនិយមបានរាលដាលចេញពីប្រទេសចិនទៅដល់កូរ៉េ ជប៉ុន និងវៀតណាម និងបានក្លាយទៅជាកត្តារឹងមាំក្នុងវប្បធម៌អាស៊ីខាងកើតព្រមទាំងបានជំរុញឱ្យមានការចាប់អារម្មណ៍ក្នុងចំណោមអ្នកប្រាជ្ញបស្ចិមប្រទេសស្ទើរតែទាំងអស់។ ទោះបីខុងជឺនិយមបានក្លាយទៅជាមនោគមវិជ្ជាផ្លូវការរបស់រដ្ឋចិនក៏ដោយ ក៏ខុងជឺនិយមមិនដែលមានអត្ថិភាពជាសាសនាផ្លូវការទេ។ ខុងជឺបានចងក្រងគម្ពីរឈ្មោះថា «លាវយី» មានន័យថា សិល្បៈទាំង៦ ជាសិល្បៈសេរីមានគោលដៅស្វែងរកនូវសេរីភាព

ក្នុងនយោបាយនិងសេដ្ឋកិច្ច មានដូចខាងក្រោម៖

១- **គម្ពីរយី** និយាយពីការផ្ទេរកម្មសិទ្ធិនិងផ្ទេរមរតក

២- **គម្ពីរចេ** ជាកំណាព្យនិទានសម្រាប់បម្រើសោភ័ណធម្មជាតិ

៣- **គម្ពីរលី** និយាយពីការប្រារព្ធពិធីសែនព្រេនផ្សេងៗ

៤- **គម្ពីរយ៉ូ** និយាយពីបទភ្លេងនិងចម្រៀងបណ្តែតអារម្មណ៍

៥- **គម្ពីរជូ** និយាយពីប្រវត្តិសាស្ត្រនិងពង្សាវតារនៃប្រទេសចិន

៦- **គម្ពីរឈូស៊ាវ** ឬ **គម្ពីរនិទាយរដូវ** និយាយពីសរទរដូវ ជាប្រវត្តិសាស្ត្រជាក់ស្តែងរបស់សន្តតិវង្សលូ។

# គ

**គង្វាលសាស្ត្រ** ការសិក្សាអំពីវណ្ណកម្មនិងជីវិតរបស់គ្រូគង្វាល ឬលោកឪពុកសំខាន់ៗនៃវិហារគ្រិស្តសាសនា ពីសតវត្សរ៍ទី១ដល់ទី៥នៃគ្រិស្តសករាជ។
អ. patristics
បារ. patristique (f.)

**គតិបណ្ឌិត** អធ្យាស្រ័យល្អឬសុភនិច្ឆ័យរបស់មនុស្សដែលកើតចេញពីសមត្ថភាពនៃការប្រើប្រាស់បញ្ញាញាណ បទពិសោធនិងពុទ្ធិផ្ទាល់ខ្លួនដើម្បីធ្វើការសម្រេចចិត្តនិងការវិនិច្ឆ័យឱ្យបានត្រឹមត្រូវ។
អ. wisdom
បារ. sagesse (f.)

**គតិបណ្ឌិតប្រតិបត្តិ** បច្ចេកសព្ទរបស់អារីស្តូត (Aristote/Aristotle) សម្រាប់ការពិចារណាដែលនាំទៅដល់សកម្មភាពប្រតិបត្តិ ពោលគឺសំដៅទៅដល់គុណធម៌ដែលកើតចេញពីការពិចារណាអំពីការអនុវត្តត្រឹមត្រូវនូវការយល់ដឹងទូទៅនិងការយល់ដឹងខាងទ្រឹស្តីសីលធម៌ចំពោះករណីជាក់ស្តែងដោយឡែកៗ។
អារីស្តូតនិយាយថា គតិបណ្ឌិតប្រតិបត្តិ គឺជាសភាពពិតនិងសមហេតុផលនៃសមត្ថភាពក្នុងការធ្វើអំពើណាមួយដោយគិតដល់ផលល្អនិងអាក្រក់ចំពោះមនុស្ស។
(បញ្ញត្តិនេះ គេប្រើនៅក្នុងទស្សនវិជ្ជាក្រិកបុរាណ
អ. practical wisdom
បារ. sagesse pratique

សីលវិជ្ជា និង ទស្សនវិជ្ជាស្ដីអំពីអំពើ [គតិបណ្ឌិត ប្រតិបត្តិ = ការពិចារណា = ការយល់ដឹង = បញ្ញា = ហេតុផលប្រតិបត្តិ = ការប្រុងប្រយ័ត្ន])។

**គុណធម៌ធម្មជាតិ**

អ. natural virtue

បារ. vertu naturelle

ចំពោះ ដាវីដ ហ៊ូម (David Hume) គុណធម៌ គឺជាគុណភាពខាងសីលធម៌នៅក្នុងខ្លួនរបស់យើង ឬក្នុងខ្លួនរបស់អ្នកដទៃ ដែលត្រូវបានយល់ព្រម ដោយទស្សនៈខាងសីលធម៌។ ហ៊ូម បានញែកគុណធម៌ធម្មជាតិចេញពីគុណធម៌សិប្បនិម្មិត។ គុណធម៌ធម្មជាតិ គឺជាទំនោរនិងលក្ខណៈគុណធម៌ដែលកើតឡើងពីឧបនិស្ស័យមូលដ្ឋាននៃធម្មជាតិពិតរបស់មនុស្ស ហើយវាមិនមែនជាអ្វីដែលត្រូវបានគេបណ្ដុះដោយចេតនាទេ។ លក្ខណៈទាំងនេះមានដូចជា សេចក្ដីករុណា ចិត្តសប្បុរស ចិត្តប្រណី ចិត្តទូលាយ សេចក្ដីស្រឡាញ់របស់អ្នកណាម្នាក់ចំពោះក្មេងៗ ការអភ័យទោស។ល។ ផ្ទុយទៅវិញ គុណធម៌សិប្បនិម្មិតដូចជាយុត្តិធម៌ ស្វាមីភក្តិ សេចក្ដីស្មោះត្រង់ គឺជាលទ្ធផលនៃល្បិចដ៏ប៉ិនប្រសប់ និងការអប់រំដែលគេទទួលបានក្នុងអំឡុងពេលដ៏យូរ។ លក្ខណៈទាំងនេះជាសិប្បនិម្មិត និងត្រូវបានគេប្រឌិត ប៉ុន្តែមិនមែនធ្វើឡើងតាមទំនើងចិត្តនោះទេ។ ហ៊ូម

អះអាងថា គុណធម៌ធម្មជាតិផ្តល់មូលដ្ឋានចំពោះជីវិតគ្រួសារនិងទំនាក់ទំនងជិតស្និទ្ធរវាងមិត្តភក្តិ។ ចំណែកឯគុណធម៌សិប្បនិម្មិតវិញ គឺជាតម្រូវការចាំបាច់ចំពោះជីវិតសង្គមដ៏ទូលំទូលាយរបស់យើង។

(ពាក្យនេះ គេប្រើនៅក្នុងសីលវិជ្ជា)

**គុណូបការៈ/ គុណូបការ**
អ. merit
បារ. mérite (m.)

ឧត្តមភាពឬតម្លៃដែលសក្តិសមនឹងទទួលបានការតបស្នងជារង្វាន់ឬកិត្តិយស។ គុណូបការៈចែកចេញជាពីរគឺ គុណូបការៈសីលធម៌ ដូចជា គុណធម៌ កុសលភាព ជាដើម និង គុណូបការៈមិនមែនសីលធម៌ ដូចជា ជំនាញ បំណិន ជាដើម។ គុណូបការៈទាំងអស់គឺជាគុណសម្បត្តិដែលត្រូវគោរពឬគួរគោរពនិងកោតសរសើរក្នុងសង្គម។

(ពាក្យនេះ គេប្រើក្នុងទស្សនវិជ្ជាសីលធម៌ និង ទស្សនវិជ្ជានយោបាយ)

**គោលជំហរ**
អ. attitude (position)
បារ. attitude (position)

សភាពនៃការយល់ព្រម ឬ ការមិនយល់ព្រមខាងគំនិត ការពេញចិត្ត ឬ ការមិនពេញចិត្ត ដែលទាក់ទងនឹងវេទនារម្មណ៍និងអារម្មណ៍ ហើយដែលផ្ទុយទៅនឹងជំនឿ។ ជំនឿទាក់ទងនឹងហេតុការណ៍និងការគិត។ ចំណែកឯគោលជំហរវិញទាក់ទងនឹងការវាយតម្លៃនិងការឆ្លើយតបខាងវេទនារម្មណ៍។

មនុស្សដែលមានជំនឿដូចគ្នាអាចមានគោលជំហរខុសគ្នា ឬក៏មនុស្សដែលមានគោលជំហរដូចគ្នាអាចមានជំនឿខុសគ្នាចំពោះកម្មវត្ថុតែមួយ។ ដូច្នេះការខុសគ្នារវាងគោលជំហរនិងជំនឿ ដូចគ្នាទៅនឹងការខុសគ្នារវាងតម្លៃនិងហេតុការណ៍។ សីលវិជ្ជាអត្តនោម័តិអះអាងថា គោលជំហរទាក់ទងដោយផ្ទាល់នឹងហេតុផលជំរុញនិងឥរិយាបថ និងអះអាងថា ការវិនិច្ឆ័យខាងសីលវិជ្ជានិងខាងតម្លៃគឺជាបញ្ហានៃគោលជំហរជាជាងបញ្ហានៃការគិត។

(ពាក្យនេះ គេប្រើនៅក្នុងសីលវិជ្ជា និង ទស្សនវិជ្ជាស្តីពីអំពើ)

**គំនិត**

អ. idea

បារ. idée (f.)

១- សំណើឬផែនការសម្រាប់ធ្វើអ្វីមួយ,
ឧ. ខ្ញុំមានគំនិតបន្តការសិក្សានៅបរទេស។
២- ការយល់ឃើញ ការគិត ឬ រូបភាពនៅក្នុងសតិ (mind) របស់មនុស្ស, ឧ. តើអ្នកមានគំនិតថាគាត់មានរូបរាងដូចម្តេច?
៣- ជំនឿ ឬ ទស្សនៈ, ឧ. យើងមានគំនិតខុសគ្នាស្រឡះអំពីការដាក់ពិន័យចំពោះកុមារ។
៤- បំណងឬហេតុផលក្នុងការធ្វើអ្វីមួយ, ឧ. គំនិតរួមនៃការផ្សាយពាណិជ្ជកម្ម គឺបានធ្វើឱ្យមនុស្សទិញផលិតផលឬសេវា។

# ឃ

**ឃាតកម្ម**
អ. killing
បារ. meurtre
( m. )

អំពើនៃការបញ្ចប់ជីវិត។ ឃាតកម្មលើភាវៈមនុស្ស ជានិច្ចកាលត្រូវបានគេចាត់ទុកថាជាអំពើអាក្រក់បំផុតខាងសីលធម៌ ហើយសិទ្ធិរស់រានមានជីវិតត្រូវបានគេចាត់ទុកជាសិទ្ធិមនុស្សសំខាន់បំផុត។ ការហាមមិនឱ្យសម្លាប់មនុស្សដែលគ្មានទោស គឺជាគោលការណ៍ទូទៅខាងសីលធម៌និងចាស់ជាងគេបំផុត។ នៅក្នុងសង្គមបុរាណ គោលការណ៍ទូទៅនេះអនុវត្តតែក្នុងសហគមន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ។ ក្នុងក្របខណ្ឌសាសនា មានសាសនាព្រះពុទ្ធ និងសាសនាគ្រិស្តជាដើម គោលការណ៍ទូទៅនេះបានពង្រីកទៅដល់ការហាមមិនឱ្យសម្លាប់មនុស្សសត្វគ្រប់ប្រភេទ។ ទ្រឹស្តីសីលធម៌សម័យទំនើបធ្វើយុត្តិកម្មភាពមិនអាចបំពានបាននៃជីវិតមនុស្សក្នុងក្របខណ្ឌនៃសេចក្តីថ្លៃថ្នូររបស់មនុស្សដែលជាភាវៈប្រកបដោយវិចារណញ្ញាណ។ ជាប្រពៃណី ឃាតកម្មត្រូវបានគេធ្វើយុត្តិកម្មតែនៅក្នុងយុត្តសង្គ្រាម និងការកាត់ទោសប្រហារជីវិតប៉ុណ្ណោះ ទោះបីជាមូលដ្ឋានទាំងពីរនេះនៅតែត្រូវបានគេជជែកដេញដោលនៅឡើយក៏ដោយ។

( ពាក្យនេះ គេប្រើនៅក្នុងសីលវិជ្ជា )

# ច

**ចិត្ត**

អ. mind

បារ. esprit (m.)

សមត្ថភាពគិត យល់ដឹង ពិចារណា វិនិច្ឆ័យ និងសម្រេចចិត្តរបស់មនុស្ស។ លើសពីនេះទៀត **ចិត្ត** ក៏ជាមជ្ឈមណ្ឌលនៃញាណដែលបង្កើតការគិត អារម្មណ៍ គំនិត ប្រត្យក្សារម្មណ៍ និងជាកន្លែងផ្ទុកពុទ្ធិនិងការចងចាំ។ លោក រ៉ឺណេ ដេកាត (René Déscartes) បានប្រើពាក្យ **ចិត្ត**(mind) និង **ព្រលឹង** (soul) អាចជំនួសគ្នាទៅវិញទៅមកបាន។ ចំពោះគាត់ **ចិត្ត**(mind) ដូចគ្នានឹង **អត្តៈ** (មនុស្ស) ដែលជាសារធាតុអាចគិត ជឿ សង្ស័យ មានចំណង់ យល់ដឹង និងធ្វើអំពើ។ ចំពោះទស្សនវិទូដទៃទៀត ដូចជា ដាវីដ ហ៊្យូម (David Hume) យល់ថា **ចិត្ត** (mind) គឺជាបណ្តុំនៃសភាពខាងចិត្តសាស្ត្រ ហើយក្នុងន័យនេះវាស្រដៀងគ្នាទៅនឹង **ញាណ** (consciousness) ប៉ុន្តែ វាផ្ទុយទៅនឹងសភាពខាងរូបកាយ។ ការយល់ដឹងខុសៗគ្នាអំពី **ចិត្ត** នាំទៅដល់ការយល់ដឹងខុសគ្នាអំពីបញ្ហា **ចិត្ត-កាយ** (mind-body problem)។

(បញ្ញត្តិនេះ គេប្រើក្នុងទស្សនវិជ្ជាអំពីចិត្ត)

**ចៃដន្យ**
អ. accident
បារ. accident (m.)

លក្ខណៈមួយដែលអាចឬមិនអាចជាកម្មសិទ្ធិរបស់អ្វីមួយដោយវាមិនជះឥទ្ធិពលលើសារជាតិរបស់វត្ថុនោះទេ។ ពាក្យ **ចៃដន្យ** នេះ ត្រូវបានគេប្រើនៅក្នុងប្រវត្តិទស្សនវិជ្ជាទាំងមូលដោយមានអត្ថន័យប្លែកៗគ្នាមួយចំនួន។ នៅក្នុងអស្តិរូបវិជ្ជារបស់អារីស្តូត (Aristotle) «ចៃដន្យ» ជាលក្ខណៈនៃអ្វីមួយដែលមិនមែនជាសារជាតិរបស់វា (អ្វីមួយអាចបាត់បង់ ឬ ត្រូវបានបន្ថែមដោយមិនធ្វើឱ្យសារជាតុ ឬវត្ថុប្រែប្រួល)។

លោករ៉ឺណេ ដេកាត (René Descartes) យល់ថា ការគិតគឺជាចំណុចសំខាន់នៃព្រលឹង ឯកម្មវត្ថុនៃការគិត គឺជា «ចៃដន្យ»។

ឧ. អាទិទេពគ្មានចៃដន្យទេ ព្រោះថា សច្ចភាពទាំងអស់របស់អាទិទេពសុទ្ធតែកើតឡើងដោយខ្លួនឯង។

**ចៃដន្យនិយម**
អ. accidentalism
បា. accidentalisme (m.)

ទ្រឹស្តីដែលយល់ថា លំហូរព្រឹត្តិការណ៍មានលក្ខណៈមិនអាចទាយទុកមុនបាន។ ពួកអេពីគួនិយម (Epicureanism) អះអាងថា ព្រឹត្តិការណ៍ខាងគំនិតមិនអាចព្យាករបានជាក់លាក់ទេ។

គេប្រើទ្រឹស្តីនេះដើម្បីប្រឆាំងនឹងទ្រឹស្តីទំនាក់ទំនង

ហេតុផល។ នៅក្នុងវិស័យអស្តិរូបវិជ្ជា ចៃដន្យ-និយមប្រឆាំងនឹងលទ្ធិដែលថា អ្វីៗទាំងអស់កើតឡើងពីហេតុផលកំណត់មួយ, ៤. ទស្សនវិទូ ភីធើ អាប៊ឺឡាដ (Peter Abelard) បានរិះគន់ «ចៃដន្យ-និយម» នៃគ្រូរបស់គាត់ វីលៀម អូហ្វ ឆេមប៉ូ (William of Champeaux) ដែលបាននិយាយថា លក្ខណសម្បត្តិនៃភាពចៃដន្យពឹងផ្អែកទៅលើភាពខុសគ្នារបស់បុគ្គលដែលមានពីកំណើត ព្រោះហេតុដូច្នេះ លក្ខណៈនៃភាពចៃដន្យនេះមិនអាចពន្យល់ពីភាពខុសគ្នារបស់បុគ្គលបានទេ។

# ឆ

**ឆន្ទៈ**
អ. will
បារ. volonté ( f. )

អំណាចនៃចិត្តក្នុងការជ្រើសរើសចំណង់ខ្លាំងបំផុតក្នុងចំណោមចំណង់ជាច្រើនដែលមានក្នុងខណៈពេលមួយនៃការសម្រេចចិត្ត ដែលស្ដែងឡើងតាមរយៈសកម្មភាពជាក់លាក់ណាមួយ។ **ឆន្ទៈ**មិនសំដៅលើចំណង់ជាក់លាក់ណាមួយទេ ប៉ុន្តែសំដៅលើសមត្ថភាពក្នុងការប្រព្រឹត្តប្រកបដោយការសម្រេចចិត្តចំពោះចំណង់របស់បុគ្គលណាម្នាក់។ នៅក្នុងទស្សនវិជ្ជា **ឆន្ទៈ**សំខាន់ណាស់ក្នុងនាមជាផ្នែកច្បាស់លាស់មួយនៃចិត្ត រួមជាមួយនឹងវិចារណញ្ញាណនិងការយល់ដឹង។ **ឆន្ទៈ**ត្រូវបានចាត់ទុកថាសំខាន់នៅក្នុងសីលវិជ្ជា ដោយសារតែតួនាទីស្នូលនៅក្នុងការជួយមនុស្សម្នាក់ៗឱ្យប្រព្រឹត្តប្រកបដោយបំណង។

## ជ

**ជែនសិននិយម**
អ. jansenism
បារ. jansénisme
(m.)

ចលនាទស្សនវិជ្ជានិងសាសនាដែលគេបានដាក់ឈ្មោះដូច្នេះ បន្ទាប់ពីសាសនវិទូហូឡង់ ឈ្មោះ ជែនសិន (Cornelius Otto Jansen,1585-1638) បានស្លាប់ទៅ។ ជែនសិននិយមរីកចម្រើនក្នុងសតវត្សរ៍ទី១៧និង១៨ នៅអឺរ៉ុបខាងលិច ជាពិសេសក្នុងប្រទេសបារាំង។ លក្ខណៈពិសេសរបស់ចលនានេះរួមមាន បុព្វវាសនានិយមដាច់ខាត និង ការប្រតិបត្តិតឹងរ៉ឹងខាងសីលធម៌។ កំណត់និយមបែបជែនសិន ជឿថា យើងមិនអាចបំពេញបទបញ្ជារបស់អាទិទេពបានដោយគ្មានជំនួយពីអាទិទេពឡើយ ប៉ុន្តែយើងមិនអាចបដិសេធជំនួយនេះបានឡើយ ប្រសិនបើអាទិទេពផ្តល់ឱ្យយើង។ លទ្ធិជែនសិនត្រូវបានរិះគន់យ៉ាងខ្លាំងថាជា អញ្ញទិដ្ឋិដោយសម្តេចប៉ាបទី១០ (Pope Innocent X) ហើយសហគមន៍ជែនសិនត្រូវបានរំលាយ ក្នុងឆ្នាំ១៧០៩។ ចលនាជែនសិននិយមនេះបានជះឥទ្ធិពលលើការគិតរបស់ប្លេស ប៉ាស្កាល(Blaise Pascal) ជនជាតិបារាំងបន្តរហូតដល់សតវត្សរ៍ទី១៩។
(ពាក្យនេះ គេប្រើក្នុងទស្សនវិជ្ជាអំពីសាសនា)

# ញ

**ញាណ**
អ. consciousness
បារ. conscience
(f.)

សភាពនៃការដឹងខ្លួន ការស្គាល់ ការយល់ ការចេះ និងការដឹងពីអ្វីមួយដែលកំពុងកើតឡើងនៅជុំវិញខ្លួនយើង។ ម្យ៉ាងទៀត **ញាណ** គឺជាសភាពចិត្ត ដូចជា ការឈឺចាប់ វេទនារម្មណ៍ គំនិត និង ការយល់ដឹងខាងផ្លូវចិត្តផ្សេងៗទៀត។

# ដ

**ដាច់ខាតនិយម/**
**អហង្ការនិយម**

អ. absolutism

បារ. absolutisme
(ញ.)

ទ្រឹស្តីទស្សនវិជ្ជាដែលយល់ថា សច្ចភាពនៃតម្លៃខាងសីលធម៌ឬតម្លៃខាងសោភ័ណ គឺដាច់ខាតនិងសកល ហើយមិនទាក់ទងនឹងភាពខុសគ្នារបស់បុគ្គលនិងរបស់សង្គមទេ។ វាជាទ្រឹស្តីមួយដែលនិយាយថា តថភាពគឺមានតែមួយនិងមិនអាចផ្លាស់ប្តូរ ឯការផ្លាស់ប្តូរនិងភាពប្លែកៗគ្នាគឺគ្រាន់តែជាដំណើរភាន់នៃគំនិតប៉ុណ្ណោះ។

ឧ. យោងតាមដាច់ខាតនិយម គោលការណ៍សីលធម៌មានតែមួយគត់និងមានលក្ខណៈសកល។

# ត

**តថនិយម**

អ. realism

បារ. réalisme (m.)

លទ្ធិមួយដែលចាត់ទុកថា មានពិភពសច្ចមួយដែលមានអត្ថិភាពមិនចំណុះមនុស្ស ប៉ុន្តែគេអាចយល់ដឹងបានតាមរយៈបញ្ញានិងប្រត្យក្សារម្មណ៍។

ពួកមនោនិយមអះអាងថា អ្វីមួយដែលជាបទពិសោធរបស់មនុស្ស គឺជាស្មារតីឬគំនិត រីឯពួកតថនិយមវិញអះអាងថា តថភាពមានទាំងរូបធាតុ (material) និងអរូបធាតុ (immaterial)។ វត្ថុរូបី កម្លាំង និងទំនាក់ទំនង គឺ «ស្ថិតនៅខាងក្រៅ» វង់ចាំរបកគំឃើញឬការយល់ដឹងពីមនុស្ស វាមិនមែនអនុលោមតាមឆន្ទៈ សេចក្តីសង្ឃឹម ជំនឿ ឬ បំណងរបស់មនុស្សជាតិឡើយ។

២. រសជាតិប្រៃរបស់អំបិល គឺជាតថភាពមួយដែលមានស្រាប់នៅក្នុងធម្មជាតិរបស់អំបិល។ បើយោងតាមពួកតថនិយម រសជាតិប្រៃនេះមានលក្ខណៈសត្យានុម័តិ ឯករាជ្យពីការកំណត់របស់មនុស្ស។ មនុស្សគ្រាន់តែអាចដឹងពីវាតាមរយៈជិវ្ហាវិញ្ញាណថាវាមានរសជាតិប្រៃ និងទទួលស្គាល់ការណ៍ពិត (សច្ចភាព)នៃតថភាពនោះតែប៉ុណ្ណោះ។

**តថភាពនិយមកញ្ឆោត**

អ. naive realism

បារ. réalisme naïf

ទស្សនៈសុភនិច្ឆ័យស្តីអំពីពិភពលោកដែលប្រកាន់យកដោយប្រជាជនសាមញ្ញភាគច្រើនបំផុត។ យោងតាមទស្សនៈនេះ ពិភពខាងក្រៅផ្សំពីវត្ថុផ្សេងៗ ដូចជា ទឹក ដី ភ្លើង ខ្យល់ ព្រៃឈើ ថ្ម ដី ជាដើម និងគុណភាពរបស់វត្ថុទាំងនោះ។ ពិភពលោកមានអត្ថិភាពនិងរីកចម្រើនដោយឯករាជ្យពីឥន្ទ្រិយារម្មណ៍ និងគំនិតរបស់យើង។ ឥន្ទ្រិយារម្មណ៍របស់យើងប្រៀបដូចជាកញ្ចក់ដែលឆ្លុះបញ្ចាំងអំពីតថភាពរបស់ពិភពលោក។ ទស្សនៈនេះក៏ជឿដោយឥតសង្ស័យដែរថា យើងមានលទ្ធភាពដឹងពីពិភពលោក។ ទោះជាយ៉ាងនោះក៏ដោយ ផ្អែកលើការពិចារណាទស្សនវិទូជាច្រើនបានរកឃើញថា ធម្មជាតិនៃពិភពលោក និងចំណេះដឹងរបស់យើងអំពីពិភពលោកមានលក្ខណៈស្មុគស្មាញនិងអាចកំបាំងជាងការពន្យល់របស់តថភាពនិយមកញ្ឆោត។ គុណភាពជាច្រើនដែលគេហៅថា បន្ទាប់បន្សំ ដូចជា ពណ៌ រសជាតិ និង ក្លិន គឺមិនអាចផ្តាច់ចេញពីវិញ្ញាណរបស់យើងដូចជាលក្ខណៈស្ថូល(ចាំបាច់) របស់វត្ថុដែលឯករាជ្យពីយើងនោះទេ។ ប្រត្យក្សារម្មណ៍របស់យើង ពេលខ្លះបំភាន់យើង។ ដោយផ្តើមចេញពីទស្សនៈនេះ យើងអាចដកស្រង់សំណួរទស្សនវិជ្ជាសំខាន់ៗ

ជាច្រើន ដូចជា "តើអ្វីជាការណ៍ពិត?" "តើអ្វីជាភាពស្មែងចេញ?" "តើមាយាការអាចកើតឡើងរបៀបណា?" "តើបទពិសោធរបស់យើងគឺជាប្រភពពុទ្ធិដែលអាចទុកចិត្តបានដែរឬទេ?" កិច្ចការមួយក្នុងចំណោមកិច្ចការសំខាន់របស់ទស្សនវិជ្ជាគឺគាស់កកាយការលំបាកនានាដែលកប់នៅក្នុងការសន្មតទូទៅអំពីការយល់ឃើញ ដូចជាតថភាពនិយមកញ្ចោតជាដើម ដើម្បីយល់ដឹងពីពិភពលោកឱ្យកាន់តែច្បាស់។

(ពាក្យនេះ គេប្រើនៅក្នុងពុទ្ធិវិទ្យា)

**តម្រេកនិយមសីលវិជ្ជា**

អ. ethical hedonism

បារ. hédonisme éthique

ទ្រឹស្តីសីលវិជ្ជាដែលអះអាងថា សេចក្តីរីករាយ ឬសុភមង្គល គឺជាកុសលធម្មជាតិខ្ពស់បំផុត និងជាគោលបំណងនៅក្នុងជីវិត និងថា មនុស្សគួរតែស្វែងរកសេចក្តីរីករាយឱ្យបានច្រើនបំផុត និងកាត់បន្ថយការឈឺចាប់ឱ្យនៅតិចបំផុត។ ទ្រឹស្តីនេះការពារដោយទស្សនវិទូក្រិកឈ្មោះ អារីស្ទីពុស (Arisstippus) និង អេពីកួ (Epicurus) ទស្សន-វិទូពិសោធន៍និយមជនជាតិអង់គ្លេស តូម៉ាស ហូប (Thomas Hobbes) ទស្សនវិទូផលប្រយោជន៍និយម ចន ឡុក(John Lock) ដាវីដ ហ៊ូម

(David Hume) និងទស្សនវិទូផលប្រយោជន៍-និយមផ្សេងៗទៀត។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ទស្សនវិទូតម្រេកនិយម បានបង្ហាញឱ្យឃើញពីភាពខុសគ្នាជាច្រើនទាក់ទងនឹងសេចក្តីរីករាយនេះ ហើយការយល់ដឹងពីភាពខុសគ្នានេះនាំឱ្យមានប្រភេទខុសៗគ្នានៃតម្រេកនិយម។ ជាទូទៅ មានការលើកឡើងថា សេចក្តីរីករាយគឺជាពាក្យអវិជ្ជមានដោយសារគេគិតថា សេចក្តីរីករាយនេះសំដៅតែទៅលើតម្រូវការខាងរាងកាយឬខាងវិញ្ញាណ។ ប៉ុន្តែទស្សនវិទូខាងតម្រេកនិយមអះអាងថា សេចក្តីរីករាយនេះមិនសំដៅតែទៅលើសេចក្តីរីករាយខាងឥន្ទ្រីយ៍នោះទេ។ លើសពីនេះទៀត សេចក្តីរីករាយក៏សំដៅទៅលើចំណង់ចំណូលចិត្ត សុភមង្គល និងឧត្តមគតិផងដែរ។

(ពាក្យនេះ គេប្រើក្នុងសីលវិជ្ជា)

**តម្លៃសច្ចភាព**
អ. truth-value
បារ. valeur de vérité

ភាពពិតឬភាពមិនពិតដែលមាននៅក្នុងសេចក្តីថ្លែងនីមួយៗ។ តក្កវិជ្ជាបុរាណអះអាងថា រាល់សេចក្តីថ្លែងត្រូវតែពិតឬមិនពិត ហើយភាពពិតឬភាពមិនពិតរបស់វាគឺជាតម្លៃសច្ចភាពរបស់វា។ ប្រសិនបើសេចក្តីថ្លែងនោះពិត តម្លៃសច្ចភាពរបស់វាគឺភាពពិត

ប្រសិនបើសេចក្ដីថ្លែងនោះមិនពិត តម្លៃសច្ចភាពរបស់វាគឺភាពមិនពិត។ «ធ្យូងថ្មនោះមានពណ៌ស» មិនពិត ដូច្នេះយើងនិយាយថា តម្លៃសច្ចភាពនៃប្រយោគនោះ គឺភាពមិនពិត។ «ទឹកកកសំឡីមានពណ៌ស» ពិត ដូច្នេះ យើងនិយាយថា តម្លៃសច្ចភាពនៃប្រយោគនោះ គឺភាពពិត។ ប្រសិនបើសេចក្ដីថ្លែងពីរដូចគ្នា វាមានតម្លៃសច្ចភាពដូចគ្នា។ គោលការណ៍ស្ដីពីទ្វិកលក្ខណៈ នៅក្នុងតក្កវិជ្ជាបុរាណទទួលស្គាល់តម្លៃសច្ចភាពតែពីរ ចំណែកឯទម្រង់មួយចំនួននៃតក្កវិជ្ជាទំនើប បដិសេធការសន្មតនេះ ហើយអះអាងថា តក្កវិជ្ជាមានតម្លៃបីឬច្រើន។ លោក ស្ត្រសាន់ (Strawson) អះអាងថា អាចមានសេចក្ដីថ្លែងដែលគ្មានតម្លៃសច្ចភាព ពោលគឺ សេចក្ដីថ្លែងដែលមិនពិត ហើយក៏មិនខុសដែរ និងដែលមានចន្លោះតម្លៃសច្ចភាព។

(ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា)

**តម្លៃសោភ័ណ**
អ. aesthetic value
បារ. valeur esthétique

លក្ខណៈនានាដែលធ្វើឱ្យស្នាដៃសិល្បៈមួយល្អ ឬ ជោគជ័យ ដូចជា តុល្យភាព ភាពទាក់ទាញ ប្រណីតភាព ភាពរស់រវើក ភាពស៊ីចង្វាក់ ភាពពេញលេញ ឬ ឯកភាព ពោលគឺជាអ្វីដែលជួយឱ្យស្នាដៃ

សិល្បៈមួយមាន «សោភណភាព» ហើយដែលខុសពីអ្វីដែលផ្ដល់ប្រយោជន៍សច្ចភាព និង សីលកុសលរបស់ស្នាដៃនោះ។

(បញ្ញត្តិនេះ គេប្រើនៅក្នុងសោភណវិជ្ជា)។

**តាវនិយម**
អ. taoism
បារ. taoïsme (m.)

ទស្សនវិជ្ជាចិនបុរាណដែលមានអត្ថន័យពីរយ៉ាង ៖
- **ទីមួយ** គឺជាទស្សនវិជ្ជាស្ដីអំពីភាពសាមញ្ញ និងភាពមិនជ្រៀតជ្រែក ពោលគឺសំដៅយកទស្សនវិជ្ជាចិនដែលគាំទ្រជីវិតសាមញ្ញនិងគោលការណ៍នៃការមិនជ្រៀតជ្រែកដំណើរវិវត្តន៍បែបធម្មជាតិរបស់អ្វីមួយ។ តាវនិយមត្រូវបានគេរកឃើញក្នុងសតវត្សរ៍ទី៦មុនគ្រិស្ដសករាជ ដោយ ឡៅស៊ឺ (Laotzu) ដែលជាទស្សនវិទូនិងអ្នកអធិធម្មជាតិ។
- **ទីពីរ** គឺជាសាសនាពេញនិយមរបស់ចិនដែលស្វែងរកសុខដុមនិងអាយុវែង តាមរយៈទស្សនវិជ្ជារបស់តាវនិយមដែលផ្សំពីអាទិទេពធម្មជាតិនិងការប្រតិបត្តិខាងវេទមន្ត។

**តូតឹម**
អ. totem
បារ. totem (m.)

វត្ថុ សត្វ រុក្ខជាតិ ឬ បាតុភូតធម្មជាតិដទៃទៀតដែលគេគោរពយ៉ាងខ្លាំងថាជាសញ្ញារបស់ក្រុមមនុស្សឬសង្គមណាមួយ ហើយជាញឹកញាប់ត្រូវបានគេប្រើ

នៅក្នុងពិធីសាសនាផ្សេងៗរបស់ពួកគេ។
៤. ជនជាតិគ្រឹងចាត់ទុក ទឹក ដី ជុំថ្ម...ថាជា **តូតឹម** របស់ខ្លួន។

**តូតឹមនិយម**
អ. totemism
បារ. totemisme (m.)

ជំនឿសាសនាដែលផ្អែកលើប្រព័ន្ធស្មុគស្មាញមួយ ដូចជា ការជឿលើគំនិត សញ្ញា និង ការប្រតិបត្តិ ដោយផ្អែកលើទំនាក់ទំនងដែលបានសន្មតរវាង បុគ្គល ក្រុម សង្គម និង វត្ថុធម្មជាតិដែលគេស្គាល់ថាជា**តូតឹម**។

**ត្រីមូរ្តិ / ត្រីមូរតិ**
អ. trimurti
បារ. trimurti (m.)

បញ្ញត្តិមួយដែលគេប្រើនៅក្នុងសាសនាហិណ្ឌូ សំដៅទៅលើអាទិទេពបីអង្គគឺ ព្រះព្រហ្ម (អ្នកបង្កើតលោក) ព្រះវិស្ណុ/ព្រះនរាយណ៍ (អ្នកការពារនិងថែរក្សាលោក) និង ព្រះសិវៈ/ព្រះឥសូរ (អ្នកបំផ្លាញ ឬបង្កើតលោកឡើងវិញ) ហើយត្រូវបានគេធ្វើបដិរូបកម្មជាប្រជុំអាទិទេព។ នៅពេលដែលអាទិទេពទាំងបីរបស់ត្រីមូរ្តិ / ត្រីមូរតិ ប្រែក្លាយទៅជាអវតារតែមួយ គេហៅថា **ទត្តាត្រេយ**។

**ត្រីអង្គ**
អ. trinity
បារ. trinité (f.)

បញ្ញត្តិមួយស្តីពីអាទិទេពនៅក្នុងលទ្ធិគ្រិស្តសាសនា ដែលជឿថា អាទិទេពមានអត្ថិភាពជាអង្គបីគឺ ព្រះវរបិតា ព្រះរាជបុត្រា(ព្រះយេស៊ូគ្រិស្ត) និង ព្រះវិញ្ញាណបរិសុទ្ធ។

**ត្រីអង្គនិយម**
អ. trinitarianism
បារ. trinitarianisme (m.)

លទ្ធិមួយនៅក្នុងគ្រិស្តសាសនាដែលជឿថា អាទិទេពមានអត្ថិភាពជាអង្គបី ប៉ុន្តែជាភាវៈតែមួយ។ អង្គទាំងបីនោះត្រូវបានគេយល់ថា មានអត្ថិភាពជា ព្រះវរបិតា ព្រះរាជបុត្រា (ព្រះយេស៊ូគ្រិស្ត) និង ព្រះវិញ្ញាណបរិសុទ្ធ ហើយអង្គនីមួយៗមានធម្មជាតិឬសារជាតិដូចគ្នា។

# ទ

**ទម្រង់ការសក្តិសិទ្ធិ**
អ. effective procedure
បារ. procédure efficace

ទម្រង់ការមួយដែលផ្តល់ផលនៅក្នុងដំណោះស្រាយបញ្ហាមួយទៅតាមជំហានជាក់លាក់មួយចំនួន។

**ទស្សនវិជ្ជា**
អ. philosophy
បារ. philosophie (f.)

ពាក្យនេះមានអត្ថន័យច្រើន យោងតាមសម័យកាល និងតាមទស្សនវិទូម្នាក់ៗ។ អត្ថន័យមូលដ្ឋាននៃពាក្យទស្សនវិជ្ជាគឺការស្រឡាញ់គតិបណ្ឌិត ពុទ្ធិ ឬ គតិវិញ្ញូ។ ក្រៅពីនេះ ទស្សនវិជ្ជា មានន័យផ្សេងទៀតដូចជា៖

១- **ការពិចារណាអំពីបញ្ញត្តិមូលដ្ឋាន** ជាផ្នែកជាងនៃពុទ្ធិឬការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រដែលផ្តោតជាសំខាន់ចំពោះការពិនិត្យ ការពិចារណាជាប្រព័ន្ធអំពីបញ្ញត្តិសំខាន់ៗ ដូចជា សច្ចភាព តថភាព ទំនាក់-ទំនងហេតុនិងផល និង សេរីភាព ជាដើម។

២- **និកាយគំនិត** ជាប្រព័ន្ធនៃគំនិត ឬ លទ្ធិមួយជាក់លាក់ ដូចជា អត្ថិភាពនិយម រូបធាតុនិយម មនោនិយម ជាដើម។

៣- **គោលការណ៍មូលដ្ឋានឬគោលការណ៍ណែនាំនានា** ជាបណ្តុំនៃគោលការណ៍ឬបញ្ញត្តិសំខាន់ៗដែលកប់

នៅក្នុងវិស័យជាក់លាក់ណាមួយនៃពុទ្ធិ ដូចជា ទ្រឹស្តីកិច្ចសន្យាសង្គមរបស់ ហ្សង់ ហ្សាក់ រូសូ (Jean Jacques Rousseau) និង គោលការណ៍បែងចែកអំណាចរបស់ ម៉ុងតេសស្គីយើ (Montesquieu) ជាដើម។

៤- **បណ្តុំជំនឿឬបំណងប្រាថ្នា** ជាសិក្ខាបទមួយឬច្រើនដែលបង្កប់នៅក្នុងឥរិយាបថឬការប្រតិបត្តិរបស់អ្នកណាម្នាក់។

៥- **ការប្រើវិចារណញ្ញាណក្នុងការស្វែងយល់អ្វីមួយ** ដូចជា ធម្មជាតិនៃតថភាពនិងអត្ថិភាព ការប្រើប្រាស់និងការកំណត់ពុទ្ធិ និង គោលការណ៍នានាដែលគ្រប់គ្រងនិងជះឥទ្ធិពលលើការវិនិច្ឆ័យខាងសីលធម៌ជាដើម។

ឧ. ការស្វែងយល់បាតុភូតរន្ធះ ការស្វែងយល់ពីរបត់ព្រះពុទ្ធសាសនានៅក្នុងសង្គមតាមបែបទស្សនវិជ្ជា។

**ទស្សនវិជ្ជាធម្មជាតិ**
អ. natural philosophy
បារ. philosophie naturelle

ការសិក្សាបែបវិទ្យាសាស្ត្រអំពីធម្មជាតិ ដែលក្នុងនោះរួមមាន បាតុភូតធម្មជាតិ និង វត្ថុធម្មជាតិ។

ទស្សនវិជ្ជាធម្មជាតិនេះមានឥទ្ធិពលខ្លាំងមុនពេលមានការអភិវឌ្ឍវិទ្យាសាស្ត្រទំនើប។ វាត្រូវបានគេចាត់ទុកថាជាបុព្វវត្ថុនៃវិទ្យាសាស្ត្រធម្មជាតិ ដូចជា រូបវិទ្យា ជាដើម។

៥១- អភិប្រាយបែបវិទ្យាសាស្ត្រ ឆ្នាំ១៦៨៧ របស់ អ៊ីសាក់ ញូតុន(Isaac Newton) ត្រូវបានគេស្គាល់ថាជា «គោលការណ៍គណិតវិទ្យានៃទស្សនវិជ្ជាធម្មជាតិ»,

៥២- អភិប្រាយ ឆ្នាំ១៨៦៧ របស់ Lord Kelvin និង Peter Guthrie Tait ដែលបានជួយកំណត់និយមន័យជាច្រើនអំពីរូបវិទ្យាទំនើប ត្រូវបានគេហៅថា «អភិប្រាយអំពីទស្សនវិជ្ជាធម្មជាតិ»។

**ទស្សនវិជ្ជានយោបាយ**
អ. political philosophy
បា. philosophie politique

ការសិក្សានិងការវិភាគអំពីប្រធានបទ ដូចជា ទម្រង់នៃរដ្ឋាភិបាល សេរីភាព យុត្តិធម៌ កម្មសិទ្ធិ សិទ្ធិ ច្បាប់ លទ្ធិ មនោគមវិជ្ជា ការពង្រឹងការអនុវត្តច្បាប់ដោយអាជ្ញាធរជាដើម ដោយចោទជាសំណួរថា សេរីភាព យុត្តិធម៌ កម្មសិទ្ធិ សិទ្ធិ ច្បាប់ លទ្ធិ មនោគមវិជ្ជា ការពង្រឹងការអនុវត្តច្បាប់ដោយអាជ្ញាធរ... ជាអ្វី?

**ទស្សនវិជ្ជាបស្ចិមប្រទេស**
អ. western philosophy
បារ. philosophie occidentale

ស្នាដៃនិងគំនិតនៃពួកបស្ចិមប្រទេស (បណ្ដាប្រទេសអឺរ៉ុបនិងអាម៉េរិក) ត្រូវបានគេបង្កើតឡើងដោយការគិតបែបទស្សនវិជ្ជាស្ដីពីអរិយធម៌បស្ចិមប្រទេស ជាពិសេសអរិយធម៌ដែលចាប់ផ្ដើមដោយទស្សនវិជ្ជាក្រិកបុរាណ។ ទស្សនវិជ្ជាបស្ចិមប្រទេសខុសគ្នាពីទស្សនវិជ្ជាបូព៌ាប្រទេស និង ទស្សនវិជ្ជាអន្ដោគ្រាម។

**ទស្សនវិជ្ជាអំពីចិត្ត**
អ. philosophy of mind
បារ. philosophie de l'esprit

ទស្សនវិជ្ជាដែលសិក្សាអំពីធម្មជាតិនៃចិត្ត ព្រឹត្តិការណ៍គំនិត (បាតុភូតគំនិត) មុខងារគំនិត លក្ខណសម្បត្តិគំនិត មនសិការ និង សម្ព័ន្ធភាពនៃធាតុទាំងនេះជាមួយនឹងរាងកាយ ជាពិសេសខួរក្បាល។

**ទស្សនវិជ្ជា អំពីច្បាប់**
អ. philosophy of law
បារ. philosophie du droit

ទស្សនវិជ្ជាមួយដែលសិក្សាអំពីបញ្ហាមូលដ្ឋាននៃច្បាប់ ប្រព័ន្ធច្បាប់ យុត្តិសាស្ត្រ លក្ខណវិនិច្ឆ័យសម្រាប់សុពលភាពនៃច្បាប់ ទំនាក់ទំនងរវាងច្បាប់និងសីលធម៌ ។ល។

ឧ. ដើម្បីសិក្សាមុខវិជ្ជាច្បាប់ឱ្យកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយទូលំទូលាយ គេត្រូវសិក្សាទស្សនវិជ្ជាអំពីច្បាប់។

**ទស្សនវិជ្ជា អំពីភាសា**
អ. philosophy of language
បារ. philosophie du langage

ទស្សនវិជ្ជាមួយដែលនិយាយពីធម្មជាតិនៃអត្ថន័យរបស់ភាសា, ការប្រើភាសា, ការសម្គាល់ភាសា និងទំនាក់ទំនងរវាងភាសានិងតថភាព។

ឧ. ការធ្វើទស្សនវិជ្ជាអំពីភាសាជាការធ្វើឱ្យការប្រើប្រាស់ភាសាកាន់តែសម្បូរបែប។

**ទស្សនវិជ្ជាអំពីសាសនា**
អ. philosophy of religion
បារ. philosophie de la religion

មែកធាងមួយនៃទស្សនវិជ្ជាដែលសិក្សា ពិនិត្យ និងវិភាគយ៉ាងល្អិតល្អន់និងប្រុងប្រយ័ត្នអំពីអំណះអំណាងរបស់សាសនាដែលគេបង្កើតឡើង និង អំពីអំណះអំណាងរបស់សាសនិកនិងសាសនវិទូល្បីៗ។ វិស័យសំខាន់ៗនៃការសិក្សានៅក្នុងទស្សនវិជ្ជាអំពីសាសនា រួមមាន ភស្តុតាងបែបទស្សនវិជ្ជាចំពោះអត្ថិភាពរបស់អាទិទេព សាសនវិជ្ជាបែបទស្សនវិជ្ជាដែលផ្តោតទៅលើការរៀបរាប់អំពីធម្មជាតិនិងអត្ថិភាពរបស់អាទិទេព និង ពុទ្ធិវិជ្ជាបែបសាសនាដែលយកចិត្តទុកដាក់ទៅលើស្ថានភាពនៃជំនឿដែលថាអាទិទេពមានអត្ថិភាព។

៖. យោងតាមទស្សនវិជ្ជាអំពីសាសនា ជំនឿ និងសាសនាផ្សេងៗនៅលើពិភពលោកត្រូវបានបង្កើតឡើងដោយមនុស្ស។

**ទស្សនវិជ្ជាអំពីវិទ្យាសាស្ត្រ**
អ. philosophy of science
បារ. philosophie des sciences

មែកធាងមួយនៃទស្សនវិជ្ជាដែលសិក្សាអំពីមូលដ្ឋានគ្រឹះ វិធីប្រព័ន្ធ ការអនុវត្តនិងវិបាក គោលបំណងនិងភាពគួរឱ្យជឿជាក់បាននៃទ្រឹស្តីវិទ្យាសាស្ត្រ។

**ទស្សនវិទូ**
អ. philosopher
បារ. philosophe
(m.)

អ្នកបង្កើតទស្សនវិជ្ជាឬអ្នកប្រាជ្ញខាងទស្សនវិជ្ជា។ អត្ថន័យផ្សេងៗនៃពាក្យនេះ មានដូចតទៅ៖

១- **អ្នកប្រាជ្ញ អ្នកជំនាញ ឬ អ្នកសិក្សាខាងទស្សនវិជ្ជា** សំដៅទៅលើអ្នកណាម្នាក់ដែលស្វែងរកការយល់ដឹង ការពន្យល់អំពីអត្ថិភាពនិងតថភាព ដូចជាសូក្រាត ខុង ជឺ ជាដើម។

២- **មនុស្សដែលប្រកបដោយការពិចារណា** អ្នកគិតដែលពិចារណាយ៉ាងហ្មត់ចត់និងជ្រៅជ្រះអំពីជីវិតកិច្ចការទូទៅរបស់មនុស្សនិងសង្គម។

៣- **មនុស្សប្រកបដោយហេតុផលនិងភាពអហិង្សា** អ្នកណាម្នាក់ដែលប្រតិកម្មដោយសន្តិវិធី និងប្រកបដោយហេតុផលចំពោះព្រឹត្តិការណ៍នានា ជាពិសេសចំពោះហេតុការណ៍អាក្រក់ឬស្ថានភាពលំបាក ដូចជាព្រះពុទ្ធ(លោកវិទូ) មហាត្មៈគន្ធី ជាដើម។

៤- **មនុស្សរស់នៅដោយអនុលោមទៅតាមទស្សនវិជ្ជាឬគតិបណ្ឌិត។**

៥- **អ្នកណាម្នាក់ដែលសិក្សាឬសរសេរអំពីអត្ថន័យនៃជីវិត។**

**ទឡ្ហីករណ៍បុព្វហេតុទីមួយ**

ទឡ្ហីករណ៍មួយនៃទឡ្ហីករណ៍បុរាណស្ដីអំពីអត្ថិភាពរបស់អាទិទេព។ ហេតុការណ៍នីមួយៗនៅក្នុងពិភព

អ. first cause argument
បារ. argument de la cause première

ធម្មជាតិមានបុព្វហេតុរបស់វា។ ទោះបីជាយ៉ាងណាក៏ដោយ ក៏គេមិនអាចរកឃើញបុព្វហេតុដំបូងបំផុតដែរ គឺគេគ្រាន់តែអាចត្រឡប់ទៅរកបុព្វហេតុនានាដោយពន្លាតថយក្រោយបន្តបន្ទាប់ប៉ុណ្ណោះ។ ដើម្បីបញ្ឈប់ការត្រឡប់ពន្លាតថយក្រោយនេះ យើងត្រូវតែសន្មតថា អ្វីជាបុព្វហេតុទីមួយ។ បុព្វហេតុទីមួយនេះ ត្រូវបានគេសន្មតថាជាសកម្មភាពនៃការបង្កើតរបស់អាទិទេព។

**ទឡ្ហីករណ៍ឯកភាព**
អ. henological argument
បារ. argument hénologique

ប្រភេទនៃអំណះអំណាងបែបទេវនិយមសម្រាប់អះអាងអំពីអត្ថិភាពរបស់អាទិទេពដោយប្រើប្រាស់ទម្រង់ដែលដូចគ្នានឹងវិធីទីបួនក្នុងវិធីទាំងប្រាំរបស់អាគីណាស់(Aquinas)។ តាមរយៈការសង្កេតដែលមានកម្រិតផ្សេងៗនៃកុសលភាព សុក្រឹតភាព សច្ចភាព និង តថភាព នៅក្នុងពិភពលោក អំណះ-អំណាងនេះសន្និដ្ឋានថា ត្រូវតែមានភាវៈមួយដែលតាងឱ្យកម្រិតខ្ពស់បំផុតនៃលក្ខណៈវិជ្ជមានទាំងអស់នេះ ក្នុងនាមជាភាពពេញលេញរបស់ពួកវា។ ភាវៈនេះជាភាវៈល្អបំផុត សុក្រឹតបំផុត សច្ចៈបំផុត និងពិតបំផុត ហើយភាវៈនោះគឺអាទិទេព។ ប្រសិនបើលក្ខណៈវិជ្ជមានអាចកើតមាននៅក្នុងកម្រិតផ្សេងៗគ្នា ដោយមិនត្រូវបានសម្រេចនៅក្នុងភាវៈមួយនៅ

កម្រិតខ្ពស់បំផុត ឬ ប្រសិនបើពុំមានកម្រិតខ្ពស់ដូចនោះទេ អំណះអំណាងនេះបរាជ័យ។

(ពាក្យនេះ គេប្រើនៅទស្សនវិជ្ជាអំពីសាសនា)

**ទារុណវិបត្តិ (ហាម៉ាត្យា)**
អ. hamartia
បា. hamartia

សំដៅទៅលើ**កំហុសឆ្គងឬបរាជ័យ**ដែលនាំឱ្យតួអង្គសំខាន់នៃទារុណកថា ឈានទៅដល់មហន្តរាយ ដាយថាហេតុ។

បច្ចេកសព្ទនេះ ប្រើដោយអារីស្តូត។

**ទេវធម្មជាតិនិយម**
អ. pantheism
បារ. panthéisme (m.)

លទ្ធិឬជំនឿដែលជឿថា ចក្រវាលគឺជាអាទិទេព។ ជំនឿនេះជឿថា អាទិទេពមិនមែនជាភាវៈដោយឡែកទេ ប៉ុន្តែគេជឿថា អាទិទេពជាតថភាពទាំងមូល ឬជាអំណាចដែលមានគ្រប់ទិដ្ឋភាពនៃតថភាព។ យោងតាមស្ពីណូហ្សា (Spinoza) អាទិទេពនិងធម្មជាតិគឺតែមួយ និង មានសារជាតុដូចគ្នា។

២. មនុស្សជំនាន់ដើមជឿថា ភពផែនដីគឺជាព្រះអាទិទេព (ព្រះធរណី)។

**ទេវនិយម**
អ. theism
បារ. théisme (m.)

លទ្ធិឬជំនឿមួយដែលជឿលើអត្ថិភាពនៃអាទិទេពមួយឬច្រើន។

ជំនឿនេះចាត់ទុកអាទិទេពថា ជាអ្នកបង្កើតលោក ជាប្រភពនៃតម្លៃទាំងអស់ ជាភាវៈមួយដែលមានវត្តមានគ្រប់ដំណើរទាំងអស់ក្នុងលោកនេះ ជាភាវៈ

ស្មារតី និង ជាភាវៈមនុស្ស ហើយ តាមរយៈនេះ មនុស្សអាចទាក់ទងជាមួយអាទិទេពយ៉ាងជិតស្និទ្ធ។

២. ជនជាតិក្រិកបុរាណមានជំនឿលើទេវនិយម។

**ទេវាធិបតេយ្យ**

អ. theocracy

បារ. théocratie (f.)

ទម្រង់នៃការគ្រប់គ្រងរដ្ឋដែលច្បាប់និងបទបញ្ញត្តិទាំងឡាយកើតចេញពីក្រឹត្យក្រម (ច្បាប់) ដែលកំណត់ដោយសាសនាណាមួយ។ ទម្រង់នៃការគ្រប់គ្រងរដ្ឋបែបនេះ ដឹកនាំដោយផ្អែកលើច្បាប់អាទិទេព ហើយអាទិទេពត្រូវបានចាត់ទុកជាប្រមុខរដ្ឋ។ គម្ពីរ-ពិសិដ្ឋរបស់សាសនាត្រូវបានចាត់ទុកជាសារ ឬបទ-បញ្ជា ឬក៏ច្បាប់របស់អាទិទេព ហើយត្រូវបានប្រើប្រាស់ដើម្បីដឹកនាំសង្គមឬរដ្ឋ។ ជាញឹកញាប់ ទម្រង់នៃការគ្រប់គ្រងរដ្ឋបែបទេវាធិបតេយ្យត្រូវបានគ្រប់-គ្រងដោយឥស្សរជនសាសនា ឬ ក្រុមបព្វជិតដែលកាន់អំណាចនយោបាយក្នុងនាមអាទិទេព។

ឥស្សរជនទាំងនោះបកស្រាយគម្ពីរពិសិដ្ឋសាសនាដើម្បីគោលបំណងនយោបាយរបស់ខ្លួន ហើយអះ-អាងថា ពួកគេគោរពនិងអនុវត្តឆន្ទៈរបស់អាទិទេព។

**ទុទិដ្ឋិនិយម**

អ. pessimism

បារ. pessimisme (m.)

លទ្ធិមួយដែលចាត់ទុកថាជាសារវន្តជីវិតគឺអាក្រក់ពោលគឺ នៅក្នុងពិភពលោកមានការឈឺចាប់ច្រើនជាងការសប្បាយរីករាយ, មានអកុសលច្រើនជាងកុសល។

៤. ទស្សនវិជ្ជាជីវិតឥតន័យរបស់ អាល់ប៊ែរ កាមុស (Albert Camus) គឺជាទស្សនៈទុទិដ្ឋិនិយម។

**ទំនាក់ទំនងនិយម**
អ. relativism
បារ. relativisme (m.)

លទ្ធិមួយដែលតែងតែបញ្ជាក់ថា ក្នុងវិស័យមួយចំនួន យ៉ាងហោចណាស់សច្ចភាពខ្លួនវាទាក់ទងទៅនឹងទស្សនៈរបស់អ្នកវិនិច្ឆ័យ (ឧទាហរណ៍ : សោភណភាពនៃអ្វីមួយអាស្រ័យលើភ្នែករបស់អ្នកសង្កេត)។ សេចក្តីថ្លែងបុរាណដំបូងគេគឺជាលទ្ធិរបស់ពួកសូហ្វីស (Sophist) ដែលប្រូតាហ្គ៉ា (Protagoras) អះអាងថា «មនុស្សគឺជារង្វាស់នៃអ្វីៗទាំងអស់»។

ទំនាក់ទំនងនិយមអាចជាលទ្ធិសាកលមួយដែលនិយាយអំពីរាល់ពុទ្ធិទាំងអស់ ឬ ជាលទ្ធិដោយឡែកមួយដែលនិយាយអំពីវិស័យណាមួយ(ឧទាហរណ៍ : សោភណវិជ្ជា សីលវិជ្ជា ឬ ការវិនិច្ឆ័យអំពីគុណភាពបន្ទាប់បន្សំ)។ ទិដ្ឋភាពនានាដែលជះឥទ្ធិពលលើការវិនិច្ឆ័យរបស់ប្រធាន(អ្នកវិនិច្ឆ័យ) ចំពោះការសន្មតថាអ្វីមួយពិតឬមិនពិតចំពោះពួកគេ អាចរួមមានមូលដ្ឋានប្រវត្តិសាស្ត្រ វប្បធម៌ សង្គម ភាសា ឬចិត្តសាស្ត្រ ឬក៏សុខភាពនៃសរីរាង្គវិញ្ញាណ។

ទំនាក់ទំនងនិយម ជាញឹកញាប់ ត្រូវបានបដិសេធ

ដោយផ្អែកលើមូលដ្ឋានថា ជំនឿឬការវិនិច្ឆ័យត្រូវតែឆ្លើយតបទៅនឹងនិយាមនានា ដោយឯករាជ្យពីទំនោររបស់មនុស្សម្នាក់ៗ។

**ទំនាស់វណ្ណៈ**
អ. class conflict
បា. conflit de classe

ជាទូទៅ សំដៅទៅរកការតស៊ូវណ្ណៈឬសង្គ្រាមវណ្ណៈ ពោលគឺជាភាពតានតឹង ឬ បដិបក្ខនិយមដែលកើតឡើងនៅក្នុងសង្គម បណ្តាលមកពីការប្រកួតប្រជែងផលប្រយោជន៍សេដ្ឋកិច្ចសង្គមនិងសេចក្តីប្រាថ្នាផ្សេងៗរបស់មនុស្សនៅក្នុងសង្គម ដែលមានវណ្ណៈខុសៗគ្នា។

**ទំនោរ**
អ. tendency
បារ. tendance (f.)

ទិដ្ឋភាពនៃការប្រព្រឹត្តរបស់មនុស្សម្នាក់ៗ ដែលបង្ហាញតាមវិធីជាក់លាក់ណាមួយ ហើយជាកម្លាំងចលករខាងផ្លូវចិត្តច្បាស់លាស់តម្រង់ទៅរកគោលបំណងជាក់លាក់ណាមួយ។ តាមធម្មជាតិរបស់មនុស្ស ទំនោរសុទ្ធតែជាកម្លាំងពិតប្រាកដ ហើយសុទ្ធតែមានគោលបំណងជាក់លាក់។ តាមវិទ្យាសាស្ត្រ គោលបំណងទាំងឡាយពុំមែនកើតឡើងដោយឯកឯងនោះទេ ផ្ទុយទៅវិញវាសុទ្ធតែមានប្រភពរបស់វា។

**ទ្រឹស្ដីតម្លៃពលកម្ម** ទស្សនៈដែលយល់ថា តម្លៃនៃទំនិញឆ្លុះបញ្ចាំងពីបរិមាណពលកម្មដែលពាក់ព័ន្ធក្នុងដំណើរផលិតកម្មរបស់ទំនិញ។

អ. labour theory of value

បារ. théorie de la valeur du travail

**ទ្រឹស្ដីសកម្មភាព** វិស័យមួយនៃទស្សនវិជ្ជាដែលយកចិត្តទុកដាក់លើដំណើរបង្កឱ្យមានប្រភេទចលនាស្មុគស្មាញនៃរាងកាយរបស់មនុស្ស។

ទ្រឹស្ដីនេះសិក្សាពីរចនាសម្ព័ន្ធនៃសកម្មភាពមនុស្ស ដំណើរដែលបង្កឱ្យមានសកម្មភាព និង វិធីដែលគេពន្យល់ពីសកម្មភាព។

អ. action theory

បា. théorie de l'action

**ទ្វិកនិយម** លទ្ធិទស្សនវិជ្ជាដែលទទួលស្គាល់គោលការណ៍ឬគំនិតពីរឬក៏ប្រព័ន្ធពីរផ្សេងគ្នា ក្នុងតថភាពតែមួយ។

អ. dualism

បារ. dualisme ( m. )

**ធ្វើទស្សនវិជ្ជា**
អ. philosophize
បារ. philosopher

បង្កើតទស្សនវិជ្ជា ដែលសំដៅលើ៖

១- ពិភាក្សាអំពីធម្មជាតិនៃតថភាព ផ្តល់យោបល់ ឬព្យាយាមពន្យល់អំពីធម្មជាតិនៃជីវិតនិងតថភាព ឬ ផ្នែកមួយនៃតថភាព ដូចជា សីលវិជ្ជា តក្កវិជ្ជា ពុទ្ធិ ឬ អត្ថិភាព។

២- ពិចារណា ពន្យល់ ឬ ដោះស្រាយបញ្ហាអ្វីមួយ ដោយផ្តើមចេញពីការយល់ឃើញបែបទស្សនវិជ្ជា។

៣- ជជែកស៊ីជម្រៅអំពីអត្ថន័យនៃជីវិត។

ឧ. នៅពេលមនុស្សណាម្នាក់កំពុងជជែកស៊ីជម្រៅ អំពីអត្ថន័យនៃជីវិត មានន័យថា មនុស្សនោះកំពុង ធ្វើទស្សនវិជ្ជាហើយ។

# ន

**នរក**
អ. hell
បារ. enfer (m.)

តាមលទ្ធិគ្រិស្តសាសនា នរកជាលោកឬសភាវៈសម្រាប់អ្នកសាងបាបដែលមិនភ្ញាក់រឭកក្រោយពេលពួកគេស្លាប់ទៅ ហើយអ្នកសាងបាបទាំងនោះត្រូវកាត់ផ្តាច់ពីអាទិទេព និងទទួលរងទណ្ឌកម្មផ្សេងៗផងដែរ។

តាមទស្សនៈពុទ្ធសាសនា នរកជាទីអបាយភូមិឬអធោលោកដែលមានរណ្តៅជាលំនៅនៃសត្វមានបាបនៅរងទុក្ខតាមកម្លាំងកម្មដែលខ្លួនបានធ្វើ។

**នវប្លាតុងនិយម**
អ. neoplatonism
បារ. néoplatonisme (m.)

ប្រព័ន្ធទស្សនវិជ្ជាមួយដែលផ្សំពីប្លាតុងនិយម និងជំនឿខាងសាសនាដែលមានលក្ខណៈអាថ៌កំបាំង/គូឡ្ហធម្ម (mysticism) នៅក្នុងគំនិតរបស់យូដា (judaic ideas) និង នៅក្នុងគំនិតរបស់គ្រិស្តសាសនិក (christian ideas)។

ប្រព័ន្ធទស្សនវិជ្ជានេះត្រូវបានបង្កើតឡើងដំបូងដោយលោក ផ្លូទីនុស (Plotinus) ជាទស្សនវិទូរ៉ូម៉ាំង ចាប់ពីសតវត្សរ៍ទី៣ ហើយបន្តអភិវឌ្ឍដល់សតវត្សរ៍ទី៥នៃគ្រិស្តសករាជ។

**នវសេរីនិយម**
អ. neoliberalism
បារ. néolibéralisme

គំរូគោលនយោបាយមួយស្តីអំពីការសិក្សាសង្គម និងសេដ្ឋកិច្ច ដែលផ្ទេរការគ្រប់គ្រងវិស័យសេដ្ឋ-កិច្ចពីរដ្ឋទៅឯកជន។ នវសេរីនិយមមានប្រភពពី

គោលការណ៍មូលដ្ឋាននៃសេដ្ឋកិច្ចនវក្លាសុិក (neoclassical economics) ដែលស្នើថា រដ្ឋាភិបាលត្រូវតែកម្រិតឧបត្ថម្ភធន ធ្វើកំណែទម្រង់ច្បាប់ពន្ធ ដើម្បីពង្រីកមូលដ្ឋានពន្ធ កាត់បន្ថយឱនភាពថវិកាកម្រិតគាំពារនិយម (limit protecttionism) និងបើកចំហទីផ្សារទៅរកពាណិជ្ជកម្ម។ នវសេរីក៏ស្វែងរកការលុបចោលនូវអត្រាប្តូរប្រាក់ថេរ គាំទ្រការកាត់បន្ថយការគ្រប់គ្រងរបស់រដ្ឋមកលើធុរកិច្ច អនុញ្ញាតឱ្យមានទ្រព្យសម្បត្តិឯកជន និងធ្វើឯកជននីយកម្មធុរកិច្ច។

**និព្វាន**

អ. nirvana

បារ. nirvana

(m.)

និព្វានត្រូវបានបកស្រាយខុសៗគ្នាដូចខាងក្រោម៖

- ឈ្មោះធម្មជាតិឬចិត្តដែលចេញចាកផុតពីកិលេស និងតណ្ហា អស់មានកម្មជាអ្នកតាក់តែងនាំឱ្យមានការកើតក្នុងវដ្ត និងជាទីបរមសុខស្ងប់ដែលកើតចេញពីសីល សមាធិ និង បញ្ញា។

- សភាពឥតខ្ចោះឬបរមសុខ និង ភាពស្ងប់ដែលកើតឡើងដោយការរំលត់ចំណង់និងតណ្ហា និងភាពអស្ចារ្យក្នុងការផ្តាច់អត្ថិភាពរបស់អត្តៈ។ (ព្រះពុទ្ធសាសនា)

- ការរួបរួម ឬ ការដឹងអំពីអត្តសញ្ញាណនៃអាត្ម័ន

ជាមួយព្រហ្មនដែលគេជឿថា អាត្មននេះមានភាពអមតៈ (Brahman)។ (ហិណ្ឌូសាសនា)

- ការរំដោះព្រលឹងចេញពីទាសភាពនៃកម្មនិងសំសារៈ ហើយវាក៏មានន័យថាជាគោលដៅសង្គ្រោះផងដែរ។ (ជេនសាសនា)

(វេវចនៈនឹងពាក្យ *និព្វាន* មានដូចជា *និវាណ មោក្ស មោក្ខ វិមុត្តិ* ជាដើម)។

**និមិត្តសត្វ**
អ. animal symbolicum
បារ. animaux symbolicum

តាមទស្សនៈរបស់លោក កាស៊ីរើ (Ernst Cassirer) **និមិត្តសត្វ** សំដៅទៅលើមនុស្សដែលមានលក្ខណៈពិសេសរបស់ខ្លួនអាស្រ័យទៅលើសមិទ្ធផល ដោយមិនអាស្រ័យលើរូបកាយនិងស្មារតីនោះទេ។

**និយាមសីលធម៌**
អ. moral norm
បារ. norme de morale

គោលការណ៍នៃអំពើត្រឹមត្រូវដែលកំណត់ដោយសមាជិកនៃក្រុមមួយ។

ការប្រព្រឹត្តដែលផ្អែកលើគោលការណ៍ទាំងនេះគឺជាគំរូមួយ ដែលបន្ទាប់មកត្រូវបានគេយកលំនាំតាម និងវិនិច្ឆ័យថាល្អឬអាក្រក់។

ឧ. ក្មេងត្រូវតែគោរពចាស់ គឺជានិយាមសីលធម៌ខ្មែរ។

**បច្ឆាពិសោធន៍**
អ. a posteriori
បា. a posteriori

ដែលមានក្រោយបទពិសោធ។ នៅក្នុងទស្សនវិជ្ជា វាទាក់ទងទៅនឹងពុទ្ធិដែលគេដឹងតាមរយៈបទពិសោធ ហើយវាជាបញ្ញត្តិសំខាន់នៅក្នុងពុទ្ធិវិទ្យា។ អ្នកពិសោធន៍និយមអះអាងថា ពុទ្ធិដែលផ្អែកលើបទ-ពិសោធ គឺជាពុទ្ធិពិតតែមួយគត់ ដោយទទូចថា អ្វីៗទាំងអស់ដែលយើងអាចដឹងបាន គឺជាអ្វីដែលចូលមកក្នុងខ្លួនយើងតាមរយៈបទពិសោធ ជាពិសេសតាមរយៈការដឹងដោយវិញ្ញាណ (ពុទ្ធិឥន្ទ្រិយ)។

**បញ្ញត្តិកម្ម**
អ. conception
បារ. conception (f.)

ការបង្កើតគំនិត ពោលគឺជាដំណើរនៃការឈានទៅដល់គំនិត ឬ ជំនឿអរូបីមួយ ឬ ខណៈមួយដែលគំនិតអរូបិយនោះចាប់ផ្ដើមចាប់យកទម្រង់មួយ ឬផុសឡើង។

**បញ្ហាចិត្ត-កាយ**
**អ.** mind-body problem

បញ្ហាទស្សនវិជ្ជាអំពីចិត្តដែលនិយាយអំពីទំនាក់ទំនងរវាងចិត្តនិងកាយ។ បញ្ញត្តិនេះត្រូវបានបង្កើតឡើងដំបូងដោយប្លាតុង (Platon/Plato) និងអារីស្តូត (Aristote/Aristotle) ហើយក្រោយមក ដេកាត (Descartes) បានចាត់ទុកបញ្ហាចិត្ត-កាយនេះជាបញ្ហាស្នូលក្នុងទស្សនវិជ្ជាទំនើប។

ដេកាតអះអាងថា ចិត្តមានការគិតជាខ្លឹមរបស់វា ហើយចិត្តគឺជាអង្គដាច់ដោយឡែកពីរាងកាយឬជាសារធាតុបន្ថែម។

មានទស្សនៈពីរដែលនិយាយពីបញ្ហាចិត្ត-កាយ គឺឯកនិយម(monism) និង ទ្វិកនិយម(dualism)។ ឯកនិយមអះអាងថា មនុស្សត្រូវបានបង្កើតពីរូបធាតុឬកាយ ហើយអ្វីៗដែលលេចចេញពីកាយគឺគ្រាន់តែមុខងារនៃកាយប៉ុណ្ណោះ។ ចំណែកឯទ្វិកនិយមវិញអះអាងថា មនុស្សត្រូវបានបង្កើតឡើងពីធាតុពីរគឺកាយ(រូបធាតុ)និងចិត្ត(ស្មារតីឬព្រលឹង)ដែលមិនអាចកាត់ផ្តាច់ពីគ្នាបានទេ។

(ពាក្យនេះ គេប្រើនៅក្នុងទស្សនវិជ្ជាអំពីចិត្ត)

**បដិសំយោគ**

អ. dialectic

បារ. dialectique (f.)/ méthode dialectique

វិធី សិល្បៈនៃការស្វែងរកសច្ចភាពតាមរយៈការពិចារណា ការពិភាក្សា លើទស្សនៈមួយដែលយល់ឃើញពីចរិតលក្ខណៈមិនអាចកាត់ផ្តាច់ចេញពីគ្នាបាននៃសំណើដែលប្រឈមគ្នាឬគំនិតដែលយល់ឃើញខុសគ្នា ហើយដែលគេអាចរួមបញ្ចូលមកជាសម្មតិកម្មសំយោគមួយ។

យោងទៅតាមទស្សនៈផ្សេងៗស្តីអំពីដំណើរនៃការពិចារណានេះ បញ្ញត្តិកម្មខុសគ្នាស្តីអំពីបដិសំយោគបានលេចឡើង៖

- ក្នុងវិធីរបស់សូក្រាត(Socrates) បដិសំយោគ គឺជាដំណើរការនៃការទាញយកសច្ចភាពតាមរយៈ មធ្យោបាយនៃការសួរដេញដោលដើម្បីលាតត្រដាង នូវអ្វីដែលបានដឹងរួចហើយ តែមិនទាន់ច្បាស់លាស់ ឬការលាតត្រដាងនូវបដិវាទកម្មនិងសភាពភាន់ច្រឡំ នៃជំហរបស់អ្នកប្រឆាំង។

- ក្នុងកិច្ចសន្ទនាដំណាក់កាលកណ្ដាលរបស់ប្លាតុង (Platon) បដិសំយោគក្លាយទៅជាដំណើរការ ពេញលេញនៃការយល់ដឹងជ្រៅជ្រះ។

- ចំពោះអារីស្តូត(Aristotle) បដិសំយោគគឺជា ការពិចារណាសមហេតុផលលើមូលបដិញ្ញាដែល គួរឱ្យជឿជាក់។

- តាម កាន្ត (Immanuel Kant) បដិសំយោគ គឺជាតក្កវិជ្ជាស្តីពីមាយាការឬការប្រើប្រាស់តក្កវិជ្ជា ខុសក្នុងការផ្ដល់នូវទម្រង់នៃជំនឿដ៏រឹងមាំ។ វាជា ការងារមួយនៃការងាររបស់ទស្សនវិជ្ជាពិតក្នុងការ បង្ហាញឱ្យឃើញនូវទីកន្លែងដែលវិចារណញ្ញាណ ប្រព្រឹត្តកន្លងព្រំដែនត្រឹមត្រូវនានារបស់វា។ ការងារ នេះបង្កើតមាយាការរបស់អស្តិរូបវិជ្ជាអតិសេដ្ឋ។

- តាម ហេហ្គេល(Hegel) បដិសំយោគសំដៅ យកដំណើរការចាំបាច់ដែលបង្កើតការរីកចម្រើន

ទាំងក្នុងគំនិតនិងពិភពលោក។ ដំណើរការណ៍នោះគឺជាការខិតខំប្រឹងប្រែងដោះស្រាយបដិវាទកម្មរវាងមតិស្របនិងមតិផ្ទុយតាមរយៈមធ្យោបាយនៃសំ-យោគ។ ជាលទ្ធផល សំយោគនេះបែរជាត្រូវបានគេជំទាស់ ហើយដំណើរនេះប្រព្រឹត្តទៅសាចុះសាឡើងរហូតដល់ឈានទៅសម្រេចបានសុក្រឹតភាពចុងក្រោយ។

**បិតាធិបតេយ្យ**

អ. paternalism

បារ. paternalisme (m.)

របៀបនៃការគ្រប់គ្រងនិងការដឹកនាំរដ្ឋដែលមានលក្ខណៈស្រដៀងនឹងការគ្រប់គ្រងរបស់ឪពុកទៅលើកូន ឬ ការគ្រប់គ្រងដែលមានលក្ខណៈរួមផ្សំរវាងការប្រើអំណាចជាមួយនឹងការទទួលខុសត្រូវក្នុងការមើលថែសមាជិកដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ នៅក្នុងសីលវិជ្ជា ពាក្យនេះមានន័យថាជាការជ្រៀតជ្រែកចូលទៅក្នុងសេរីភាពរបស់អ្នកណាម្នាក់ ដោយជឿថា ការជ្រៀតជ្រែកនោះគឺដើម្បីលើកកម្ពស់កុសលរបស់អ្នកនោះ ឬ ការពារអ្នកនោះពីគ្រោះថ្នាក់ដែលកើតឡើង ទោះបីការជ្រៀតជ្រែកនោះបង្កឱ្យមានការជំទាស់ ឬ ការតវ៉ាពីបុគ្គលដែលត្រូវបានគេជ្រៀតជ្រែកសេរីភាពនោះក៏ដោយ។

បច្ចុប្បន្ន បិតាធិបតេយ្យត្រូវបានជំទាស់ដោយ

ទស្សនៈសេរីនិយម ដោយគេយល់ថាជាការធ្វើឱ្យបាត់បង់សេរីភាព ស្វ័យភាព និង សិទ្ធិបុគ្គល។

(ពាក្យនេះ គេប្រើនៅក្នុងសីលវិជ្ជានិងទស្សនវិជ្ជានយោបាយ)

**បុគ្គលភាពនិយម**
អ. personalism
បារ. personnalisme
(ព.)

លទ្ធិមួយដែលផ្ដោតការយកចិត្តទុកដាក់ទៅលើតថភាពរបស់ពិភពលោក ហើយអត្ថន័យនៃពាក្យ «បុគ្គលភាពនិយម» មានន័យជាច្រើនដូចខាងក្រោម៖

១- លទ្ធិមួយដែលអះអាងថា តថភាពដាច់ខាតរបស់ពិភពលោក គឺទេវបុគ្គលដែលជាអ្នកទ្រទ្រង់ចក្រវាលដោយអំពើជាបន្តបន្ទាប់នៃឆន្ទៈបង្កើតរបស់អាទិទេព។

២- លោក Edgar Sheffield Brightman ដែលជាអ្នកបុគ្គលភាពនិយមសហសម័យដ៏ឆ្នើមម្នាក់យល់ថា «បុគ្គលភាពនិយមគឺជាប្រព័ន្ធទស្សនវិជ្ជាមួយដែលចាត់ទុកបុគ្គលភាពរបស់មនុស្សថាជាតថភាពអស្តិរូបវិជ្ជាតែមួយគត់ (ឬសំខាន់បំផុត) ព្រមទាំងមានតម្លៃខ្ពង់ខ្ពស់ពិតប្រាកដ»។

៣- លោក Copleston ឱ្យនិយមន័យ «បុគ្គលភាពនិយម» ថាជាទស្សនវិជ្ជាមួយដែលមានជំនឿ

ជាមូលដ្ឋានថា តថភាពគឺជាប្រព័ន្ធនៃបុគ្គលភាព ដែលជាធាតុមិនអាចបំបែកបាននៃអត្ថិភាពទាំង-អស់។

២. ទស្សនៈថា តថភាពមានលក្ខណៈរូបីនិងដោយឡែក មានលក្ខណៈបុគ្គលភាពនិយម។

**បុព្វវាសនា**
អ. predestination
បារ. prédestination (f.)

សាសនវិជ្ជាដែលអះអាងថា ព្រឹត្តិការណ៍ទាំងអស់នៅក្នុងដំណើរជីវិតរបស់មនុស្សម្នាក់ៗ ពោលគឺអ្វីៗដែលបានកើតឡើង កំពុងកើតឡើង ឬនឹងកើតឡើងត្រូវបានកំណត់ជាមុនដោយអាទិទេព និងមិនអាចកែប្រែបាន។ ការកំណត់ថា តើព្រលឹងរបស់មនុស្សម្នាក់ៗនឹងឡើងទៅឋានសួគ៌ ឬធ្លាក់ទៅឋាននរកត្រូវបានសម្រេចដោយឆន្ទៈរបស់អាទិទេពតាំងពីមនុស្សនោះកើតមកម្ល៉េះ ដោយមិនអាស្រ័យលើការប្រព្រឹត្តរបស់គេឡើយ។

(ពាក្យនេះ គេប្រើនៅក្នុងទស្សនវិជ្ជាអំពីសាសនាអស្តិរូបវិជ្ជា និង តក្កវិជ្ជា)

**បុរេពិសោធន៍**
អ. a priori
បារ. a priori

«ដែលមានមុនបទពិសោធ»។ នៅក្នុងទស្សនវិជ្ជាវាទាក់ទងទៅនឹងពុទ្ធិដែលគេទទួលបានដោយមិនផ្អែកលើបទពិសោធ ពោលគឺ គេទទួលបានពុទ្ធិ

នោះ តាមការពិចារណាបែបអនុមានញែកតែមួយប៉ុណ្ណោះ។ ពុទ្ធិដែលឯករាជ្យពីបទពិសោធ មានសារៈសំខាន់(ជាមូលដ្ឋាន) ចំពោះមែកធាងមួយចំនួនរបស់ពុទ្ធិវិជ្ជាជាពិសេសចំពោះទ្រឹស្តីវិចារណញ្ញាណនិយមនានា។

**ប្រតិបត្តិនិយម**
អ. pragmatism
បារ. pragmatisme
(m.)

ទស្សនវិជ្ជាមួយដែលនិយាយថា អត្ថន័យ តម្លៃ និងសច្ចភាពនៃគំនិត ទ្រឹស្តី ឬជំនឿមួយ ត្រូវបានកំណត់ដោយលទ្ធផលនៃការប្រតិបត្តិជាក់ស្តែងរបស់វា និងអះអាងថា មុខងាររបស់គំនិត គឺបង្កើតឬដឹកនាំសកម្មភាព។

ឧ. ទ្រឹស្តីប្រតិបត្តិនិយមបានពន្យល់ថា បើចង់ដឹងថា សីលប្រាំនៅក្នុងព្រះពុទ្ធសាសនាល្អឬមិនល្អ យើងត្រូវតែយកវាទៅអនុវត្តឬប្រតិបត្តិ បន្ទាប់មកពិនិត្យមើលលទ្ធផលរបស់វា។ បើចង់ដឹងថា គោល-ការណ៍ ទ្រឹស្តី រូបមន្ត សេចក្តីសម្រេចចិត្ត ច្បាប់ គំនិតណាមួយ។ល។ ត្រូវឬខុស ត្រូវតែយកវាទៅអនុវត្ត បន្ទាប់មកត្រូវពិនិត្យមើលផលប៉ះពាល់ ឬលទ្ធផលរបស់វា។ បើលទ្ធផលល្អភាគច្រើន នោះវាពិតជាត្រឹមត្រូវ ប៉ុន្តែប្រសិនបើលទ្ធផលភាគច្រើនមិនល្អ នោះវាពិតជាមិនត្រឹមត្រូវទេ។

**ប្រធាន**
អ. subject
បារ. sujet (m.)

មនុស្សណាម្នាក់ ក្រុមណាមួយ ដែលធ្វើអំពើតាមផ្លូវកាយឬតាមផ្លូវចិត្តទៅលើមនុស្សណាម្នាក់ ក្រុមណាមួយ ឬ ទៅលើអ្វីមួយ។

ឧ. សកម្មជនឬក្រុមមនុស្សដែលកំពុងតាមដាននិងវាយតម្លៃអំពីស្ថានការណ៍សិទ្ធិមនុស្សនិងការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា គឺជាប្រធាន។

**ប្រយោជន៍និយម**
អ. utilitarianism
បារ. utilitarisme (m.)

លទ្ធិមួយរបស់ទស្សនវិជ្ជាសីលធម៌ដែលយល់ថា សេចក្តីរីករាយខាងវិញ្ញាណ ឬ សុភមង្គលសម្រាប់មនុស្សភាគច្រើននៅក្នុងសង្គម គឺជាកុសលដ៏ប្រសើរ និងជាគោលបំណងដ៏ពិសិដ្ឋនៃជីវិត។

**ប្រូតេស្តង់និយម**
អ. protestantism
បារ. protestantisme (m.)

លទ្ធិមួយក្នុងចំណោមលទ្ធិសំខាន់ៗទាំង៣នៃគ្រិស្តសាសនា រួមមាន រ៉ូម៉ាំងកាតូលិកនិយម (Catholicism) អ័រតូដុកនិយម (Orthodoxy) និង ប្រូតេស្តង់និយម (Protestantism)។

ប្រូតេស្តង់និយមបានចាប់ផ្តើមឡើងនៅសតវត្សរ៍ទី១៦ ជាចលនាមួយដើម្បីកែទម្រង់សហគមន៍គ្រិស្តសាសនានៅបស្ចិមប្រទេស ដោយបង្កើតសហគមន៍ប្រូតេស្តង់ចេញពីរ៉ូម៉ាំងកាតូលិក។ គោលបំណងរបស់ពួកប្រូតេស្តង់និយម គឺស្រោចស្រង់ជំនឿគ្រិស្តសាសនាឱ្យល្អដូចដើមឡើងវិញ។ ទន្ទឹមនឹងនេះ

ពួកគេក៏បានរក្សាទុកនូវអ្វីដែលពួកគេគិតថាមាន
តម្លៃ ហើយដែលបានអភិវឌ្ឍដោយពួករ៉ូម៉ាំងកាតូ-
លិក នៅចន្លោះសតវត្សរ៍ទី៥ដល់ទី១៥។

# ព

**ពហុទេវនិយម**
អ. polytheism
បារ. polythéisme
(m.)

លទ្ធិឬជំនឿដែលយល់ថា មានអាទិទេពច្រើន ក្នុងនោះមានប្រុស មានស្រី ហើយអាទិទេពនីមួយៗត្រូវគេធ្វើបដិរូបកម្មដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់មនុស្សជាតិ ដូចដែលមានបង្ហាញនៅក្នុងព្រហ្មញ្ញសាសនាជាដើម។

**ពុត**
អ. hypocrisy
បារ. hypocrisie
(f.)

សភាពនៃការស្តែងចេញខាងក្រៅរបស់មនុស្សណាម្នាក់ ដែលមិនមែនជាសញ្ញានៃសភាពពិតខាងក្នុងរបស់ខ្លួន។ ការស្តែងចេញខាងក្រៅនោះអនុលោមទៅតាមការទាមទារខាងសីលធម៌ ចំណែកឯសភាពលាក់បាំងខាងក្នុងនោះប្រាសចាកសីលធម៌។ ពុតអាចត្រូវផ្តន្ទាទោសខាងសីលធម៌ ពីព្រោះវាជាប្រភេទនៃការបំភាន់ឬការក្លែងធ្វើអ្វីមួយដែលប្រាសចាកសីលធម៌សង្គម។ ដូច្នេះ ពុតជាប់ទាក់ទងនឹងកង្វះភាពគួរឱ្យទុកចិត្តបាន ភាពមិនស្មោះត្រង់ និង ភាពមិនពិត ហើយជាទូទៅ វាមានវិបាកដែលមិនគួរឱ្យចង់បាន។

(ពាក្យនេះ គេប្រើនៅក្នុងទស្សនវិជ្ជាសីលធម៌)

**ពុទ្ធិវិជ្ជា**
អ. epistemology
បារ. épistémologie (f.)

មែកធាងទស្សនវិជ្ជាដែលផ្ដោតការយកចិត្តទុកដាក់លើបញ្ហាទស្សនវិជ្ជាដែលទាក់ទងជាមួយទ្រឹស្ដីពុទ្ធិ។ ពុទ្ធិវិជ្ជាសិក្សាអំពីនិយមន័យនៃពុទ្ធិនិងបញ្ញត្តិពាក់ព័ន្ធ ប្រភពនិងលក្ខណៈវិនិច្ឆ័យរបស់ពុទ្ធិ ប្រភេទពុទ្ធិ និង កម្រិតនៃភាពត្រឹមត្រូវដែលអាចទទួលបាន ដែនកំណត់នៃពុទ្ធិ និងទំនាក់ទំនងជាក់លាក់រវាងអ្នកដឹងនិងកម្មវត្ថុដែលត្រូវដឹង។

**ពូជសាសន៍និយម/ពូជនិយម**
អ. racism
បារ. racisme (m.)

អំណះអំណាងមួយដែលថាមានឋានានុក្រមនៃសមត្ថភាពឬតម្លៃដែលកំណត់ដោយជីវសាស្ត្រ ក្នុងចំណោមពូជផ្សេងៗគ្នា និង អះអាងដោយខុសឆ្គងថា ពូជទាបគួរត្រូវបានគ្រប់គ្រងដោយពូជខ្ពស់។ ជាទូទៅ ពូជសាសន៍និយម/ពូជនិយមបង្ខំឬជំរុញដោយការភ័យខ្លាចនិងការស្អប់ខ្ពើម ហើយដែលនាំទៅដល់អំពើហិង្សាឬអំពើប្រល័យពូជសាសន៍ទ្រង់ទ្រាយធំៗ។

(ពាក្យនេះ គេប្រើនៅក្នុងទស្សនវិជ្ជានយោបាយ)

**ព្រលឹង**
អ. soul
បារ. âme (f.)

ផ្នែកអរូបធាតុដែលគេសន្មតថា មានវត្តមានតែនៅក្នុងភាវៈរស់ប៉ុណ្ណោះ។ ដោយសារតែហាក់ដូចជាគ្មានភាពខុសគ្នាខាងរូបធាតុ រវាងភាវៈរស់នៅ

ក្នុងខណៈនៃជីវិតដែលហៀបនឹងស្លាប់និងរាងកាយដែលទើបនឹងស្លាប់ថ្មីៗ ទើបទស្សនវិទូជាច្រើនតាំងពីសម័យប្លាតុង(Plato)បានអះអាងថា ព្រលឹងគឺជាសមាសភាគអរូបធាតុរបស់ភាវៈរស់។ ដោយហេតុថា មានតែវត្ថុរូបធាតុប៉ុណ្ណោះដែលមានទីបញ្ចប់ ទើបប្លាតុងចាត់ទុកថាភាពអរូបធាតុរបស់ព្រលឹងជាមូលដ្ឋាននៃអមតភាពរបស់ព្រលឹង។

ទាំងប្លាតុង ទាំងអារីស្តូត មិនបានគិតថាមានតែមនុស្សទេដែលមានព្រលឹង៖ អារីស្តូតអះអាងថាព្រលឹងក៏មានចំពោះសត្វនិងរុក្ខជាតិដែរ ពីព្រោះសត្វនិងរុក្ខជាតិសុទ្ធតែបង្ហាញមុខងារខ្លះជាភាវៈមានជីវិត។ ខុសពីប្លាតុង អារីស្តូតបដិសេធការចាកចេញនៃព្រលឹងពីអម្បូរមួយទៅអម្បូរមួយទៀត ឬពីរាងកាយមួយទៅរាងកាយមួយទៀត បន្ទាប់ពីការស្លាប់។ គាត់សង្ស័យចំពោះសមត្ថភាពចាកចេញពីរាងកាយរបស់ព្រលឹងថា តើព្រលឹងអាចចាកចេញដោយរលូន នៅមានជីវិត និង បំពេញមុខងារដោយគ្មានរាងកាយបានដែរឬទេ។ រ៉ឺណេដេកាត (René Déscartes) អះអាងថា មានតែមនុស្សទេដែលមានព្រលឹង និងអះអាងថាធម្មជាតិអរូបធាតុរបស់ព្រលឹងអាចបង្កើតសេរីភាពបាន

ទោះបីជារាងកាយរបស់មនុស្សស្ថិតនៅឬមិនស្ថិត
នៅក្រោមការកំណត់របស់ច្បាប់រូបធាតុក៏ដោយ។

**ព្រលឹងនិយម**
អ. animism
បារ. animisme (m.)

ជំនឿលើទេវមួយឬច្រើនក្នុងឋានៈជាស្មារតីដែលមានក្នុងភាវៈមានជីវិតឬគ្មានជីវិត ដូចជា សត្វ រុក្ខជាតិ និងថ្ម។ ក្នុងចំណោមមនុស្សទូទៅ ពេញទាំងពិភពលោកនាសម័យបុរាណ ជំនឿនេះចាត់ទុកទេវមួយឬច្រើនថា មនុស្សជាតិមិនអាចយល់ដឹងបានឡើយ ប៉ុន្តែទេវទាំងនេះបានរួមចំណែកដល់កិច្ចការរបស់មនុស្ស។

ឧ. ជនជាតិខ្មែរតែងតែបន់ស្រន់សុំសេចក្ដីសុខពីអារក្ស អ្នកតា តាមជំនឿបែបព្រលឹងនិយម។

**ព្រះរាជបុត្រា / ទេវបុត្រា**
អ. god the son
បារ. dieu le fils

ឈ្មោះដែលគ្រិស្តសាសនិកផ្ដល់ឱ្យព្រះយេស៊ូគ្រិស្ដជាពិសេស សំដៅដល់តួអង្គមួយក្នុងចំណោមត្រី-អង្គ។ ព្រះរាជបុត្រា / ទេវបុត្រាឬព្រះយេស៊ូគ្រិស្ដ គឺជាតួអង្គសំខាន់ទីពីរក្នុងគ្រិស្តសាសនា ដែលប្រ-សូតនៅចន្លោះឆ្នាំទី៨និងឆ្នាំទី៤មុនគ្រិស្តសករាជ ហើយសោយទិវង្គតប្រហែលក្នុងឆ្នាំ២៩នៃគ្រិស្តសករាជ នៅក្រុងបេថ្លេអែម (Bethléem) ខេត្តជូដា (Judaea) ចក្រភពរ៉ូម៉ាំង។

(បញ្ញត្តិនេះ គេប្រើក្នុងបរិបទគ្រិស្តសាសនា)

**ព្រះវរបិតា**
អ. god the father
បារ. dieu le père

ព្រះនាមដែលគ្រិស្តសាសនិកថ្វាយដល់អាទិទេព នៅក្នុងគ្រិស្តសាសនា។ ព្រះវរបិតាត្រូវគេចាត់ទុកថាជាតួអង្គសំខាន់ទីមួយនៅក្នុងត្រីអង្គ ជាព្រះបិតារបស់ព្រះយេស៊ូគ្រិស្តនិងជាអ្នកបង្កើតចក្រវាល។

(បញ្ញត្តិនេះ គេប្រើក្នុងបរិបទគ្រិស្តសាសនា)

**ព្រះវិញ្ញាណបរិសុទ្ធ**
អ. god the holy spirit
បារ. dieu le saint-esprit

ព្រះនាមដែលគ្រិស្តសាសនិកថ្វាយដល់អាទិទេព នៅក្នុងគ្រិស្តសាសនា។ ព្រះវិញ្ញាណបរិសុទ្ធគឺជាតួអង្គសំខាន់ទីបីនៅក្នុងត្រីអង្គ និងជាកម្លាំងខាងស្មារតីរបស់អាទិទេព។

(បញ្ញត្តិនេះ គេប្រើក្នុងបរិបទគ្រិស្តសាសនា)

**ភាពចាំបាច់ដាច់ខាត**
អ. absolute necessity
បារ. nécessité absolue

ភាពចាំបាច់ដែលមាននៅក្នុងខ្លួនរបស់វា ហើយភាពចាំបាច់ដាច់ខាតនេះ ត្រូវបានហៅផងដែរថា ភាពចាំបាច់ខាងគណិតវិទ្យា ភាពចាំបាច់ខាងអស្តិរូបវិជ្ជា ឬ ភាពចាំបាច់ខាងតក្កវិជ្ជា។ ភាពចាំបាច់ដាច់ខាតនេះ ផ្ទុយពីភាពចាំបាច់សន្មត។ ភាពចាំបាច់ដាច់ខាតនេះគឺជាករណីសាកលនិងគ្មានលក្ខខណ្ឌ។ សច្ចភាពនៃភាពចាំបាច់ប្រភេទនេះគឺជាសច្ចភាពនៃវិចារណញ្ញាណ។

(ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា អស្តិរូបវិជ្ជា និងទស្សនវិជ្ជាអំពីគណិតវិទ្យា)

**ភាពចាំបាច់សន្មត**
អ. hypothetical necessity
បារ. nécessité hypothétique

ភាពចាំបាច់ដែលគេផ្តល់ឱ្យ ដូចដែលមានអត្ថិភាពក្នុងសង្គម ហើយភាពចាំបាច់សន្មតនេះត្រូវបានហៅផងដែរថា ភាពចាំបាច់ខាងសីលធម៌ ភាពចាំបាច់ខាងវិបាក ឬ ភាពចាំបាច់ខាងរូបី។

យោងតាម ឡេបនីស(Leibniz) សភាពរបស់ពិភពលោកបច្ចុប្បន្នមិនមែនជាភាពចាំបាច់ដាច់ខាតទេ ប៉ុន្តែវាគ្រាន់តែជាភាពចាំបាច់សន្មតប៉ុណ្ណោះ។ ចំណែកឯទស្សនវិទូផ្សេងៗទៀត បានហៅភាព

ចាំបាច់សន្មតនេះថាជាភាពចាំបាច់មិនដាច់ខាត ពីព្រោះវាទាក់ទងទៅនឹងការសន្មតជាមូលដ្ឋានណាមួយ។

**ភាវៈមនុស្ស**
អ. human being
បារ. être humain

ចំពោះអារីស្តូត(Aristotle) «ភាវៈមនុស្ស» គឺជាសត្វប្រកបដោយវិចារណញ្ញាណ។ ចំពោះរ៉ឺណេដេកាត(René Déscartes) «ភាវៈមនុស្ស» មិនមែនជាសរីរាង្គតែមួយទេ ប៉ុន្តែវាជាបន្សំនៃធាតុខុសគ្នាពីរ គឺចិត្តនិងកាយ។ ទោះបីជាមានភាពខុសគ្នាក្នុងការកំណត់បញ្ញត្តិ «ភាវៈមនុស្ស» រវាងអារីស្តូត និង រ៉ឺណេដេកាត ក៏ដោយ ក៏អ្នកទាំងពីរបានចាត់ទុកថា វិចារណញ្ញាណគឺជាលក្ខណៈសំខាន់នៃភាវៈមនុស្ស។ ភាវៈមនុស្សត្រូវបានគេប្រើជាសទិសន័យជាមួយពាក្យ «មនុស្ស» ដែលគេយល់ថាជាភាវៈមួយដែលមានសិទ្ធិមិនអាចដកហូតបាន ពោលគឺសិទ្ធិរស់រានមានជីវិត និង សិទ្ធិមានសេរីភាព ព្រមទាំងជាភាវៈមួយខ្ពស់ជាងសត្វផ្សេងៗដែលមិនមែនជាមនុស្ស។

ទស្សនវិជ្ជាសីលធម៌សហសម័យ មានទំនោរចង់ផ្តាច់ «មនុស្ស» ចេញពី «ភាវៈមនុស្ស» ដោយជឿថា «មនុស្ស» គឺជាភាវៈដែលមានស្វ័យញាណ

ចំណែកឯ «ភាវៈមនុស្ស» គ្រាន់តែជាសមាជិកនៃពូជដើមរបស់មនុស្ស គឺ អូម៉ូសាព្យាង (Homosa-piens) ប៉ុណ្ណោះ។

(ពាក្យនេះ គេប្រើនៅក្នុងអស្តិរូបវិជ្ជា សីលវិជ្ជា និងទស្សនវិជ្ជាអំពីចិត្ត)

**ភ្នាក់ងារ**
អ. agent
បារ. agent (m.)

មនុស្សដែលប្រកបដោយវិចារណញ្ញាណ និងជាប្រធាននៃអំពើដែលអាចសម្រេចចិត្តធ្វើឬមិនធ្វើអំពើណាមួយ ហើយអាចពិចារណារកវិធីនិងអនុវត្តវិធីនោះដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរ។

(ពាក្យនេះ គេប្រើក្នុងទស្សនវិជ្ជាស្តីពីអំពើ និងសីលវិជ្ជា)

**មនសិការ**
អ. conscience
បារ. conscience
(f.)

ការភ្ញាក់រលឹករបស់មនុស្ស ដែលជួយឱ្យមនុស្សស្គាល់ត្រូវ ស្គាល់ខុស និងដឹងថា អ្វីគួរធ្វើ អ្វីមិនគួរធ្វើ។ មនសិការត្រូវបានគេជឿថា ជាប្រភពមួយក្នុងចំណោមប្រភពសំខាន់ៗនៃសីលធម៌។

ទស្សនវិទូផ្សេងៗបានយល់ខុសគ្នាអំពីមនសិការ ដោយចាត់ទុកមនសិការថាជាសមត្ថភាពខាងសីលញាណរបស់មនុស្ស សំឡេងរបស់អាទិទេព សតិផ្ទាល់ខ្លួន និង ជាសំឡេងរបស់វិចារណញ្ញាណ។

**មនុស្សជាតិ**
អ. humanity
បារ. humanité
(f.)

ភាពរួមនៃអម្បូរមនុស្សទាំងមូល។ គំនិតនេះចាប់ផ្ដើមដោយអ្នកអត់ធ្មត់និយមដែលតែងយល់ថា មនុស្សជាតិជាកម្មវត្ថុនៃការគោរពនៅក្នុងជីវិតប្រកបដោយសីលធម៌។ ដោយឡែកនៅក្នុងសតវត្សរ៍ទី២០ កាស្ស៊ីរ៉េ(Cassirer)បានស្នើថា មនុស្សជាតិគួរត្រូវបានគេយល់ក្នុងក្របខណ្ឌនៃសកម្មភាពដែលនាំទៅដល់ស្នាដៃខាងវប្បធម៌និងប្រវត្តិសាស្ត្រ។ ស៊ីសឺរ៉ូ(Cicero) និង សេណេកា(Seneca) បានបង្កើតពាក្យ *មនុស្សជាតិ* ដោយសម្គាល់ន័យថាជា *ឧត្តមគតិខាងសីលធម៌ សោភ័ណ ឬ វិថីនៃជីវិត* ជាគំនិតមួយដែលត្រូវបានគេធ្វើឱ្យរស់ឡើងវិញនៅក្នុងបុនសម័យឬសម័យកកើតឡើងវិញ។

(ពាក្យនេះ គេប្រើក្នុងសីលវិជ្ជា និង សោភណវិជ្ជា)

**មនោនិយម**
អ. idealism
បារ. idéalisme
(m.)

គំនិតមួយដែលផ្ទុយនឹងលទ្ធិរូបធាតុនិយម ហើយអះអាងថា តថភាពជាមូលដ្ឋានរួមឬទាក់ទងនឹងគំនិតឬទស្សនៈ ហើយថា រូបធាតុគឺគ្រាន់តែជាផលិតផលនៃកិច្ចការរបស់គំនិតប៉ុណ្ណោះ។ ពួកមនោនិយមយល់ថា គំនិតគឺពិត ហើយរូបធាតុគឺគ្រាន់តែជារូបរាងខាងក្រៅ។ មនោនិយមចែកចេញជាពីរ គឺ មនោនិយមបរានុម័តិ និង មនោនិយមអត្តនោម័តិ។

១. យោងតាមពួកមនោនិយម គេអាចយល់ដឹងពីពិភពលោកបានដោយច្បាប់គំនិតនិងការយល់ដឹងឬមនសិការ មិនមែនដោយវិធីវិទ្យាសាស្ត្ររូបវិទ្យាទេ។

**មនោនិយមសត្យានុម័តិ**
អ. objective idealism
បារ. idéalisme objectif

លទ្ធិមួយដែលយល់ថា ពិភពលោកមានអត្ថិភាពឯករាជ្យដាច់ពីពិភពគំនិត រីឯពិភពលោកនេះត្រូវបានគេស្គាល់តាមរយៈគំនិតយល់ដឹង ដែលកំណត់រចនាសម្ព័ន្ធនិងទម្រង់របស់វាដូចជាពុទ្ធិរបស់មនុស្សដែរ។ គំនិតរបស់មនុស្សគ្រាន់តែរកឃើញនិងបកស្រាយអំពីលំដាប់និងតម្លៃដំបូងគេរបស់ចក្រវាលតែប៉ុណ្ណោះ។ មនោនិយមសត្យានុម័តិផ្ដួចផ្ដើមដោយ ប្លាតុង ហើយ ទស្សនៈស្ដីពីមនោនិយមរបស់គាត់ត្រូវបានគេចាត់ទុកថាមានចំណាស់ជាង

គេនៅក្នុងវិស័យទស្សនវិជ្ជានៅអឺរ៉ុប។ ចំពោះប្លាតុង វត្ថុដែលពិតនិងមានអត្ថន័យសំខាន់នៅក្នុងលោក នេះ គឺគំនិត។ ចំពោះពាក្យ «គំនិត» គាត់មិនបាន និយាយអំពីគំនិតណាមួយដែលមានអត្ថិភាពចំណុះ គំនិតរបស់មនុស្សឬអាទិទេពឡើយ។

២. មនោនិយមសត្យានុម័តិរបស់ប្លាតុង យល់ថា គំនិតកើតមុនអត្ថិភាព ពោលគឺ គំនិតស្ដីពីមនុស្ស សត្វ រុក្ខជាតិ រថយន្ត និង វត្ថុអរូបីផ្សេងៗ ដូចជា ជំនឿ យុត្តិធម៌ គុណធម៌ កុសល... មាននៅក្នុង ពិភពគំនិត ទើបមានអត្ថិភាពនៅក្នុងធម្មជាតិនិង ពិភពជាក់ស្ដែង។

**មនោនិយម អត្តនោម័តិ**
អ. subjective idealism
បារ. idéalisme subjectif

លទ្ធិមួយដែលចាត់ទុកថា ជាតុជាមូលដ្ឋានរបស់ ពិភពលោក មិនមែនជារូបធាតុទេ ប៉ុន្តែគឺជាស្មារតី ឬគំនិត។ ក្នុងតថភាព អ្វីដែលបង្ហាញជាពិភពរូបឬ សម្ភារៈ គឺគ្រាន់តែជាការប្រមូលផ្ដុំទស្សនៈដែលមាន អត្ថិភាពផ្អែកលើគំនិតយល់ដឹង។ ដូច្នេះ បើយោង ទៅតាមមនោនិយមអត្តនោម័តិ គឺគ្មានអ្វីមួយមាន អត្ថិភាពក្រៅពីគំនិតនិងទស្សនៈរបស់មនុស្សឡើយ។ មនោនិយមអត្តនោម័តិត្រូវបានគេកត់សម្គាល់នៅ អឺរ៉ុបក្នុងសតវត្សរ៍ទី១៨ តាមរយៈស្នាដៃរបស់លោក George Berkeley។ លោកបានអះអាងថា គំនិត

ស្តីពីតថភាពដែលឯករាជ្យពីចិត្ត មិនមានភាពច្បាស់លាស់ទេ។ អ្នកនិពន្ធក្រោយៗមកទៀតបានបន្តពន្យល់អំពីទទ្ធីករណ៍សង្ស័យនិយមរបស់ Berkeley។ អ៊ីម៉ានុយអែល កាន្ត (Immanuel Kant) បានឆ្លើយតបតាមរយៈការបដិសេធអរូបធាតុនិយមរបស់ Berkeley និងដោយការជំនួសមកវិញនូវមនោនិយមអតិសេដ្ឋដែលយល់ថា ពិភពដែលឯករាជ្យពីចិត្តកំពុងមានអត្ថិភាពមិនអាចយល់ដឹងបានដោយខ្លួនឯង។

 ២. តម្លៃរបស់មនុស្ស តម្លៃនៃប្រពៃណី តម្លៃទំនៀមទម្លាប់និងតម្លៃសីលធម៌សង្គម កំណត់ដោយគំនិតអត្តនោម័តិរបស់មនុស្ស។

**ម៉ាក្សនិយម**
អ. marxism
បារ. marxisme
(m.)

 លទ្ធិទស្សនវិជ្ជា សេដ្ឋកិច្ច នយោបាយ និងសង្គមដែលបង្កើតដោយ កាល់ម៉ាក្ស (Karl Marx) និងហ្វ្រេដេរិច អង់ហ្គែល (Frédéric Engels) ដែលក្នុងនោះមានសម្ភារនិយមបដិសំយោគ (dialectical materialism) សម្ភារនិយមប្រវត្តិសាស្ត្រ (historical materialism) និង សេដ្ឋកិច្ចនយោបាយ (political economics)។

 ២. លទ្ធិម៉ាក្សនិយមយល់ថា រូបធាតុ ជានិច្ចកាលជាដើមហេតុនៃការអភិវឌ្ឍប្រវត្តិសាស្ត្រ។

# ៥៩

**យុត្តសង្គ្រាម**

អ. just war

បារ. juste la guerre

ទ្រឹស្តីយុត្តសង្គ្រាមដំបូងបង្អស់ជាប់ពាក់ព័ន្ធទៅនឹងគំនិតរបស់និកាយកាតូលិកដែលអះអាងថា ការប្រើកម្លាំងគឺជាអំពើត្រឹមត្រូវតាមច្បាប់សម្រាប់ដាក់ទោសអ្នកប្រព្រឹត្តអាក្រក់ប្រឆាំងនឹងសាសនារបស់ខ្លួន។ បច្ចុប្បន្ន វាជាប្រធានបទសំខាន់មួយនៅក្នុងទស្សនវិជ្ជានយោបាយដែលចាត់ទុកការប្រើប្រាស់កម្លាំងសម្រាប់គោលបំណងខាងនយោបាយថាជារឿងត្រឹមត្រូវខាងសីលធម៌។ ជាធម្មតា ទ្រឹស្តីយុត្ត-សង្គ្រាមពាក់ព័ន្ធនឹងលក្ខខណ្ឌពីរពោលគឺ បុព្វហេតុត្រឹមត្រូវចំពោះសង្គ្រាម និង មធ្យោបាយត្រឹមត្រូវរបស់សង្គ្រាម។ បុព្វហេតុត្រឹមត្រូវសំដៅយកការធ្វើសង្គ្រាមដើម្បីការពារព្រំដែន ឆ្លើយតបទៅនឹងការឈ្លានពាននិងស្វែងរកសន្តិភាព។ មធ្យោបាយត្រឹមត្រូវគឺសំដៅយកការប្រើប្រាស់អាវុធធម្មតាសម្រាប់ធ្វើសង្គ្រាមដោយជៀសវាងការប្រើប្រាស់អាវុធមហាប្រល័យ ដូចជា អាវុធបរមាណូ អាវុធជីវសាស្ត្រ និង អាវុធគីមី ជាដើម។ យុត្តសង្គ្រាមត្រូវតែផ្តួចផ្តើមដឹកនាំនិងប្រកាសជាផ្លូវការដោយអាជ្ញាធរធម្មានុរូប ត្រូវតែប្រយុទ្ធដើម្បីបុព្វហេតុយុត្តិធម៌ប្រកបដោយគោលបំណងត្រឹមត្រូវ និងត្រូវ

តែការពារនិងជៀសវាងការសម្លាប់បុគ្គលិកយោធាដែលមិនប្រយុទ្ធ (គ្រូពេទ្យ បព្វជិត...) ជាពិសេសប្រជាជនដែលគ្មានកំហុស។

(ពាក្យនេះ គេប្រើនៅក្នុងសីលវិជ្ជា និង ទស្សនវិជ្ជានយោបាយ)

# រ

**រាជានិយម**
អ. royalism
បារ. royalisme (m.)

ទស្សនៈដែលគាំទ្រគោលការណ៍ដឹកនាំដោយក្សត្រ ឬសន្តតិវង្សណាមួយ និង ជំនឿចំពោះអំណាចធម្មានុរូបរបស់រដ្ឋបាលរាជាធិបតេយ្យឬក្សត្រ។

**រូបតំណាង**
អ. realistic statue
បារ. statue réaliste

រូបភាពដែលប្រត្យក្សារម្មណ៍ផ្តល់ឱ្យអង្គចងចាំ (លំនឹក) នៅពេលដែលមនុស្សបានជួបប្រាស្រ័យផ្ទាល់ជាមួយអង្គវត្ថុជាច្រើនលើក ហើយបានផ្តិតស្លាកស្នាមរបស់វាចូលទៅក្នុងខួរក្បាលមនុស្ស ក្រោយមក អង្គចងចាំនោះបង្ហាញឡើងវិញនូវលក្ខណៈពិសេសមួយចំនួន ពេលដែលមនុស្សមិននៅផ្ទាល់ជាមួយអង្គវត្ថុដែលគេបានជួបកន្លងមក។

**រូបធាតុនិយម**
អ. materialism
បារ. matérialisme (m.)

ទ្រឹស្តីដែលថា រូបធាតុ(physical matter) គឺជាតថភាពដំបូង ពោលគឺ រូបធាតុនិងដំណើរបាតុភូតទាំងអស់អាចឱ្យគេពន្យល់បានថាជាការបង្ហាញឱ្យឃើញឬជាលទ្ធផលនៃរូបធាតុ។ លទ្ធិរូបធាតុនិយមត្រូវបានគេបែងចែកជាក្រុមសំខាន់ៗពីរគឺ លទ្ធិរូប-ធាតុនិយមមេកានិក និង លទ្ធិរូបធាតុនិយមបដិសំ-យោគ។

២. ទ្រឹស្តីពុទ្ធសាសនាដែលថា ទឹក ដី ភ្លើង ខ្យល់

គឺជាធាតុបង្កើតពិភពលោកស្របនឹងទ្រឹស្តីរូបធាតុ-និយម។

**រូបធាតុនិយមចលនការ**
អ. mechanistic materialism
បារ. matérialisme mécaniste

លទ្ធិរូបធាតុនិយមដែលសង្កត់ធ្ងន់ទៅលើវិទ្យា-សាស្ត្រធម្មជាតិ។ ទស្សនៈពួករូបធាតុនិយមចលន-ការយល់ថា អ្វីមួយដែលកើតឡើងក្នុងពិភពលោកនេះអាចឱ្យគេពន្យល់បានតាមរយៈច្បាប់កំណត់និយមរបស់ធម្មជាតិ។ ពួកគេបដិសេធអត្ថិភាពនៃសារធាតុស្មារតី ហើយអះអាងថា គំនិតគ្រាន់តែជារូបធាតុ ជាផលិតផលនៃការចាត់ចែង និងជាដំណើរការនៃសារធាតុរូប (physical substance)។ អត្ថន័យដ៏សំខាន់មួយនៃលទ្ធិរូបធាតុនិយមចលនការគឺថា អ្វីៗនៅក្នុងពិភពលោកនេះកំណត់ដោយច្បាប់ធម្មជាតិ ដោយមិនទុកឱ្យមនុស្សមានសេរីភាពជ្រើសរើសទេ។

២. យោងតាមរូបធាតុនិយមចលនការ បម្រែបម្រួលធម្មជាតិកំណត់ដោយច្បាប់ធម្មជាតិ។

**រូបធាតុនិយមបដិសំយោគ**
អ. dialectic materialism

ការធ្វើសនិទានកម្មលើការប្រែប្រួលឬការផ្លាស់ប្តូរតថភាព ដូចជា ការប្រែប្រួលឬការផ្លាស់ប្តូរតថភាពសង្គមពីកម្រិតមួយទៅកម្រិតមួយទៀត ឆ្លងតាមគំរូវិវត្តន៍ដោយកម្លាំងប្រឆាំងកំណត់ដោយបែបផែន

បារ. matérialisme dialectique ផលិតកម្មដែលមានមូលដ្ឋានសេដ្ឋកិច្ចនិងសម្ភារៈជាកត្តាសំខាន់។

២. យោងតាមរូបធាតុនិយមបដិសំយោគ ការអភិវឌ្ឍសេដ្ឋកិច្ច វិទ្យាសាស្ត្រ បច្ចេកវិទ្យា នាំឱ្យមានការផ្លាស់ប្តូរផ្នត់គំនិតនិងឥរិយាបថសង្គម។

# ល

**លូថែនិយម**

អ. lutheranism

បារ. luthéranisme (m.)

ទម្រង់ដំបូងនៃលទ្ធិប្រូតេស្តង់ដែលបង្កើតឡើងដោយ ម៉ាទីនលូថែ (Martin Luther, ១៤៨៣-១៥៤៦) ជនជាតិអាល្លឺម៉ង់ នាសតវត្សរ៍ទី១៦ នៅប្រទេសអាល្លឺម៉ង់។

លទ្ធិនេះផ្តោតទៅលើការបង្រៀនរបស់ព្រះយេស៊ូគ្រិស្ត និង សង្កត់ធ្ងន់ទៅលើជំនឿនិងសេចក្តីស្មោះត្រង់របស់បុគ្គលទៅលើអំណាចរួមរបស់សហគមន៍គ្រិស្តសាសនា។ លូថែនិយមបានសាយភាយដំបូងឆ្លងកាត់អឺរ៉ុបខាងជើង ជាពិសេស ឆ្លងកាត់តំបន់ស្កង់ឌីណាវី (Scandinavia)។ បច្ចុប្បន្ន លទ្ធិនេះត្រូវបានគេប្រតិបត្តិពាសពេញពិភពលោក។

# វ

**វចីសុចរិត**

ការប្រព្រឹត្តត្រឹមត្រូវដោយវាចាមាន៤ប្រការគឺៈ

១- ការតាំងចិត្តវៀរចាកការនិយាយកុហក

២- ការតាំងចិត្តវៀរចាកការនិយាយស៊កសៀត និយាយឱ្យអ្នកដទៃបែកបាក់គ្នា

៣- តាំងចិត្តវៀរចាកការនិយាយពាក្យគ្រោតគ្រាត

៤- ការតាំងចិត្តវៀរចាកការនិយាយពាក្យរោយរាយ ឥតប្រយោជន៍។

**វប្បធម៌ស្ថាប័ន**

អ. organizational culture

បារ. culture organisationnelle

ឥរិយាបថរួមរបស់មន្ត្រីនិងបុគ្គលិកដែលជាផ្នែកមួយរបស់ស្ថាប័ន និងជាតម្លៃដែលចងភ្ជាប់មនុស្សទៅនឹងការងារឬអំពើរបស់ពួកគេ។ វប្បធម៌នេះរួមមាន តម្លៃទស្សនវិស័យ និយាមភាសា ការងារប្រព័ន្ធសញ្ញា ជំនឿ និង ទម្លាប់របស់ស្ថាប័ន។

វប្បធម៌ស្ថាប័នជះឥទ្ធិពលលើរបៀបដែលមនុស្ស និងក្រុមនីមួយៗធ្វើអន្តរកម្មជាមួយគ្នា លើអតិថិជន និង លើអ្នកពាក់ព័ន្ធផ្សេងទៀត។

ឧទាហរណ៍ : សមាជិកថ្មីនៃស្ថាប័ននីមួយៗតែងតែត្រូវបានគេបង្រៀនអំពីវប្បធម៌ស្ថាប័ន ជាពិសេសបង្រៀនអំពីគំរូនៃឥរិយាបថនិងការកំណត់រួមដែលទាក់ទងទៅនឹងវិធីនៃការយល់ឃើញ ការគិត និងការមានអារម្មណ៍អំពីការងារ។

**វាសនានិយម**
អ. fatalism
បារ. fatalisme
(m.)

លទ្ធិមួយនៃទស្សនវិជ្ជាដែលយល់ថា ព្រឹត្តិការណ៍ទាំងអស់កើតឡើងដោយមានការរៀបចំទុកជាមុន ឬចំណុះក្រោមវាសនា។ ព្រឹត្តិការណ៍នោះមានលក្ខណៈចាំបាច់ស្របតាមអ្វីដែលគេបាននិយាយ និងសរសេរនៅក្នុងគម្ពីរសាសនា។

**វិជ្ជមាននិយម**
អ. positivism
បារ. positivisme
(m.)

ប្រព័ន្ធគំនិតទស្សនវិជ្ជាដែលបង្កើតឡើងដោយទស្សនវិទូបារាំង អូហ្គុកុង (Auguste Comte) ប៉ុន្តែឫសគល់របស់វាចេញមកពី ហ្វ្រង់ស៊ីស បេខឹន (Francis Bacon)។

ស្មារតីរួមរបស់វិជ្ជមាននិយមគឺថាទស្សនវិជ្ជាគួរតែផ្តោតការយកចិត្តទុកដាក់តែទៅលើអ្វីដែលបទពិសោធផ្តល់ឱ្យជាក់ស្តែង និង គួរតែចៀសវាងពីការគិតបែបសន្មតដែលទៅហួសពីបទពិសោធ។ ដូច្នេះវិជ្ជមាននិយមចាត់ទុកការសិក្សាអំពីវិធីវិទ្យាសាស្ត្រថាជាកិច្ចការចម្បងរបស់ខ្លួន និងបង្ហាញខ្លួនឯងថាជាប្រភេទនៃទស្សនវិជ្ជាអំពីវិទ្យាសាស្ត្រ។

(ពាក្យនេះ គេប្រើនៅក្នុងទស្សនវិជ្ជាអំពីវិទ្យាសាស្ត្រ ពុទ្ធិវិទ្យា ទស្សនវិជ្ជាអំពីវិទ្យាសាស្ត្រសង្គម និង ទស្សនវិជ្ជាអំពីសាសនា)

**វិញ្ញាណ**
អ. sense
បារ. sens (m.)

សមត្ថភាពនៃការដឹងឬការស្គាល់ ការវាយតម្លៃឬប្រតិកម្មចំពោះអ្វីមួយ ជាពិសេស តាមរយៈអង្គ-វិញ្ញាណ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ។

ឧ. វិញ្ញាណរបស់ខ្ញុំដឹងថា ម្ហូបមួយចាននេះឆ្ងាញ់ ទឹកនេះក្តៅ ចម្រៀងនេះពីរោះ...។

**វិញ្ញូជន/វិញ្ញុជន**
អ. scholar
បារ. érudit,e (n.)

មនុស្សដែលមានពុទ្ធិទូលំទូលាយមានចំណេះដឹងច្រើនមុខវិជ្ជា មានសមត្ថភាពបរិបូរ ប៉ិនប្រសប់ និងមានសុភនិច្ឆ័យក្នុងកិច្ចការទាំងពួង។

**វិធីសូន្យ**
អ. zero method
បារ. méthode zero

វិធីមួយដែលបង្ហាញយ៉ាងច្បាស់អំពីទម្រង់មូលដ្ឋាននៃភាសា ដោយការបង្កើតពាក្យមួយតាមរយៈបន្សំនៃសញ្ញានានា។ ដោយសារតែទម្រង់តែមួយគត់របស់វា សញ្ញាទាំងនេះបានលុបចោលទាំងស្រុងនូវខ្លឹមសាររូបធាតុរបស់ខ្លួន។ វិធីសូន្យគឺជាវិធីតក្កវិជ្ជាស្តីពីការបង្កើតគំរូមួយផ្អែកលើការសន្មតទៅតាមសនិទានភាព។ ឧទាហរណ៍ : ក្នុងវិធីសូន្យគេបង្កើតពាក្យ «ត្រី»(បញ្ញត្តិត្រី) ពីទម្រង់ឬរូបរាងផ្សេងៗរបស់សត្វត្រីជាក់ស្តែង។

(ពាក្យនេះ គេប្រើក្នុងតក្កវិជ្ជា និង ទស្សនវិជ្ជាអំពីភាសា)

**វិបាក**
អ. consequence
បារ. conséquence (f.)

លទ្ធផលឬទំនាក់ទំនងហេតុនិងផលដែលកើតចេញពីស្ថានភាពណាមួយ ពីការសម្រេចចិត្ត ឬពីការប្រព្រឹត្តរបស់មនុស្សណាម្នាក់ឬក្រុមណាមួយ។

ឧ. តាមទស្សនវិទូបារាំង ហ្សាក់គីលីន រូស្សូ (Jacqueline Rousseau) វិបាកនៃការលុបចោលសំណួរ «ហេតុអ្វី» ធ្វើឱ្យស្មារតីមនុស្សគ្មានហេតុផល។

**វិភាគ**
អ. analysis
បារ. analyse (f.)

ដំណើរនៃការគិតដោយបំបែកបញ្ហាទាំងមូលទៅជាសមាសភាគរបស់វា និង ទំនាក់ទំនងរវាងសមាសភាគទាំងនោះ។

**វិរុទ្ធនិទស្សន៍**
អ. fallacy
បារ. sophisme (m.)

កំហុសនៅក្នុងការពិចារណាឬជាទឡ្ហីករណ៍មួយដែលមិនបានផ្ដល់ហេតុផលគ្រប់គ្រាន់ចំពោះសច្ចភាពនៃការសន្និដ្ឋានរបស់ខ្លួន ប៉ុន្តែវាបែរជាលេចចេញនូវការបញ្ចុះបញ្ចូលឱ្យជឿតាមរបៀបផ្សេងទៅវិញ។

**វិរុទ្ធនិទស្សន៍ករណីដោយឡែក**
អ. fallacy of secundumquid

ការយល់ខុសដោយការគិតមិនគ្រប់ជ្រុងជ្រោយអំពីគុណវុឌ្ឍិដែលប្រើគំនិតខុសឆ្គងថា អ្វីដែលពិតដោយមានគុណវុឌ្ឍិជាក់លាក់ណាមួយ វាក៏ពិតដោយគ្មានគុណវុឌ្ឍិជាក់លាក់នោះដែរ។ វិរុទ្ធនិទស្សន៍

បារ. erreur de secundumquid

ករណីដោយឡែកស្រដៀងគ្នាទៅនឹងវិរុទ្ធនិទស្សន៍ចៃដន្យដែលប្រើគោលការណ៍ឬវិធានទូទៅ ដោយមិនគិតពីទិដ្ឋភាពជាក់លាក់នៃកាលៈទេសៈក្នុងការប្រើប្រាស់របស់វា។ វិរុទ្ធនិទស្សន៍ករណីដោយឡែកមានទម្រង់បន្ថែមមួយទៀតដែលធ្វើទូទៅនីយកម្មវិធានមួយចេញពីតួយ៉ាងណាមួយដែលអាចមានលក្ខណៈដោយឡែកឬករណីលើកលែង។ នៅក្នុងទម្រង់នេះ វិរុទ្ធនិទស្សន៍ករណីដោយឡែក ធ្វើទូទៅនីយកម្មយ៉ាងប្រញាប់ប្រញាល់ ដោយផ្ដើមចេញពីករណីដោយឡែកទៅរកករណីទូទៅ។

ឧ១. សៅជាខ្មែរ គាត់រួសរាយចំពោះមនុស្សគ្រប់គ្នា ដូច្នេះខ្មែរទាំងអស់រួសរាយ។

ឧ២. វិចិត្រករ ញ៉ុក ឌឹម ជាជនជាតិខ្មែរ គាត់មានទេពកោសល្យគូររូបទេសភាពនិងសម្រស់នារីខ្មែរ ដូច្នេះវិចិត្រករខ្មែរទាំងអស់សុទ្ធតែមានទេពកោសល្យគូររូបទេសភាពនិងសម្រស់នារីខ្មែរ។

**វិរុទ្ធនិទស្សន៍បុព្វហេតុមិនពិត**
អ. fallacy of false cause

ហេតុផលនៃទឡ្ហីករណ៍ដែលអះអាងថាក្នុងចំណោមវត្ថុជាប់ទាក់ទងគ្នាពីរ កនិងខ ក ជាបុព្វហេតុរបស់ ខ ដោយសារតែ ក នៅមុន ខ។ ដូចគ្នានេះដែរ វិរុទ្ធនិទស្សន៍បុព្វហេតុមិនពិតគឺជាទឡ្ហីករណ៍មួយ

បារ. erreur de la fausse cause

ដែលផ្តល់ហេតុផលខុសឆ្គងដោយភ្ជាប់ព្រឹត្តិការណ៍ បាតុភូត ឬ សកម្មភាពពីរឬច្រើន ដែលកើតឡើងបន្តបន្ទាប់គ្នា ដោយអះអាងថា ព្រឹត្តិការណ៍ បាតុ-ភូតឬសកម្មភាពទី១ បណ្តាលឱ្យកើតព្រឹត្តិការណ៍ បាតុភូតឬសកម្មភាពបន្តបន្ទាប់។ ឧទាហរណ៍១ : ក្រោយមាន់រងាវ ព្រះអាទិត្យរះ ដូច្នេះមាន់រងាវបណ្តាលឱ្យព្រះអាទិត្យរះ។ ឧទាហរណ៍២ : ជានិច្ច-កាល ខ្ញុំផឹកតែក្រោយអាហារថ្ងៃត្រង់ ដូច្នេះអាហារថ្ងៃត្រង់ជាបុព្វហេតុនៃការផឹកតែរបស់ខ្ញុំ។

អំណះអំណាងទាំងនេះមិនត្រឹមត្រូវទេ ព្រោះមានការភាន់ច្រឡំរវាងលំដាប់និងដំណើរនៃបុព្វហេតុ។ វាផ្លាស់ពីលំដាប់នៃព្រឹត្តិការណ៍ដែលគ្រាន់តែទាក់-ទងនឹងពេលវេលាទៅលំដាប់ខាងបុព្វហេតុ។ បុព្វ-ហេតុមិនពិតមិនបណ្តាលឱ្យមានវិបាកទេ ហើយក៏មិនមែនជាបុព្វហាតុទាល់តែសោះ។

( ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា )

**វិរុទ្ធនិទស្សន៍ពន្ធុ**

អ. genetic fallacy

បារ. erreur génétique

ទទ្បីករណ៍ដែលវិនិច្ឆ័យ វាយតម្លៃឬពន្យល់អ្វីមួយផ្អែកតែទៅលើប្រភពកំណើតឬបរិបទដើមដែលវាកើតឡើងឬត្រូវបានបង្កើតឡើងដោយមិនផ្អែកលើការវិវត្តឬបច្ចុប្បន្នភាពរបស់វា។ ដោយសារវាអាច

មានភាពខុសគ្នាសំខាន់ៗមួយចំនួនរវាងប្រភព កំណើតនៃអ្វីមួយនិងសភាពបច្ចុប្បន្នរបស់វា ទើប ទឡ្ហីករណ៍បែបនេះតែងតែត្រូវបានចាត់ទុកថាជា វិរុទ្ធនិទស្សន៍ពន្ធុ ជាពិសេស នៅពេលគេប្រើទឡ្ហី-ករណ៍នោះដើម្បីបដិសេធគំនិតជំទាស់ណាមួយ។

មនុស្សដែលមានប្រភពកំណើតចេញពីសត្វស្វា មិនមានន័យថា ពួកគេនៅតែជាសត្វស្វានោះទេ។

(ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា)

**វិរុទ្ធនិទស្សន៍សមាសភាព**
អ. fallacy of composition
បារ. erreur de composition

ប្រភេទនៃការផ្ដល់ហេតុផលខុសដែលអះអាងថា បើផ្នែកនីមួយៗនៃអង្គទាំងមូលមានលក្ខណសម្បត្តិ ជាក់លាក់ណាមួយ នោះអង្គទាំងមូលក៏មាន លក្ខណសម្បត្តិដូចនោះដែរ។ ឧទាហរណ៍ : បើ គ្រឿងបង្គុំនីមួយៗរបស់រថយន្តមួយមានគុណភាព ល្អនោះ រថយន្តនោះក៏មានគុណភាពល្អដែរ។

បច្ចេកសព្ទនេះ ក៏ត្រូវបានគេប្រើដែរសម្រាប់ទឡ្ហី-ករណ៍មួយដោយផ្ដើមចេញពីមូលបដិញ្ញាដែលថា ធាតុនីមួយៗនៃបណ្ដុំមួយមានលក្ខណសម្បត្តិជាក់ លាក់ណាមួយឈានទៅដល់ការសន្និដ្ឋានថាបណ្ដុំ នោះក៏មានលក្ខណសម្បត្តិដូចនោះដែរ។

ទឡ្ហីករណ៍នេះគ្មានសុពលភាពទេ ព្រោះវាសន្មត

ដោយខុសឆ្គងថា អង្គទាំងមូលឬបណ្តុំជាការផ្គុំគ្នាយ៉ាងសាមញ្ញមួយនៃផ្នែកឬធាតុនីមួយៗ។ ដោយបញ្ច្រាសមកវិញ វិរុទ្ធនិទស្សន៍បំបែកដែលមានលក្ខណសម្បត្តិជាក់លាក់ណាមួយ ធាតុឬផ្នែកនីមួយៗក៏មានលក្ខណសម្បត្តិដូចនោះដែរ។ ឧទាហរណ៍ : សហរដ្ឋអាម៉េរិកជាប្រទេសអ្នកមាន ដូច្នេះ ពលរដ្ឋអាម៉េរិកម្នាក់ៗក៏ជាអ្នកមានដែរ។ វិរុទ្ធនិទស្សន៍នេះមិនដឹងថា មិនមានទំនាក់ទំនងផ្ទេររវាងអង្គទាំងមូលនិងផ្នែកផ្សេងៗរបស់វាទេ។ ទាំងវិរុទ្ធនិទស្សន៍សមាសភាព ទាំងវិរុទ្ធនិទស្សន៍បំបែក ជាគំរូរបស់វិរុទ្ធនិទស្សន៍នៃភាពមិនច្បាស់លាស់ ពីព្រោះជាញឹកញាប់វិរុទ្ធនិទស្សន៍ទាំងពីរនេះជាប់ពាក់ព័ន្ធនឹងការភាន់ច្រឡំរវាងការប្រើប្រាស់ដាច់ដោយឡែកៗនិងការប្រើប្រាស់បែបប្រមូលផ្តុំនៃពាក្យមួយ។

(ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា)

**វិរុទ្ធនិទស្សន៍សំណួរស្មុគស្មាញ**
អ. fallacy of many questions/fallacy

ប្រភេទនៃសំណួរប្រកបដោយល្បិចបែបវោហារ-សាស្ត្រដែលអ្នកឆ្លើយមិនអាចគេចផុតពីការទទួលយកបុរេសន្មតរបស់អ្នកសួរបានឡើយ។ លោកសុខសួរលោកសៅមួយសំណួរ ហើយទាមទារ

of complex questions
បារ. erreur de nombreuses questions

ចម្លើយសាមញ្ញថា «បាទ» ឬ «ទេ» ។ ប៉ុន្តែសំណួរនោះបង្កប់នូវបុរេសន្មតមិនសមហេតុផលណាមួយដែលតម្រូវឱ្យឆ្លើយដាច់ពីគ្នា។

ចម្លើយសាមញ្ញថា«បាទ» ឬ «ទេ» នឹងធ្វើឱ្យលោកសៅយល់ព្រមទទួលបុរេសន្មតដែលមិនសមហេតុផល។ ឧទាហរណ៍ : *តើអ្នកឈប់វាយឪពុករបស់អ្នកហើយឬនៅ?* មិនថាលោកសៅឆ្លើយ «បាទ» ឬ «ទេ» នោះទេ គឺចម្លើយរបស់គាត់បញ្ជាក់ថាគាត់យល់ព្រមទទួលស្គាល់ថា គាត់បានវាយឪពុករបស់គាត់ ប៉ុន្តែ តាមពិតវាអាចមិនដូច្នោះទេ។

( ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា )

**វិរុទ្ធនិទស្សន៍សំនៀង**
អ. fallacy of accent
បារ. erreur d' accent

ទឡ្ហីករណ៍មួយឈានទៅសន្និដ្ឋានដោយការផ្លាស់ប្តូរសំនៀងព្យាង្គនៃពាក្យមួយដែលធ្វើឱ្យខ្លឹមសាររបស់វាផ្លាស់ប្តូរ។ ជាការពិត ទឡ្ហីករណ៍មួយបែបនេះគ្មានសុពលភាពទេ។ ក្រោយមកវិរុទ្ធនិទស្សន៍សំនៀងត្រូវបានពង្រីកគ្របដណ្តប់លើករណីផ្សេងៗដែលក្នុងនោះ គេធ្វើទឡ្ហីកម្មដោយការសង្កត់សំឡេងលើផ្នែកផ្សេងៗនៃឃ្លាមួយដែលធ្វើឱ្យអត្ថន័យរបស់វាក៏ផ្លាស់ប្តូរផងដែរ។ វិរុទ្ធនិទស្សន៍សំនៀង ហៅម្យ៉ាងទៀតថា វិរុទ្ធនិទស្សន៍សង្កត់សូរ ហើយជានិច្ច-

កាល វាកើតឡើងនៅក្នុងភាសានិយាយ។

ឧទាហរណ៍៖

- *ខ្ញុំធ្វើស្រែ។* (មុខរបររបស់ខ្ញុំ ធ្វើស្រែ)
- *ខ្ញុំ ធ្វើស្រែ។* (កាលណាគេនិយាយសង្កត់សូរទៅលើពាក្យ *ខ្ញុំ* មានន័យថា *ខ្ញុំមិនសមធ្វើស្រែទេ* ឬអាចមានន័យថា *ខ្ញុំសប្បាយចិត្តនឹងធ្វើស្រែ*)។

(ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា)

**វិសេសានុមាន**
អ. abduction
បារ. enlèvement (m.)/abduction (f.)

វិធីបង្ហាញពីដំណើរនៃការប្រើប្រាស់ភស្តុតាងដើម្បីឈានទៅរកការសន្និដ្ឋានមួយដ៏ទូលំទូលាយ ដែលជាការពិចារណាមួយឆ្ពោះទៅរកការពន្យល់មួយសមហេតុផលបំផុត។

វិសេសានុមាន បង្ហាញដោយទស្សនវិទូជនជាតិអាម៉េរិក ឆាល សេនដឺ ផៀស (Charles Sanders Peirce, ១៨៣៩-១៩១៤) ដែលលោកបានចាត់ទុកថា វិសេសានុមានជារបៀបបែបច្នៃប្រឌិតក្នុងការទាញសេចក្តីសន្និដ្ឋាន ប៉ុន្តែ គាត់បញ្ជាក់ថា លទ្ធផលនៃការសន្និដ្ឋាននេះត្រូវស្ថិតនៅក្រោមការវាយតម្លៃប្រកបដោយវិចារណញ្ញាណ។

ឧទាហរណ៍៖

១- **អនុមានញែក** (Deduction)

- ក្បួន( rule ): សណ្ដែកទាំងអស់នៅក្នុងថង់នេះ ពណ៌ស
- ករណី( case ): សណ្ដែកទាំងនេះយកចេញពី ថង់នេះ
- លទ្ធផល( result ): សណ្ដែកទាំងនេះពណ៌ស។

២- **អនុមានរួម** ( Induction )

- ករណី( case ): សណ្ដែកទាំងនេះយកចេញពី ថង់នេះ
- លទ្ធផល( result ): សណ្ដែកទាំងនេះពណ៌ស
- ក្បួន( rule ): សណ្ដែកទាំងអស់នៅក្នុងថង់នេះ ពណ៌ស។

៣- **វិសេសានុមាន** ( Abduction )

- ក្បួន( rule ): សណ្ដែកទាំងអស់នៅក្នុងថង់នេះ ពណ៌ស
- លទ្ធផល( result ): សណ្ដែកទាំងនេះពណ៌ស
- ករណី( case ): សណ្ដែកទាំងនេះយកចេញ ពីថង់នេះ។

( បញ្ញត្តិនេះ គេប្រើនៅក្នុងតក្កវិជ្ជា )

# ស

| | |
|---|---|
| **សច្ចភាព**<br>អ. truth<br>បារ. vérité ( f. ) | ពាក្យនេះមានន័យមួយចំនួនដូចខាងក្រោមៈ<br>១- **អ្វីមួយពិត** អ្វីមួយដែលឆ្លើយតប ឬស្របទៅនឹងហេតុការណ៍ឬតថភាព។ ឧ. ប្រសិនបើអ្នកប្រាប់ការណ៍ពិត (សច្ចភាព) អ្នកគ្មានអ្វីគួរឱ្យខ្លាចទេ។<br>២- **គុណភាព លក្ខណៈឬសភាពពិត** សភាពឬលក្ខណៈដែលឆ្លើយតបឬស្របទៅនឹងហេតុការណ៍ឬតថភាព។<br>៣- **អំណះអំណាងពិត** ឬ **សេចក្តីប្រកាសពិត** អំណះអំណាងឬសេចក្តីប្រកាសដែលឆ្លើយតបឬស្របនឹងហេតុការណ៍ឬតថភាព។<br>៤- **ហេតុការណ៍ជាក់ស្តែង** អ្វីមួយពិតជាក់ស្តែងបំផុតដែលស្ទើរតែមិនចាំបាច់បញ្ជាក់។ ឧ. ទឹកតែងតែហូរពីទីខ្ពស់មកទីទាប។<br>៥- **អ្វីមួយដែលគេជឿជាទូទៅ** អំណះអំណាង ឬសេចក្តីថ្លែងដែលគេជឿជាទូទៅថាពិត។ ឧ. សច្ចភាពខាងសាសនា។ |
| **សង្ស័យនិយម / មជ្ឈធាតុនិយម**<br>អ. scepticism | លទ្ធិមួយដែលបដិសេធលទ្ធភាពរបស់មនុស្សក្នុងការទទួលពុទ្ធិអំពីតថភាពបរានុម័តិ។ ឆ្លងតាមរយៈការពង្រឹងបន្តិចម្តងៗនូវអត្ថន័យរបស់វា ពាក្យ |

| | |
|---|---|
| បារ. scepticisme (m.) | «សង្ស័យនិយម»បានក្លាយទៅជាការសង្ស័យអំពីអ្វីដែលជាទូទៅត្រូវបានគេទទួលស្គាល់ថា**ពិត**។ ចុងក្រោយ សង្ស័យនិយមបែបទស្សនវិជ្ជាទាំងអស់ជាប់ទាក់ទងជាមួយពុទ្ធិវិជ្ជា ពោលគឺវាផ្អែកទៅលើទស្សនៈស្ដីពីវិសាលភាព និងសុពលភាពនៃពុទ្ធិរបស់មនុស្ស។<br>២. យោងតាមសង្ស័យនិយម មនុស្សម្នាក់ៗត្រូវតែសង្ស័យលើលទ្ធភាពនៃការយល់ដឹងអំពីតថភាពធម្មជាតិនិងសង្គម។ |
| **សច្ចភាពចាំបាច់**<br>អ. necessary truth<br>បារ. vérité nécessaire | សច្ចភាពធម្មជាតិដែលមានសភាពពិតនៅក្នុងខ្លួនវា។ សច្ចភាពចាំបាច់ត្រូវតែពិត និងមិនអាចមិនពិតទេ។ សច្ចភាពបែបតក្កវិជ្ជានិងគណិតវិទ្យាជាទូទៅ ត្រូវបានគេចាត់ទុកថាជាគំរូនៃសច្ចភាពចាំបាច់។ ពួកវិចារណញ្ញាណនិយមបានអះអាងថា សច្ចភាពចាំបាច់ គឺជាសច្ចភាពនៃវិចារណញ្ញាណ និងផ្អែកលើការយល់ឆ្លុះជ្រៅទៅក្នុងទំនាក់ទំនងពិតរវាងហេតុការណ៍នានា។ ចំណែកឯពួកពិសោធន៍និយមវិញអះអាងថា ពុទ្ធិស្ដីពីពិភពលោកត្រូវតែផ្អែកលើការយល់ដឹងដោយវិញ្ញាណ។ ដូច្នេះ វាអាចគ្មានសច្ចភាពចាំបាច់ឬមានសច្ចភាពចាំបាច់ ប៉ុន្តែ |

វាគ្មានការបញ្ជាក់ផ្ទាល់ពីពិភពពិតទេ។

(ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា ពុទ្ធិវិទ្យា អស្តិរូបវិជ្ជា និង ទស្សនវិជ្ជាអំពីវិទ្យាសាស្រ្ត)

**សត្យានុម័ត**
អ. objective
បារ. objectif
(adj.)

ដែលផ្អែកលើហេតុការណ៍ពិតឬជាក់ស្តែងនានា និងមិនជះឥទ្ធិពលដោយជំនឿឬអារម្មណ៍របស់មនុស្សទេ ឬនិយាយម្យ៉ាងទៀតថា ដែលមានអត្ថិភាពដោយឯករាជ្យពីសតិឬការយល់ដឹងរបស់មនុស្ស។ ឧ. របាយការណ៍នេះមានលក្ខណៈមិនលម្អៀងនិងសត្យានុម័ត។

**សត្យានុមតិភាព / វត្ថុវិស័យភាព**
អ. objectivity
បារ. objectivité
(f.)

អត្ថិភាពពិតនៃអ្វីមួយដែលមិនផ្អែកលើចំណាប់អារម្មណ៍ឬគំនិតរបស់មនុស្ស។

ឧ១. រសជាតិជូរនៃផ្លែអំពិលគឺជាសត្យានុម័តិភាព។

ឧ២. សច្ចភាពនៅក្នុងហេតុការណ៍មួយគឺជាសត្យានុម័តិភាព។

**សន្និដ្ឋភាព**
អ. acquaintance
បារ. connaissance
(f.)

វិធីដែលប្រធានយល់ដឹងពីកម្មវត្ថុតាមរយៈបទពិសោធន៍ផ្ទាល់និងភ្លាមៗ។ សន្និដ្ឋភាពមានលក្ខណៈផ្ទុយពីការពិពណ៌នា ដែលក្នុងនោះកម្មវត្ថុនៃការពិពណ៌នាត្រូវបានគេស្គាល់តាមរយៈអន្តរការណ៍នៃការសន្និដ្ឋាន។ កម្មវត្ថុសន្និដ្ឋភាពកើត

ឡើងតាមរយៈទិន្នន័យខាងវិញ្ញាណ ការចងចាំ និងបញ្ញត្តិទូទៅ ដូចជា ភាពក្រហម ភាពមូល ជាដើម។ សញ្ញាណនៃសន្និដ្ឋភាពត្រូវបានគេប្រើ ដើម្បីកំណត់ព្រំដែនអ្វីដែលយើងអាចដឹងតាមរយៈ ការសង្កេតឃើញភ្លាមៗ។

(ពាក្យនេះ គេប្រើនៅក្នុងពុទ្ធិវិទ្យា)

**សព្ទវិវាទ** ការខ្វែងគំនិតគ្នាអំពីការប្រើប្រាស់ពាក្យ។

អ. logomachy

បារ. logomachie (f.)

**សភាវគតិ** គំរូឥរិយាបថរបស់មនុស្សនិងសត្វដែលមានតាំងពីកំណើត ហើយមិនអាចផ្លាស់ប្តូរបានតាមកាលៈ-ទេសៈ និងមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់គំនិតនិងវិចារណញ្ញាណឡើយ។

អ. instinct

បារ. instinct (m.)

**សមធម៌** លក្ខខណ្ឌតម្រូវជាមូលដ្ឋាននៃយុត្តិធម៌សង្គមដែលជាប់ពាក់ព័ន្ធនឹងភាពត្រឹមត្រូវឬចំណែកត្រឹមត្រូវ ហើយខុសពីសមភាពឬចំណែកស្មើគ្នា។ មិនដូច **សមភាពដាច់ខាត** ដែលមិនបានពិចារណាពីភាពខុសគ្នាក្នុងករណីនីមួយៗនោះទេ **សមធម៌**ទាមទារឱ្យករណីដូចគ្នាត្រូវបានគេប្រព្រឹត្តដោយស្មើភាពគ្នា

អ. equity

បារ. équité (f.)

និងករណីផ្សេងគ្នាត្រូវបានគេប្រព្រឹត្តដោយមិនស្មើភាពគ្នា។ ការបែងចែកធនធាននៅក្នុងសង្គមត្រូវកំណត់ដោយយោងទៅតាមគុណូបការៈ តម្រូវការ និង សមត្ថភាពរបស់អ្នកទទួល។ មានតែមនុស្សដែលស្ថិតក្នុងប្រភេទដូចគ្នានិងមានលក្ខខណ្ឌដូចគ្នាប៉ុណ្ណោះ ទើបត្រូវទទួលបានការប្រព្រឹត្តដូចគ្នា។ **សមធម៌**ទាមទារឱ្យមានការបញ្ជាក់ពីវិធានទូទៅដើម្បីឆ្លើយតបទៅនឹងស្ថានភាពពិសេស និងស្វែងរកការផ្តល់សេចក្តីសម្រេចចិត្តត្រឹមត្រូវក្នុងករណីដោយឡែកៗ។

(ពាក្យនេះ គេប្រើនៅក្នុងទស្សនវិជ្ជានយោបាយ)

**សម្មាកម្មន្តៈ**

អ. perfect conduct / right action

បារ. action juste

**ការងារត្រូវ** សំដៅដល់កាយសុចរិត៣យ៉ាង៖

១- ចេតនាវៀរចាកការសម្លាប់ជីវិតមនុស្ស សត្វ (បាណាតិបាតា វេរមណី),

២- ចេតនាវៀរចាកការកាន់យកវត្ថុដែលគេមិនបានឱ្យ (អទិន្នាទានា វេរមណី),

៣- ចេតនាវៀរចាកការប្រព្រឹត្តខុសក្នុងកាម (កាមេសុមិច្ឆាចារា វេរមណី)។

**សម្មាទិដ្ឋិ**

អ. right view / right understanding

បារ. vue juste / compréhension juste

**សេចក្តីយល់ឃើញត្រូវតាមសេចក្តីពិត** សំដៅដល់អរិយសច្ចៈទាំង៤ គឺ **ទុក្ខសច្ចៈ** សេចក្តីពិតអំពីទុក្ខ, **ទុក្ខសមុទយសច្ចៈ** សេចក្តីពិតអំពីហេតុនៃទុក្ខ, **ទុក្ខនិរោធសច្ចៈ** សេចក្តីពិតអំពីការរំលត់ទុក្ខ និង **ទុក្ខមគ្គសច្ចៈ** សេចក្តីពិតអំពីផ្លូវបដិបត្តិដើម្បីរំលត់ទុក្ខ។

**សម្មាវាចា**

អ. perfect speech / right speech

បារ. parole juste

**សម្តីត្រូវ** បានដល់ការវៀរចាកវចីទុច្ចរិត៤យ៉ាង ពោលគឺ៖

១- ពាក្យនិយាយកុហក

២- ពាក្យស៊កសៀត ញុះញង់ បំបែកបំបាក់

៣- ពាក្យអាក្រក់ គំរោះគំរើយ ជេរប្រទេច ត្មះតិះដៀល

៤- ពាក្យរោយរាយឥតប្រយោជន៍។

**សម្មាវាយាមៈ** / **សម្មាវាយាម**

អ. perfect effort / right effort

បារ. effort juste

**ការព្យាយាមត្រូវ** ដូចជាការព្យាយាមប្រព្រឹត្តអំពើល្អជាប្រយោជន៍សាធារណៈ ការព្យាយាមលះបង់ចិត្តលោភដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន ឬចិត្តជាប់ជំពាក់នឹងកាមតណ្ហា ការព្យាយាមទប់ទល់ប្រឆាំងនឹងអំពើអកុសលគ្រប់យ៉ាង ការព្យាយាមកសាងសន្សំកុសលធម៌ដែលមិនទាន់មាន និងការព្យាយាមថែរក្សាបុណ្យកុសលដែលមានហើយកុំឱ្យបាត់ទៅវិញ។ល។

**សម្មាសង្កប្បៈ**
អ. right thought / perfect resolution
បារ. pensée juste

**សេចក្តីត្រិះរិះត្រូវដើម្បីចេញចាកកាម** ពោលគឺ កម្ចាត់ការព្យាបាទ កម្ចាត់គំនិតឈ្នានីសនិងគំនិតអាក្រក់ផ្សេងទៀត ហើយរិះគិតសន្សំកសាងតែអំពើល្អនិងអហិង្សា។

**សម្មាសតិ**
អ. perfect mindfulness / right mindfulness
បារ. attention juste

**ការភ្ញាក់រឭកត្រូវឬការគ្រប់គ្រងចិត្តត្រូវ** ពោលគឺ សតិនឹករឭកយករូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារខន្ធ និងវិញ្ញាណក្ខន្ធ ជាអារម្មណ៍ ហើយពិចារណាឱ្យឃើញថា រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ជាអនិច្ចំ ទុក្ខំ អនត្តា ជាប់ជានិច្ច។

**សម្មាសមាធិ**
អ. perfect concentration/ right concentration
បារ. concentration juste

**ការតម្កល់ចិត្តក្នុងផ្លូវត្រូវ** បានដល់ការតាំងចិត្តស៊ប់មាំក្នុងកុសលធម៌ ការតម្កល់ចិត្តស៊ប់ក្នុងគន្លងអារម្មណ៍តែមួយដែលរំពឹងនិងសម្រេចដល់អង្គឈានត្រឹមត្រូវ។

**សម្មាអាជីវៈ**
អ. perfect livelihood / right livelihood
បារ. moyens d´existence juste

**ការចិញ្ចឹមជីវិតត្រូវ** ដែលវៀរចាកការចិញ្ចឹមជីវិតខុសប្រាំប្រការ៖
១- ការជួញដូរអាវុធ (សត្ថវណិជ្ជា),
២- ការជួញដូរមនុស្ស (សត្តវណិជ្ជា),

៣- ការជួញដូរសត្វយកទៅសម្លាប់ (មសំវណិជ្ជា),
៤- ការជួញ ដូរគ្រឿងស្រវឹង (មជ្ជវណិជ្ជា),
៥- ការជួញដូរថ្នាំពុល (វិសវណិជ្ជា)។
ក្រៅពីនេះ នៅមានការបិញ្ចឹមជីវិតទុច្ចរិតផ្សេងទៀត ដូចជា ការរកស៊ីលួចប្លន់ទ្រព្យសម្បត្តិឯកជន ឬទ្រព្យសម្បត្តិរដ្ឋ ការរត់ពន្ធ និង ការបិញ្ចឹមស្រី-ពេស្យាជាដើម។

**សម្រាំងនិយម**
អ. eclecticism
បារ. éclectisme (m.)

នៅក្នុងវិស័យទស្សនវិជ្ជាឬសាសនាសម្រាំងនិយម គឺជាគោលជំហរមួយដែលប្រមូលផ្តុំនិងសំយោគនូវទស្សនៈល្អៗពីសាសនានិងទស្សនវិជ្ជាដទៃទៀត។
ឧ. សាសនាកៅដាយបានប្រើប្រាស់គោលការណ៍សម្រាំងនិយម ជ្រើសយកជាតុល្អៗពីពុទ្ធសាសនា គ្រិស្តសាសនា លទ្ធិខុងជឺ និង សាសនាតៅ។

**សាកលរូបី**
អ. concrete universal
បារ. universel concret

បច្ចេកសព្ទមួយដែលបង្ហាញដោយហេហ្គែល (Hegel) ដើម្បីកែតម្រូវទស្សនៈបុរាណដែលថា សាកលគឺអរូបីដោយផ្អែកទៅលើធម្មជាតិទូទៅនៃប្រភេទភាវៈមួយតាមរយៈអរូបីកម្ម។ ហេហ្គែលជឿថា សាកលគឺជាទម្រង់រូបីជាជាងអរូបី។ "សាកលពិត" មិនមែនគ្រាន់តែជាបណ្តុំនៃលក្ខណៈ

ទូទៅចំពោះវត្ថុមួយចំនួននោះទេ ប៉ុន្តែ វាជាការរៀបរាប់លម្អិតអំពីខ្លួនវា ឬ ការបញ្ជាក់យ៉ាងច្បាស់អំពីខ្លួនវា។ សាកលមិនមែនដាច់ចេញពីភាពដោយឡែកនានាទេ ហើយវាក៏មិនមែនទៅហួសពីភាពដោយឡែកដែរ។ ផ្ទុយទៅវិញ សាកលមានមកជាប់ជាមួយនឹងភាពដោយឡែក ដែលជាកត្តាសំខាន់នៃភាពដោយឡែកទាំងនោះ។

( ពាក្យនេះ គេប្រើក្នុងបរិបទអស្តិរូបវិជ្ជា )

**សីលធម៌**
អ. moral
បារ. morale ( f. )

ការប្រព្រឹត្តផ្ទាល់របស់បុគ្គលដោយអនុលោមទៅតាមគោលការណ៍ឬច្បាប់នៃការប្រព្រឹត្តល្អដែលគេបានចេះដឹងនិងយល់ព្រមទទួល ដូចជា ជំនឿ អាកប្បកិរិយា ឬគំរូដោយឡែកៗ ដែលបានអនុវត្ត ឬប្រតិបត្តិនៅក្នុងការរស់នៅប្រចាំថ្ងៃរបស់គេ និងបង្ហាញឱ្យឃើញតាមរយៈការសម្រេចចិត្តនិងអំពើស្ម័គ្រចិត្តរបស់គេ។

**សីលវិជ្ជា**
អ. ethics
បារ. éthique ( f. )

ការសិក្សាពីអ្វីដែលត្រូវឬខុសនៅក្នុងទង្វើរបស់មនុស្សនិងជាការស្វែងរកជីវិតប្រកបដោយកុសល។ សីលវិជ្ជាសិក្សាជាសំខាន់ទៅលើគោលការណ៍សីលធម៌ ច្បាប់នៃការប្រព្រឹត្ត ឬ ប្រព័ន្ធផ្សេងៗ

ដែលគួរត្រូវបានគេប្រព្រឹត្តតាមយ៉ាងហ្មត់ចត់។

សីលវិជ្ជាកំណត់នូវអ្វីដែលជាការប្រព្រឹត្តល្អនិងអ្វីដែលជាការប្រព្រឹត្តមិនល្អ។ សីលវិជ្ជាបង្ហាញនូវអំពើរបស់មនុស្សដែលគួរឬមិនគួរយល់ព្រមតាម។ សីលវិជ្ជាផ្តល់ឱ្យយើងនូវគំរូមួយ។ ផ្អែកលើមូលដ្ឋាននេះ យើងអាចដឹងថា តើអាកប្បកិរិយារបស់យើងប្រកបដោយសីលធម៌ត្រឹមត្រូវ ប្រកបដោយគុណធម៌និងគួរឱ្យចង់បាន ឬ មិនគួរឱ្យចង់បាន។

ពាក្យ**សីលវិជ្ជា**មានន័យប្រហាក់ប្រហែលនឹងពាក្យទស្សនវិជ្ជាសីលធម៌ អភិសមាចារ ចរិយាសាស្ត្រ វិទ្យាសាស្ត្រសីលធម៌ និង គោលការណ៍សីលធម៌។

ឲ. សីលវិជ្ជាដើរតួនាទីសំខាន់ក្នុងការកំណត់ភាពត្រឹមត្រូវនិងកំហុសឆ្គងក្នុងនិយាមសង្គមនិងច្បាប់រដ្ឋ។

**សីលវិជ្ជាកាតព្វកិច្ច**
អ. deontological ethics
បារ. éthique déontologique

ដំហរសីលវិជ្ជានិយាមដែលវិនិច្ឆ័យសីលធម៌របស់អំពើមួយផ្អែកលើការអនុលោមតាមច្បាប់ឬវិធាននានាស្តីពីអំពើនោះ។

សីលវិជ្ជាកាតព្វកិច្ចគឺជាសីលធម៌ផ្អែកលើច្បាប់ ឬ វិធាននានាឬកាតព្វកិច្ចដែលសង្កត់ធ្ងន់ទៅលើអំពើត្រឹមត្រូវជាជាងវិបាកល្អ។ ពេលខ្លះ សីលវិជ្ជាកាតព្វ-

**កិច្ច**ត្រូវបានគេពិពណ៌នាថាជាសីលវិជ្ជាដែលផ្អែកលើ«កាតព្វកិច្ច»ឬ«ច្បាប់» ពីព្រោះច្បាប់ទាំងនោះចងភ្ជាប់អ្នកទៅនឹងកាតព្វកិច្ចរបស់អ្នក។

ជាទូទៅ សីលវិជ្ជាកាតព្វកិច្ច ផ្ទុយទៅនឹងវិបាកនិយមសីលវិជ្ជាគុណធម៌ និង សីលវិជ្ជាប្រតិបត្តិនិយម។ នៅក្នុងបច្ចេកសព្ទសីលវិជ្ជា កាតព្វកិច្ចនិងអំពើសំខាន់ជាងវិបាក។

**សីលវិជ្ជាជីវៈ**
អ. bioethics
បារ. bioéthique
(f.)

មែកធាងមួយនៃសីលវិជ្ជាអនុវត្តដែលទាក់ទងនឹងបញ្ហាសីលធម៌ស្ដីពីជីវិតនិងមរណភាព ដែលផ្ដើមចេញពីការស្រាវជ្រាវខាងជីវសាស្ត្រនិងវេជ្ជសាស្ត្រទំនើបនិងការប្រតិបត្តិក្នុងការថែទាំសុខភាព។

សីលវិជ្ជាជីវៈជាក្រមសីលធម៌នៃជីវិត តម្រូវឱ្យអ្នកស្រាវជ្រាវខាងជីវវិទ្យា វេជ្ជសាស្ត្រ ឱសថសាស្ត្របសុសាស្ត្រ គីមីសាស្ត្រ បរិស្ថានវិទ្យា និង បច្ចេកវិទ្យាផ្សេងៗប្រតិបត្តិតាម ហើយវាក៏ជានិយាមសីលធម៌មួយប្រើសម្រាប់វាស់អំពើរបស់អ្នកសិក្សាស្រាវជ្រាវក្នុងវិស័យខាងលើឱ្យដឹងថា តើពួកគេប្រតិបត្តិតាមគោលការណ៍សីលវិជ្ជាជីវៈបានកម្រិតណា។ បញ្ហាដែលពាក់ព័ន្ធនឹងសីលវិជ្ជាជីវៈ ដូចជាការផ្ដល់ធនធានវេជ្ជសាស្ត្រកម្រកម្រិតស្វ័យភាព

របស់អ្នកជំងឺ ព្រមទាំងវិសាលភាពនិងព្រំដែននៃអំណាចរបស់វេជ្ជបណ្ឌិតនិងគិលានុបដ្ឋាក ការរំលូតកូននិងសុឃាត ការធ្វើពិសោធន៍លើមនុស្ស ការស្រាវជ្រាវពន្ធុ(ហ្សែន) ការពន្យារកំណើត បច្ចេក-ទេសក្នុងការបង្កកំណើតមនុស្ស ការពិនិត្យគភ៌ ការពពោះជំនួស ការបរិច្ចាគជាលិកាឬសរីរាង្គជាដើម។

**សីលវិជ្ជានិយាម**
អ. normative ethics
បារ. éthique normative

សីលវិជ្ជាមួយប្រភេទដែលទាក់ទងនឹងការសម្រេចអំពីស្តង់ដាឬខ្នាតគំរូសីលធម៌ ដែលកំណត់ថាឥរិ-យាបថណាមួយត្រឹមត្រូវគួរនឹងធ្វើតាម និង ឥរិយាបថខុសឆ្គងដែលគួរជៀសវាង។

**សីលវិជ្ជាបរិស្ថាន / សីលបរិស្ថាន**
អ. environmental ethics
បា. éthique environnementale

ផ្នែកមួយនៃទស្សនវិជ្ជាបរិស្ថានដែលពិចារណាអំពីការពង្រីកព្រំដែនបែបប្រពៃណីរបស់សីលវិជ្ជាដែលសិក្សាទៅលើបញ្ហាមនុស្សទៅដល់បញ្ហាមិនមែនមនុស្ស។ សីលវិជ្ជាបរិស្ថានមានឥទ្ធិពលទូលំ-ទូលាយលើមុខវិជ្ជាផ្សេងទៀត ដូចជា ច្បាប់បរិស្ថាន សង្គមវិជ្ជាបរិស្ថាន អេកូសាសនវិទ្យា អេកូសេដ្ឋកិច្ច អេកូឡូហ្ស៊ី និង ភូមិវិទ្យាបរិស្ថាន។

**សីលវិជ្ជាអនុវត្តន៍**
អ. applied ethics

សីលវិជ្ជាមួយប្រភេទដែលទាក់ទងនឹងការវិភាគជាក់លាក់អំពីបញ្ហាវាទប្បដិវាទ(បញ្ហាចម្រូងចម្រាស)

| | |
|---|---|
| បារ. éthique appliquée | ខាងសីលធម៌ ដូចជា ការរំលូតកូន ការសម្លាប់ទារក សិទ្ធិសត្វ កង្វល់ខាងបរិស្ថាន ការសម្លាប់មនុស្សដែលមានជំងឺធ្ងន់មើលមិនជា សីលធម៌សុខាភិបាល សីលធម៌ជំនួញ ការស្រឡាញ់ភេទដូចគ្នា សីលធម៌រួមភេទ ការកាត់ទោសប្រហារជីវិត និង សង្គ្រាមបរមាណូជាដើម។ |
| **សីលវិជ្ជាអស្តិរូប**<br>អ. metaethics<br>បារ. méta-éthique | សីលវិជ្ជាមួយប្រភេទដែលសិក្សាអំពីប្រភព និង អត្ថន័យនៃបញ្ញត្តិទស្សនវិជ្ជាសីលធម៌។ |
| **ស៊ីរ៉េណៃ**<br>អ. cyrenaics<br>បារ. cyrène | និកាយទស្សនវិជ្ជាតម្រេកនិយមដែលបង្កើតឡើងដោយអារីស្ទិបកុសនៃស៊ីរ៉េន (Aristippus of cyrene) ហើយបានរីកចម្រើននៅចុងសតវត្សរ៍ទី៤ មុនគ្រិស្តសករាជ។ អារីស្ទិបកុស បានអះអាងនៅក្នុងលទ្ធិសំខាន់របស់គាត់ថា ពុទ្ធិមានលក្ខណៈមិនអាចទុកចិត្តបាននិងគ្មានប្រយោជន៍ ហើយមនុស្សគួរខិតខំព្យាយាមត្រួតត្រាកាលៈទេសៈរបស់ខ្លួនជាជាងទុកឱ្យកាលៈទេសៈត្រួតត្រាពួកគេ។ ការស្វែងរកសេចក្តីរីករាយភ្លាមៗគឺជាគោលបំណងសំខាន់នៃជីវិត។ សេចក្តីរីករាយខាងវិញ្ញាណគួរឱ្យចង់បានជាងសេចក្តីរីករាយខាងបញ្ញាដែលមាន |

លក្ខណៈល្អិតល្អន់និងស្មុគស្មាញ ទោះបីជាសេចក្ដីរីករាយមិនត្រូវបានស្វែងរកហួសពីព្រំដែនដែលបានកម្រិតដោយច្បាប់ ប្រពៃណីទំនៀមទម្លាប់ក៏ដោយ។

(ពាក្យនេះ គេប្រើនៅក្នុងទស្សនវិជ្ជាក្រិកបុរាណ)

**សុឃាត**
អ. euthanasia
បារ. euthanasie (f.)

ការប្រតិបត្តិនូវការបញ្ចប់ជីវិតអ្នកជំងឺដោយចេតនាដើម្បីបំបាត់ការឈឺចាប់ខាងផ្លូវកាយនិងផ្លូវចិត្ត។

**សុភមង្គល**
អ. happiness
បារ. bonheur (m.)

ស្ថានភាពនៃវេទនារម្មណ៍ឬគំនិតស្ដីពីសុខុមាលភាពដែលកំណត់លក្ខណៈដោយវេទនារម្មណ៍រីករាយឬរីជ្ឈមានដែលរាប់ចាប់ពីភាពស្កប់ស្កល់ទៅដល់ភាពសប្បាយរីករាយខ្ពស់បំផុត។

ទ្រឹស្ដីទស្សនវិជ្ជាសីលធម៌ទាំងអស់ផ្ដល់សារៈសំខាន់មួយចំនួនចំពោះសុភមង្គលរបស់មនុស្ស។ ទ្រឹស្ដីទាំងនោះខុសគ្នាត្រង់៖

- ទី១ ទស្សនាទានស្ដីពីអ្វីដែលសុភមង្គលនោះផ្អែកលើ,
- ទី២ ទស្សនៈស្ដីពីរបៀបនៃការទទួលសុភមង្គលបុគ្គលស្របឬប្រឆាំងទៅនឹងសុភមង្គលរួម,
- ទី៣ ថាតើវាចាំបាច់ឬទេ ក្នុងការទទួលយកនូវ

គោលបំណងផ្សេងទៀតសម្រាប់សកម្មភាពរបស់មនុស្ស។

ទ្រឹស្ដីសាមញ្ញបំផុតគឺថា សុភមង្គលខ្លួនវាមានលក្ខណៈងាយៗ, ៤. វាកើតមាននៅក្នុងឱកាសសប្បាយរីករាយ។

ទ្រឹស្ដីនេះក៏និយាយដែរថា ភ្នាក់ងារគ្រាន់តែស្វែងរកឬគួរតែស្វែងរកសុភមង្គលផ្ទាល់ខ្លួនរបស់ពួកគេ ហើយវាក៏និយាយដែរថា ពុំមានគោលបំណងផ្សេងនៃអំពើដែលអាចទៅរួចឬដែលគួរឱ្យចង់បាននោះទេ, ៤. សុភមង្គលរបស់គ្រួសារមួយអាស្រ័យលើភាពចុះសម្រុងគ្នានៃសមាជិកគ្រួសារ។

**សូហ្វីស**

អ. sophist

បារ. sophiste (m.)

កាលពីដំបូង ពាក្យ *សូហ្វីស* សំដៅយកមនុស្សដែលប្រកបដោយគតិបណ្ឌិត ដូចជា កវីនិពន្ធ អ្នកព្យាករ ព្រឹទ្ធាចារ្យ ដែលប្រកបដោយភាពឈ្លាសវៃ។ ប៉ុន្តែ នៅក្នុងសតវត្សរ៍ទី៥មុនគ្រិស្តសករាជ ពាក្យ *សូហ្វីស* សំដៅយកបច្ចេកសព្ទពិសេសមួយដែលមានន័យថា គ្រូបង្រៀនជំនាញដែលបានដើរផ្សងព្រេងពីទីក្រុងមួយទៅទីក្រុងមួយដើម្បីបង្រៀនមុខវិជ្ជាជាច្រើនដែលមិនធ្លាប់មានពីមុនមក ដូចជា វោហារសាស្ត្រ ភាសាវិទ្យាជាដើម ដែលយុវជនក្រិក

ត្រូវការជាចាំបាច់ ដើម្បីបញ្ចុះបញ្ចូលអ្នកនយោ-
បាយ។ សូហ្វីសបានយកថ្លៃបង្រៀនពីសិស្សដែល
មករៀនជាមួយពួកគេ។ នៅក្នុងពេលនោះ ពាក្យ
*សូហ្វីស* មិនមានន័យអវិជ្ជមានឬន័យអាក្រក់ទេ។
ពួកសូហ្វីសមិនមែនចេញមកពីនិកាយណាមួយ
ហើយភាគច្រើននៃពួកគេក៏មិនមែនជាទស្សនវិទូ
ដែរ។ ក្នុងចំណោមពួកសូហ្វីសដែលល្បីល្បាញ
បំផុតមាន ប្រូតាហ្គោរ៉ាស (Protagoras) ហ្គ័រហ្ស៊ី-
យ៉ាស (Gorgias) ត្រាស៊ីម៉ាជុស (Thrasymachus)
ប្រូឌីគុស (Prodicus) ហ៊ីប្យាស (Hippias)។

ក្រោយពីជំនាន់ពួកសូហ្វីសខាងលើមក ពាក្យ
*សូហ្វីស* នេះក៏មានអត្ថន័យអវិជ្ជមានរហូតមកដល់
បច្ចុប្បន្ន។ ការប្រែប្រួលដ៏ធំនេះមកពីការឃោសនា
ជំទាស់របស់ប្លាតុង និង អារីស្តូត ដែលចោទពួក
សូហ្វីសថាជាអ្នករកលុយពីការបង្រៀនរបស់ពួកគេ
និងយកតម្លៃខ្ពស់ក្នុងការបង្រៀនបច្ចេកទេសយក
ឈ្នះក្នុងការតស៊ូមតិ។ ពួកសូហ្វីសជាច្រើនជា
គោលដៅចំអកនៅក្នុងអត្ថបទសន្ទនារបស់ប្លាតុង
ហើយក្រោយមក ពួកសូហ្វីសត្រូវបានញែកចេញ
ពីអ្នកប្រកបមុខវិជ្ជាខាងបញ្ញាដោយពិតប្រាកដ។
ប៉ុន្តែផ្តើមពីការខ្វះខាតខាងព័ត៌មានសម្រាប់ដំណើរ-

ការ ពួកសូហ្វីសប្រៀបដូចជាអ្នករួមគ្នាបង្កើតចលនាសេរីដែលបង្កជាភាពសង្ស័យក្នុងប្រពៃណីនិងក្នុងចំណុចខ្លះនៃការបំភ្លឺ។ ពួកសូហ្វីសបានរួមវិភាគ-ទានដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្រនៃការគិតក្នុងជំនាញវេយ្យាករណ៍និងទ្រឹស្តីភាសាវិទ្យា សីលធម៌ ទ្រឹស្តីនយោបាយ ទ្រឹស្តីអំពីធម្មជាតិ និង ប្រភពរបស់មនុស្សនិងសង្គម។ ដោយគ្មានសំណេររបស់សូហ្វីសណាម្នាក់នៅសល់ ដូច្នេះវាជាការលំបាកក្នុងការកែតម្រូវបុរេនិច្ឆ័យពីមុនដែលប្រឆាំងនឹងពួកសូហ្វីស។

(ពាក្យនេះ គេប្រើនៅក្នុងទស្សនវិជ្ជាក្រិកសម័យបុរាណ)

**សួគ៌**
អ. heaven
បារ. Ciel (m.)

លោកឬភពនៃសន្តិនិងសុភមង្គលដ៏ឧត្តមដែលគេជឿថា បុគ្គលល្អនឹងបានទៅកើតនៅក្រោយពេលគេស្លាប់ទៅ។ អារីស្តូតឱ្យនិយមន័យពាក្យ «សួគ៌» បីយ៉ាងផ្សេងៗគ្នា៖

១- មណ្ឌលដែលស្ថិតនៅចុងបំផុតនៃចក្រវាល។

២- មេឃឬសួគ៌ តាមន័យទូទៅ។

៣- ចក្រវាលទាំងមូលដែលជាសទិសន័យនឹងលោក-ធាតុ។ នៅក្នុងប្រពៃណីគ្រិស្តសាសនា សួគ៌គឺជា

កន្លែងបម្រុងទុកសម្រាប់មនុស្សមានបាបដែលព្រះបានសង្គ្រោះ ក្រោយពេលស្លាប់។ តាមន័យនេះ សួគ៌ជាភពដែលអាទិទេពនិងអស់ទេវតាស្ថិតនៅ។

**សេរីនិយមក្លាស៊ិក/សេរីនិយមបែបបុរាណ**
អ. classic liberalism
បារ. libéralisme classique

មនោគមវិជ្ជានយោបាយម្យ៉ាង និងជាមែកជាងមួយនៃសេរីនិយមដែលគាំទ្រសេរីភាពពលរដ្ឋនៅក្រោមនីតិរដ្ឋ និងផ្តោតលើសេរីភាពខាងសេដ្ឋកិច្ច។ សេរីនិយមក្លាស៊ិកទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងសេរីនិយម និងសេរីនិយមខាងសេដ្ឋកិច្ច។ នៅដើមសតវត្សរ៍ទី១៩ សេរីនិយមក្លាស៊ិកត្រូវបានអភិវឌ្ឍដោយឈរលើគំនិតរបស់ទស្សនវិទូនៃសតវត្សរ៍មុនៗជាការឆ្លើយតបទៅនឹងនគរូបនីយកម្មនិងបដិវត្តន៍ឧស្សាហកម្មនៅអឺរ៉ុបនិងសហរដ្ឋអាមេរិក។ បុគ្គលល្បីល្បាញដែលគំនិតរបស់ពួកគាត់បានរួមចំណែកនៅក្នុងសេរីនិយមក្លាស៊ិក រួមមាន ចន ឡុក (John Locke) តូម៉ាស ជេហ្វឺសោន់ (Thomas Jefferson) ហ្សង់ បាបទីស្តសាយ (Jean Baptiste Say) តូម៉ាស ម៉ាល់ធឹស (Thomas Malthus) និង ដេវីដ រីកាដូ (David Ricardo)។

សេរីនិយមក្លាស៊ិកត្រូវបានដកស្រង់ចេញពីទ្រឹស្តីសេដ្ឋកិច្ច (Economics) របស់អាដាមស្មីត

(Adam Smith) ជំនឿលើច្បាប់ធម្មជាតិ (Natural law) ទ្រឹស្តីផលប្រយោជន៍និយម (Utilitarianism) និង ភាពរីកចម្រើន (progress)។

**សេរីភាព**
អ. freedom
បារ. liberté (f.)

លទ្ធភាពរបស់មនុស្សដែលធ្វើអ្វីមួយស្របទៅតាមបំណងនិងចំណង់ចំណូលចិត្តរបស់គេ។ វាជាសភាពមួយដែលមនុស្សមិនត្រូវបានគេកំណត់ព្រំដែនដោយលក្ខខណ្ឌឬការបង្ខិតបង្ខំណាមួយឡើយ។

ឧ. មនុស្សសប្បាយរីករាយនឹងសេរីភាព ពេលដែលគេមានអំណាចជ្រើសរើសដោយសេរីរវាងវិធីឬផ្លូវផ្សេងៗ។

**សេរីភាពវិជ្ជមាន**
អ. positive freedom
បារ. liberté positive

លទ្ធភាពដែលអាចធ្វើឱ្យនរណាម្នាក់ក្លាយជាម្ចាស់ក្នុងការកំណត់អំពីជីវិតនិងសកម្មភាពផ្ទាល់ខ្លួន។ សេរីភាពវិជ្ជមាននេះគឺជាសេរីភាពបែបសង្គមដែលមានព្រំដែនដាក់លាក់នៅក្នុងជំនឿទំនៀមទម្លាប់ប្រពៃណី សីលធម៌ ច្បាប់រដ្ឋ និងកំណត់ដោយសមត្ថភាព ធនធាន និងឱកាសរបស់មនុស្សម្នាក់ៗ។

(ពាក្យនេះ គេប្រើនៅក្នុងសីលវិជ្ជា និង ទស្សនវិជ្ជានយោបាយ)

**ស្កូឡាស្ទិកនិយម**
អ. scholasticism
បារ. scolastique (f.)

ប្រព័ន្ធសិក្សាបែបប្រពៃណីខាងទស្សនវិជ្ជា និងទេវវិជ្ជាមជ្ឈិមសម័យដែលផ្អែកលើអំណាចរបស់សាំង អូហ្គូស្តាំង (Saint Augustin) និងអ្នកដឹកនាំដទៃទៀតនៃសហគមន៍គ្រិស្តសាសនាដំបូងនិងផ្អែកលើស្នាដៃជាច្រើនរបស់អារីស្តូត។ វាមានបំណងភ្ជាប់គម្លាតរវាងសាសនានិងហេតុផល។

ឧ. ទស្សនវិទូស្កូឡាស្ទិកនិយមអះអាងថា ហេតុផលមិនមែនបំផ្លាញជំនឿឬសាសនាទេ ប៉ុន្តែវាធ្វើឱ្យជំនឿឬសាសនាកាន់តែសុក្រឹត។

**ស្ត្រីនិយម**
អ. feminism
បារ. féminisme (m.)

លទ្ធិមួយរបស់ទស្សនវិជ្ជាដែលបដិសេធការត្រួតត្រាឬការគ្រប់គ្រងដាច់មុខដោយបុរសនៅក្នុងសង្គម។ លទ្ធិនេះប្រឆាំងនឹងទស្សនៈនៃរបបបិតាធិបតេយ្យ និងប្រឆាំងនឹងកិច្ចមិនការពារតម្លៃស្ត្រីនិងការរើសអើងស្ត្រី។ លទ្ធិនេះទទួលស្គាល់និងលើកតម្កើងតម្លៃរបស់ស្ត្រីនៅក្នុងសង្គមឱ្យស្មើនឹងបុរស។

ឧ. ការបញ្ជ្រាបយេនឌ័រ (Gender) គឺជាទស្សនៈរបស់ស្ត្រីនិយម។

**ស្ថានភាព**
អ. situation
បារ. situation (f.)

បរិស្ថាន បរិបទ ឬកាលៈទេសៈណាមួយដែលជះឥទ្ធិពលដល់ការគិត ការសម្រេចចិត្ត ឬការប្រព្រឹត្តរបស់មនុស្ស។

# ហ

**ហឋយោគ**
អ. hatha-yoga
បារ. hatha-yoga

ផ្នែកមួយនៃប្រព័ន្ធទស្សនវិជ្ជាយោគៈ ដែលជាការហ្វឹកហាត់និងលត់ដំរាងកាយនិងចិត្តឱ្យមានតុល្យភាពដោយប្រើវិធីផ្សេងៗ ដូចជា ការធ្វើសមាធិ ការហាត់ប្រាណជាដើម ហើយដែលមានកម្រិតស្រាលជាងប្រព័ន្ធវិធីយោគៈផ្សេងៗទៀត។

**ហេតុជំរុញ**
អ. motive
បារ. motif (m.)

គោលបំណង ឆន្ទៈ សារៈសំខាន់ ឬផលប្រយោជន៍ដែលជាធាតុមូលដ្ឋាននៃអំពើរបស់មនុស្សជំរុញឱ្យចិត្តរបស់មនុស្សធ្វើឬទប់ស្កាត់មិនឱ្យធ្វើអំពើណាមួយ។ អ្នកដែលដឹងពីហេតុផលជំរុញនេះច្បាស់គឺមានតែអ្នកធ្វើអំពើនេះតែប៉ុណ្ណោះ។

ឧ. ហេតុផលជំរុញដែលនាំឱ្យព្រះសិទ្ធត្ថ(ព្រះពុទ្ធ) សុខចិត្តលះបង់រាជសម្បត្តិ/រាជ្យសម្បត្តិគឺដើម្បីស្វែងរកសច្ចធម៌នៃជីវិត។

**ហេតុផលភាពបញ្ច្រាស/ហេតុវាទបញ្ច្រាស**
អ. backward causation
បារ. causalité descendante

សញ្ញាណទូទៅនៃព្រឹត្តិការណ៍មួយដែលបង្កឱ្យព្រឹត្តិការណ៍មួយផ្សេងទៀតកើតឡើង ជាធម្មតាជំរុញឱ្យយើងគិតពីបុព្វហេតុដែលកើតឡើងមុន និងផលដែលកើតឡើងបន្ទាប់។ ប៉ុន្តែ ក៏អាចមានករណីខ្លះ ផលកើតមុនហេតុផងដែរ។

ឧ. ព្រហ្មលិខិតដែលកំណត់ដោយអាទិទេព គឺ

ជាផល រីឯព្រឹត្តិការណ៍ឬដំណើរជីវិតរបស់មនុស្សម្នាក់ៗដែលស្របទៅនឹងព្រហ្មលិខិតនោះ គឺជាហេតុ។

**អញ្ញទិដ្ឋិ**
អ. heresy
បារ. hérésie (f.)

ទស្សនៈ ជំនឿ ឬ ដំណើរយល់ឃើញផ្ទាល់ខ្លួន ដែលផ្ទុយឬប្រឆាំងទៅនឹងគោលការណ៍ឬទស្សនៈ របស់សាសនាផ្លូវការឬពេញនិយមណាមួយ។ នៅ សម័យបុរាណ និកាយណាក៏ដោយ ដូចជា និកាយ ប៉េរីប៉ាតេទិកនិយម (Peripatetics) អាកាដេមិក និយម (Academics) ពួកអេពីគួនិយម (Epicu- reans) ឬ ពួកអត់ធ្មត់និយម (Stoics) ត្រូវបាន ចាត់ទុកថាជា **អញ្ញទិដ្ឋិ**។

អញ្ញទិដ្ឋិកជន សំដៅលើមនុស្សណាម្នាក់ឬក្រុម ណាមួយដែលបង្រៀនតាមទស្សនៈផ្ទាល់ខ្លួន។

ដំបូងឡើយ **អញ្ញទិដ្ឋិ** មិនមែនជាបច្ចេកសព្ទក្នុង ន័យអវិជ្ជមាននោះទេ សូម្បីតែគ្រិស្តសាសនាក៏គិត ខ្លួនឯងថាជាអញ្ញទិដ្ឋិដែរ។ ប៉ុន្តែ ចាប់ពីពេលដែល គ្រិស្តសាសនាបានទទួលអំណាចលើសលប់ជាង គេក្នុងមជ្ឈិមសម័យ សាសនានេះបានប្រើពាក្យ **អញ្ញទិដ្ឋិ**សំដៅលើទស្សនៈណាមួយដែលមិនស្រប តាមការបង្រៀនរបស់គ្រិស្តសាសនានិកាយអ័រតូ- ដុកឬនិកាយណាមួយដែលធ្វើការបកស្រាយគម្ពីរ ប៊ីប(Bible) ខុសពីការបកស្រាយផ្លូវការនៃសហ- គមន៍គ្រិស្តសាសនា។ លក្ខណៈប្រហាក់ប្រហែល

នឹងអញ្ញទិដ្ឋិ គឺការបដិសេធ ការប្រានចោលគំនិត ឬទ្រឹស្ដីណាមួយដែលខុសពីគំនិតរបស់ខ្លួន។

អញ្ញទិដ្ឋិបានកើតឡើងនៅក្នុងវិស័យអាណាចក្រ ជាពិសេសនៅទីណាដែលការប្រើអាជ្ញាសំខាន់ជាង ការប្រើវិចារណញ្ញាណនៅក្នុងការដោះស្រាយទំនាស់ខាងទ្រឹស្ដី។

(បញ្ញត្តិនេះ គេប្រើនៅក្នុងទស្សនវិជ្ជាអំពីសាសនា)

**អដ្ឋង្គិកមគ្គ**

អ. eightfold path

បារ. octuple sentier

ផ្លូវដែលប្រកបដោយអង្គប្រាំបីដែលជាមជ្ឈិមប្បដិបទា(ផ្លូវកណ្ដាល) សំដៅដល់ សីល សមាធិ បញ្ញា ជាផ្លូវប្រតិបត្តិដើម្បីរំដោះខ្លួនឱ្យចេញផុតពីសេចក្ដីទុក្ខ។ អង្គរបស់អដ្ឋង្គិកមគ្គទាំង៨ មាន៖

១- **សម្មាទិដ្ឋិ** មានន័យថាគំនិតយល់ឃើញត្រូវ គឺគំនិតយល់ឃើញថា ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាបជាដើម។ សមាទិដ្ឋិនេះទៀតសោត គឺសំដៅយកបញ្ញាយល់ឃើញប្រពៃគឺឃើញនូវអរិយសច្ចទាំងបួនមាន ទុក្ខសច្ច សមុទយសច្ច និរោធសច្ច និង មគ្គសច្ច។

២- **សម្មាសង្កប្បោ** មានន័យថាត្រិះរិះត្រូវគឺត្រិះរិះចេញចាកកាម ត្រិះរិះដល់ការមិនព្យាបាទ ហៅថា អព្យាបាទ និង ការត្រិះរិះមិនជាហេតុបៀតបៀន

អ្នកដទៃ(អវិហិង្សា)។

៣- **សម្មាវាចា** មានន័យថាសម្ដីនិយាយត្រូវ បានដល់វាចាវៀរចាករបីទុច្ចរិត៤។

៤- **សម្មាកម្មន្តោ** មានន័យថាការងារត្រូវ បានដល់ការងារដែលវៀរចាកនូវទុច្ចរិតទាំង៣ ឬការងារទាំងឡាយណាដែលមិនមានទោស ហើយផ្ដល់ប្រយោជន៍ដល់ខ្លួននិងសង្គម។

៥- **សម្មាអាជីវោ** មានន័យថាការចិញ្ចឹមជីវិតត្រូវ, បើគ្រហស្ថ បានដល់ការលះបង់នូវជំនួញខុសទាំង ៥ (មិច្ឆាជីវ), បើបព្វជិត បានដល់ការលះបង់នូវបាបធម៌៥ និង អនេសនៈ២១ ជាដើម។

៦- **សម្មាវាយាមោ** មានន័យថាការព្យាយាមត្រូវ បានដល់ការព្យាយាមក្នុងស្ថានទាំង៤ មានកម្ចាត់បង់នូវអំពើអាក្រក់ និង ព្យាយាមធ្វើអំពើល្អ។

៧- **សម្មាសតិ** មានន័យថារឭកប្រពៃ គឺរឭកក្នុងសតិប្បដ្ឋាន៤។

៨- **សម្មាសមាធិ** មានន័យថាតាំងចិត្តខ្ជាប់ប្រពៃ គឺចម្រើនក្នុងឈាន៤។

**អដ្ឋង្គិកមគ្គ** មិនមែនជាការអភិវឌ្ឍត្រង់ភ្លឹងដូចបន្ទាត់នោះទេប៉ុន្តែជាការបំបែកធាតុខុសៗគ្នា ដែលគេត្រូវការដើម្បីឱ្យជីវិតរស់រួចផុតពីសេចក្ដីទុក្ខបាន។

**អដ្ឋង្គិកមគ្គ** ឬហៅម្យ៉ាងទៀតថា **មជ្ឈិមប្បដិបទា** (ផ្លូវកណ្ដាល) ក៏បាន។
 ២. ព្រះសង្ឃទូន្មានឱ្យពុទ្ធបរិស័ទយកអដ្ឋង្គិកមគ្គធ្វើជាមាគ៌ាជីវិត។

**អត្តនោមតិភាព / ប្រធានវិស័យភាព**
អ. subjectivity
បារ. subjectivité (f.)

អត្ថិភាពនៃអ្វីមួយដោយផ្អែកលើទស្សនៈឬអារម្មណ៍របស់បុគ្គលជាជាងផ្អែកលើហេតុការណ៍ខាងក្រៅឬកស្តុតាង។ ឧទាហរណ៍ ការយល់ថាព្រះអាទិត្យរះនៅទិសខាងកើតនិងលិចនៅទិសខាងលិច គឺជាអត្តនោមតិភាពរបស់មនុស្ស។

**អត្តស្នេហានិយម**
អ. narcissism / narcisism
បារ. narcissisme (m.)

ការជក់ចិត្តនឹងខ្លួនឯងហួសប្រមាណ ការស្រឡាញ់ខ្លួនឯងហួសហេតុ មោទនភាពជ្រុលចំពោះខ្លួនឯង។
 ពាក្យនេះមានប្រភពមកពីទេវកថាក្រិករឿង ណាគីស្សូស(narkissos) ឬ ណាស៊ីស៊ូស(narcissus) ។

**អត្តទត្តនិយម**
អ. egoism
បារ. égoisme (m.)

គំនិតដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន។
 តាមចិត្តវិទ្យា អត្តទត្តនិយមជាទស្សនៈមួយដែលយល់ថា ជានិច្ចកាលមនុស្សត្រូវបានជំរុញឱ្យធ្វើអ្វីមួយដោយសារតែប្រយោជន៍ផ្ទាល់ខ្លួន។
 តាមសីលវិជ្ជា អត្តទត្តនិយមជាទស្សនៈមួយដែល

យល់ថា ក្នុងភាពសមហេតុផល ជានិច្ចកាលមនុស្ស ត្រូវបានជំរុញឱ្យធ្វើអ្វីមួយដោយសារតែប្រយោជន៍ផ្ទាល់ខ្លួន។

**អត្តនោម័ត**
អ. subjective
បារ. subjectif

ដែលមានអត្ថិភាពតែនៅក្នុងចិត្តគំនិតរបស់មនុស្សជាបុគ្គលឬជាក្រុម និងមិនឯករាជ្យពីសតិរបស់មនុស្សជាបុគ្គលឬជាក្រុមទេ។

**អត្ថិភាពនិយម**
អ. existentialism
បារ. existentialisme (m.)

- ចលនាឬទំនោរទស្សនវិជ្ជាដែលផ្តោតការយកចិត្ត-ទុកដាក់ទៅលើអត្ថិភាពបុគ្គល សេរីភាពបុគ្គល និងជម្រើសបុគ្គល។
- ទស្សនវិជ្ជាស្តីអំពីមនុស្សក្នុងឋានៈជាបុគ្គលមានជីវិតនិងចេះគិត បុគ្គលមានសេរីភាពជ្រើសរើសសីលធម៌ បុគ្គលចង់ចាកផុតពីសេចក្តីទុក្ខនិងការប្រឈមមុខនឹងក្តីអស់សង្ឃឹម និង បុគ្គលរស់នៅក្នុងការព្រួយបារម្ភនិងសេចក្តីស្លាប់។
- ទស្សនវិជ្ជាស្តីពីអ្វីដែលមានអត្ថិភាពពិត និងជាចលនាមួយប្រឆាំងនឹងប្រព័ន្ធគំនិតបុរាណដែលជឿលើគំនិតអរូបី។

 ៤. ទស្សនៈរួមរបស់ពួកអត្ថិភាពនិយមមានដូចជា៖

- បុគ្គលម្នាក់គ្មានសារជាតិជាពិសេសទេ គ្មានអត្ត-

សញ្ញាណផ្ទាល់ដោយខ្លួនឯងទេ គេបង្កើតដោយខ្លួនឯងតាមរយៈជម្រើសរបស់ខ្លួន។

• ចក្រវាលមិនផ្តល់នូវច្បាប់សីលធម៌ទេ។ គោលការណ៍សីលធម៌កសាងឡើងដោយមនុស្សក្នុងបរិបទទទួលខុសត្រូវចំពោះអំពើរបស់ខ្លួននិងរបស់អ្នកដទៃ។

**អទេវនិយម**
អ. atheism
បារ. athéisme (m.)

លទ្ធិឬជំនឿដែលបដិសេធអត្ថិភាពរបស់អាទិទេព។ ពួកអទេវនិយម ដូចជា នីតឆេ (Nietzsche) និង កាល់ ម៉ាក្ស (Karl Marx) ជឿថា អាទិទេពដែលពួកទេវនិយមចាត់ទុកថាជាតួអង្គជាក់ស្តែងមួយនោះគឺមិនមានអត្ថិភាពទេ ប៉ុន្តែ វាគ្រាន់តែជាការបង្កើតឡើងពីគំនិតរបស់មនុស្សដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនានារបស់ខ្លួនប៉ុណ្ណោះ។

**អនន្តភាព**
អ. eternity
បារ. éternité (f.)

លក្ខណៈមួយក្នុងចំណោមលក្ខណៈផ្សេងៗរបស់អាទិទេព ដែលត្រូវបានគេបកស្រាយបានតាមរបៀបពីរយ៉ាងខុសគ្នា។ **របៀបទី១** : អាទិទេពគឺជាអនន្ត ដោយសារតែអាទិទេពមិនចងដោយពេលវេលា។ អត្ថិភាពរបស់អាទិទេពនៅក្រៅពេលវេលាឬមិនចំណុះពេលវេលា, អាទិទេពគ្មានពេលកំណត់ ប៉ុន្តែ អាទិទេពជាអ្នកបង្កើតពេល។

ដោយសារតែអាទិទេពមិននៅក្នុងពេលវេលា រាល់ព្រឹត្តិការណ៍ដែលកើតឡើងក្នុងពេល ចំពោះទ្រង់គឺកើតឡើងដំណាលគ្នា។ ខណៈ «ឥឡូវ» របស់យើងសម្គាល់ពេលវេលានិងវត្ថុអត្ថិភាពក្នុងពេលប្រែប្រួល រីឯ «ឥឡូវ» របស់អាទិទេពឋិតថេរ មិនប្រែប្រួលនិងមិនអាចធ្វើឱ្យប្រែប្រួល។ **របៀបទី២** : អាទិទេពមានលោកិយភាព ពោលគឺ មានអតីតកាល បច្ចុប្បន្នកាល និង អនាគតកាល ប៉ុន្តែ ព្រះអង្គជាអនន្តភាព ពីព្រោះអាទិទេពតែងតែមានអត្ថិភាពនៅក្នុងអតីតកាល មានអត្ថិភាពនៅក្នុងបច្ចុប្បន្នកាល និងតែងតែមានអត្ថិភាពនៅក្នុងអនាគតកាល។ អនន្តភាពស្មើនឹងចំនួនសរុបនៃកាលទាំងបី (អតីត-កាល បច្ចុប្បន្នកាល និង អនាគតកាល)។

(ពាក្យនេះ គេប្រើក្នុងអស្តិរូបវិជ្ជា និង ទស្សនវិជ្ជាអំពីសាសនា)។

**អនិស្សរវាទ**
អ. agnosticism
បារ. agnosticisme (m.)

លទ្ធិដែលចាត់ទុកបរមត្ថ (l' absolu) ថាជាអ្វីដែលពុទ្ធិរបស់យើងមិនអាចយល់បានឬលទ្ធិដែលប្រានចោលការជញ្ជឹងគិតតាមបែបបរមត្ថវិជ្ជាថាឥតប្រយោជន៍។

**អនុមាន**

អ. inference

បារ. inférence (f.)

វិធីនៃការទាញសេចក្ដីសន្និដ្ឋានដែលមានតម្លៃខាងតក្កវិជ្ជាពិតឬមិនពិតចេញពីសេចក្ដីថ្លែង/អំណះអំណាងមួយឬច្រើន។ ជាទូទៅ អនុមានចែកចេញជាអនុមានរួម(Induction) និង អនុមានញែក (Deduction)។ ក្នុងករណីខ្លះ គេរាប់បញ្ចូលវិសេសានុមាន (Abduction) ជាប្រភេទទីបីនៃអនុមានដែរ ប៉ុន្តែជាញឹកញាប់ គេចាត់ទុកវាថាជាករណីវិសេសនៃអនុមានរួម។

(ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា)

**អនុមានញែក**

អ. deduction

បារ. déduction (f.)

វិធីនៃការពិចារណាដែលទាញសេចក្ដីសន្និដ្ឋានពីសច្ចភាពសាកលទៅរកសច្ចភាពដោយឡែកៗ ដោយផ្អែកលើតក្កសាស្ត្រ។ សេចក្ដីសន្និដ្ឋានរបស់អនុមានញែកមានសភាពពិតដាច់ខាត។

ឧទាហរណ៍៖

- មនុស្សទាំងអស់ ជាយថាហេតុ នឹងស្លាប់។
- សុខ ជាមនុស្ស។ ដូច្នេះ សុខ ជាយថាហេតុ នឹងស្លាប់ដែរ។

(ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា)

**អនុមានរួម**

អ. induction

បារ. induction

(f.)

វិធីនៃការពិចារណាដែលទាញសេចក្ដីសន្និដ្ឋានចេញពីសច្ចភាពឬករណីដោយឡែកៗទៅរកសច្ចភាពសាកលឬការធ្វើទូទៅនីយកម្មលើមូលដ្ឋាននៃសច្ចភាពឬក៏ករណីដោយឡែកៗមួយចំនួនផ្អែកលើតក្កសាស្ត្រ។ សេចក្ដីសន្និដ្ឋានរបស់អនុមានរួមជាទូទៅ មានសភាពប្រហែលជាជាងសភាពពិតដាច់ខាត។

ឧទាហរណ៍១៖

- ដែកចម្លងអគ្គិសនី ទង់ដែងចម្លងអគ្គិសនី ប្រាក់ចម្លងអគ្គិសនី។

- ដែក ទង់ដែង ប្រាក់ ជាលោហៈ។ ដូច្នេះ លោហៈទាំងអស់ចម្លងអគ្គិសនី។

ឧទាហរណ៍២៖

- ជនជាតិព្នងមានជំនឿលើព្រលឹងដូនតា ជនជាតិកួយមានជំនឿលើព្រលឹងដូនតា ជនជាតិគ្រឹងមានជំនឿលើព្រលឹងដូនតា។

- ជនជាតិកួយ ជនជាតិព្នង ជនជាតិគ្រឹង... ជាជនជាតិដើម។ ដូច្នេះ ជនជាតិដើមទាំងអស់មានជំនឿលើព្រលឹងដូនតា។

(ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា)

**អន្តរកម្មនិយម**

អ. interactionism

បារ. interactionnisme (m.)

ទស្សនៈរបស់ពួកទ្វិកនិយមដែលអះអាងថា ថ្វីបើចិត្តនិងកាយជាសារធាតុពីរដាច់ដោយឡែកពីគ្នាក៏ដោយ ក៏វាជះឥទ្ធិពលលើគ្នាទៅវិញទៅមកតាមទំនាក់ទំនងហេតុផល។ ចិត្តនិងកាយជាធាតុពីរឯករាជ្យពីគ្នា ប៉ុន្តែ នៅក្នុងជីវិតទាំងមូល កាយនិងចិត្តមានអន្តរកម្មជាមួយគ្នា។

(ពាក្យនេះ គេប្រើនៅក្នុងបរិបទអស្តិរូបវិជ្ជា និងទស្សនវិជ្ជាអំពីចិត្ត)

**អន្តរាយ**

អ. harm

បារ. mal (m.)

បញ្ញត្តិស្មុគស្មាញដែលករណីសំខាន់របស់វា រួម-មាន របួសស្នាមធ្ងន់ខាងរាងកាយ ផ្លូវចិត្ត ឬការខូចខាតផលប្រយោជន៍សំខាន់និងស្របច្បាប់របស់នរណាម្នាក់។ **អន្តរាយ** មានន័យបង្កប់មួយចំនួននៅក្នុងទង្វើរបស់មនុស្ស ដូច្នេះក្នុងករណីដែលមនុស្សម្នាក់ធ្វើឱ្យឈឺចាប់ខ្លួនឯងរយៈពេលខ្លី ឧទាហរណ៍ៈ ការជំពប់ជើង មិនមែនជាអន្តរាយឡើយ។

- គោលការណ៍ ហេតុផលមួយក្នុងចំណោមហេតុផលចម្បងៗដែលអាចទទួលយកបានចំពោះការទប់ស្កាត់ខាងផ្លូវច្បាប់និងតាមសីលធម៌ គឺជាការបង្ការមិនឱ្យមានអន្តរាយដល់អ្នកដទៃនោះ វានៅតែ

សំខាន់ចំពោះការកំណត់ព្រំដែននៃបញ្ញត្តិនេះ។ ករណីមួយចំនួននៅមានការខ្វែងគំនិតគ្នាចំពោះការចាត់ទុកថា តើវាស្ថិតនៅក្នុងប្រភេទនៃអន្តរាយដែរឬទេ រួមមាន ការបង្កឱ្យមានអផាសុកភាព ការជេរការឆាឆៅ និង ការប្រមាថ។

២. ការបើកបរលឿនអាចបង្កអន្តរាយដល់អ្នកដទៃ។

**អព្ភន្តរញ្ញាណ**
អ. intuition
បារ. intuition (f.)

លទ្ធភាពនៃការយល់ដឹងឬដឹងអ្វីមួយភ្លាមៗដោយមិនចាំបាច់ឆ្លងកាត់ការគិត ការពិចារណា ឬ ការពិសោធ។

២. ការយល់ដឹងពីសោភណភាពនៃអ្វីមួយរបស់នរណាម្នាក់ដោយអព្ភន្តរញ្ញាណ ឬឃើញភ្លាមស្រឡាញ់ភ្លែត គឺជាការស្រឡាញ់បែបអព្ភន្តរញ្ញាណ។

**អព្ភន្តរញ្ញាណនិយម**
អ. intuitionism
បារ. intuitionnisme (m.)

- តាមន័យទស្សនវិជ្ជា : លទ្ធិមួយដែលអះអាងថាពុទ្ធិពិតគឺពុទ្ធិដែលកើតពីអព្ភន្តរញ្ញាណ។

២. ពួកអព្ភន្តរញ្ញាណនិយមជាក្រុមដែលយល់ថាពុទ្ធិដែលកើតពីអារម្មណ៍គឺជាការណ៍ពិត។

- តាមន័យសីលវិជ្ជា : លទ្ធិមួយដែលអះអាងថាពុទ្ធិស្ដីពីកុសលឬកាតព្វកិច្ច និង គោលការណ៍នានា

ដែលគ្រប់គ្រងពួកវា គេអាចយល់ដឹងតាមរយៈអព្ភន្តរញ្ញាណ។

២. អ្នកអព្ភន្តរញ្ញាណនិយមជាក្រុមដែលយល់ថា អំពើកុសលឬកាតព្វកិច្ចមនុស្សម្នាក់ៗយល់ដឹងបានតាមរយៈអព្ភន្តរញ្ញាណរៀងៗខ្លួន។

**អភិប្រាយវិជ្ជា**

អ. hermeneutics

បារ. herméneutiques (f.)

ការសិក្សាអំពីទ្រឹស្តីនិងវិធីសាស្ត្រដែលនិយាយពីការបកស្រាយនិងការយល់ដឹងអំពីអត្ថបទ។

អភិប្រាយវិជ្ជាចែកចេញជាពីរ គឺ **ទីមួយ** ជាវិទ្យាសាស្ត្រនិងវិធីសាស្ត្រស្តីពីការបកស្រាយបែបវិទ្យាសាស្ត្រនូវអត្ថបទនានាតាមរយៈសំណេរ ជាពិសេសគម្ពីរសាសនា គតិបណ្ឌិតនៅក្នុងអក្សរសាស្ត្រ អត្ថបទទស្សនវិជ្ជា ជាដើម។ **ទីពីរ** ជាទេវវិជ្ជាស្តីពីបញ្ញត្តិសាសនាដែលជាមែកធាងនៃទេវវិជ្ជា ហើយដែលទាក់ទងនឹងការពន្យល់ឬការបកស្រាយតាមរយៈពាក្យសម្តីនូវបញ្ញត្តិ ទ្រឹស្តី និង គោលការណ៍ខាងសាសនានិងទស្សនវិជ្ជា។

**អវិជ្ជា**

អ. avijjā / ignorance

បារ. avijjā / ignorance (f.)

ក្នុងន័យទូទៅ **អវិជ្ជា**មានន័យថាការមិនដឹងច្បាស់ សេចក្តីល្ងង់ មោហៈ។ នៅក្នុងព្រះពុទ្ធសាសនា **អវិជ្ជា** (avijja) មានន័យថាការមិនដឹងឬមិនយល់

ពីធម្មជាតិពិតនៃជីវិតរបស់យើងនិង/ឬធម្មជាតិពិតរបស់វត្ថុ។ អវិជ្ជានៅក្នុងទ្រឹស្តីបដិច្ចសមុប្បាទ (Dependent Origination)គឺអវិជ្ជាអំពីអរិយសច្ចទាំង៤ មានន័យថា ១- មិនយល់ពីសេចក្តីទុក្ខ (ទុក្ខអរិយសច្ច), ២- មិនយល់ពីប្រភពនៃទុក្ខ (ទុក្ខសមុទយអរិយសច្ច), ៣- មិនយល់ពីសេចក្តីរំលត់ទុក្ខ (ទុក្ខនិរោធអរិយសច្ច) និង ៤- មិនយល់ពីមាគ៌ាដែលដឹកនាំទៅរកការរំលត់ទុក្ខ (មគ្គអរិយ-សច្ច)។

អវិជ្ជានេះនាំឱ្យមនុស្សធ្វើអំពើអកុសលឬអំពើបាបជាច្រើនរាប់មិនអស់។ ហេតុនេះ ការយល់ដឹងពីអរិយសច្ចទាំង៤ពិតជាមានសារៈសំខាន់ក្រៃលែង។ ដោយសារតែមនុស្សម្នាក់ៗខកខានមិនបានយល់ពីអរិយសច្ចទាំង៤នេះហើយ ទើបបានជាពួកគេត្រូវវិលវល់នៅក្នុងគំនិតជាប់ជំពាក់មិនចេះចប់ និងវិលវល់ក្នុងវដ្តសង្សារ។

**អសារនិយម**
អ. nihilism
បារ. nihilisme
(m.)

១- ទស្សនៈដែលយល់ថាជំនឿនិងតម្លៃជាប្រពៃណីគ្មានហេតុផល និងថាជាអត្ថិភាពគ្មានន័យនិងគ្មានប្រយោជន៍។

២- ទស្សនៈដែលបដិសេធនូវមូលដ្ឋានសត្យានុម័តិ

នានានៃសច្ចភាព ជាពិសេស សច្ចភាពខាងសីល-ធម៌។

៣- ទស្សនៈដែលជឿថាគ្រប់អង្គការសាសនានិងនយោបាយ អាក្រក់ណាស់ ឬជាប្រព័ន្ធគំនិតមួយដែលថា គ្មានគោលការណ៍ ឬជំនឿណាដែលមានន័យ ឬអាចជាការណ៍ពិតបានទេ។

ឧទាហរណ៍៖ ពួកអសារនិយមខាងសីលធម៌យល់ថា សីលធម៌គ្មានអត្ថិភាពពីធម្មជាតិទេ។

**អសុទ្ធចិត្ត**
អ. bad faith
បារ. mauvaise foi

លក្ខខណ្ឌមួយដែលមនុស្សម្នាក់បង្វែរការយល់ឃើញរបស់នរណាម្នាក់ទៀតចេញពីការណ៍ពិតឬអំណាចជ្រើសរើសនិងជម្រើសនានាក្នុងកម្រិតណាមួយដែលគេដឹងថាវាមាន។ លក្ខខណ្ឌនេះ កត់សម្គាល់ដោយ ហ្សង់ ប៉ូល សាត្រ (Jean-Paul Sartre)។

**អត្ថិទស្សនវិជ្ជា**
អ. metaphilosophy
បារ. métaphilosophie (f.)

ទស្សនវិជ្ជាដែលសិក្សាអំពីទស្សនវិជ្ជាខ្លួនឯង ពោលគឺសិក្សាពីធម្មជាតិ វិធី គោលបំណង ស្វ័យភាព សត្យានុម័តភាព និងសំណួររបស់ទស្សនវិជ្ជា ព្រមទាំងទំនាក់ទំនងរវាងទស្សនវិជ្ជានិងមុខវិជ្ជាដទៃទៀត។

អត្ថិទស្សនវិជ្ជាជាបច្ចេកសព្ទមួយបង្ហាញដោយ

ទស្សនវិទូ ឡាសេរ៉ូវីត (Lazerowitz, ១៩០៧-១៩៨៧) ជនជាតិប៉ូឡូញ សញ្ជាតិអាមេរិក។

**អាជ្ញា**
អ. authority
បារ. autorité (f.)

សិទ្ធិអំណាចដែលកាន់កាប់ដោយមនុស្សម្នាក់ ស្ថាប័នមួយ ឬ រដ្ឋមួយ ដើម្បីចេញបញ្ជាឱ្យគោរព។ សិទ្ធិនេះបញ្ជាក់ពីកាតព្វកិច្ចមួយដែលអ្នកនៅក្រោមបង្គាប់នៃអាជ្ញានេះត្រូវតែគោរពនិងអនុវត្តតាម។

អាជ្ញាគឺជាប្រភេទមួយនៃអំណាច ប៉ុន្តែ អំណាចទាំងអស់មិនមែនសុទ្ធតែជាអាជ្ញាទេ។ ប្រភេទអំណាចមួយចំនួនគ្រាន់តែជាកម្លាំងបង្ខិតបង្ខំ ហើយវាមិនមានធម្មានុរូបភាពទេ។ អាជ្ញាអាចគ្រប់គ្រងតែតំបន់ និងមនុស្សមួយចំនួនដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ប៉ុន្តែមិនមែនគ្រប់គ្រងតំបន់ និងមនុស្សផ្សេងទៀតដែលស្ថិតនៅក្រៅដែនសមត្ថកិច្ចរបស់ខ្លួនទេ។ វិសាលភាពនិងព្រំដែននៃអាជ្ញារបស់រដ្ឋទាមទារឱ្យមានការពន្យល់។

(ពាក្យនេះ គេប្រើក្នុងបរិបទទស្សនវិជ្ជានយោបាយ និង ទស្សនវិជ្ជាអំពីច្បាប់)

**អាជ្ញានិយម**
អ. authoritarianism

ទស្សនៈនយោបាយមួយដែលយល់ថា ប្រជាពលរដ្ឋត្រូវតែគោរពអាជ្ញាធរជាដាច់ខាត ដោយមិនអនុញ្ញាត

បារ. autoritarisme
(m.)

ឱ្យសួរដេញដោលឡើយ។ ក្នុងការប្រតិបត្តិនៅក្នុងប្រព័ន្ធនយោបាយផ្ដាច់ការមួយ រដ្ឋាភិបាលមានអំណាចឥតព្រំដែននិងខ្វះការបង្គាប់បញ្ជាត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ។ អាជ្ញាធរអាចសម្រេចចិត្តដោយមិនចាំបាច់ពិគ្រោះយោបល់ឬចរចាជាមួយអ្នកដែលទទួលផលប៉ះពាល់ពីការអនុវត្តសេចក្ដីសម្រេចចិត្តនោះឡើយ។ សង្គមបែបនេះត្រូវបានគ្រប់គ្រងដោយមនុស្សម្នាក់ឬមនុស្សមួយក្រុមជាជាងដោយច្បាប់។

(ពាក្យនេះ គេប្រើក្នុងបរិបទទស្សនវិជ្ជានយោបាយ)

**អាតូមនិយម**
អ. atomism
បារ. atomisme
(m.)

១- ទ្រឹស្ដីបុរាណរបស់ ដេម៉ូគ្រីត (Democrite / Democritus) អេពីគួ (Epicure/Epicurus) និង លុយក្រែស (Lucrèce/Lucretius) ដែលថា ចុណ្ណភាគសុទ្ធល្អិតបំផុតមិនអាចបំបែកតទៅទៀតបាន និងមិនអាចបំផ្លាញបាន គឺជាសមាសភាពមូលដ្ឋាននៃចក្រវាលទាំងមូល។

២- ទ្រឹស្ដីដែលថា ស្ថាប័ន តម្លៃ និង លំនាំសង្គម កើតឡើងពីអំពើនិងប្រយោជន៍របស់បុគ្គលម្នាក់ៗ។

**អាទិទេពវិចារណ-ញ្ញាណនិយម/អាទិទេពនិយម**
អ. deism
បារ. déisme (m.)

ជំនឿលើអត្ថិភាពរបស់អាទិទេពដោយផ្អែកលើវិចារណញ្ញាណនិងធម្មជាតិតែប៉ុណ្ណោះ ហើយអះអាងថា អាទិទេពបង្កើតចក្រវាល និងទុកឱ្យវាប្រព្រឹត្តទៅដោយខ្លួនឯងដោយមិនមានឥទ្ធិពលមកលើជីវិត បាតុភូតធម្មជាតិ និង ការបង្ហាញបែបអធិធម្មជាតិទេ។

ឧ. អាទិទេពវិចារណញ្ញាណនិយមមានឥទ្ធិពលជាពិសេសនៅក្នុងសតវត្សរ៍ទី១៧និងទី១៨នៃគ្រិស្តសករាជ។

**អេកាស្យា**
អ. eikasia

ដំណាក់ទាបបំផុតនៃការដឹង។

ឧ. ការយល់ដឹងដោយឥន្ទ្រីយ៍ទៅលើកម្មវត្ថុមួយដែលស្ថិតក្នុងបរិស្ថានស្មុគស្មាញ ជាការយល់ដឹងបែបអេកាស្យា។

**អាំងគីស៊ីស្យុង**
អ. inquisition
បារ. inquisition (f.)

តុលាការពិសេសដែលសម្ដេចប៉ាបទី៩ ឈ្មោះហ្គ្រេហ្គ័រ (Le Pape Grégoire IX) បង្កើតឡើងនៅមជ្ឈិមសម័យដើម្បីដាក់ទោសជនទាំងឡាយណាដែលមានមតិប្រឆាំងនឹងគ្រិស្តសាសនាដោយចោទប្រកាន់ថា អញ្ញទិដ្ឋិកជន (hérétiques)។

ឧ. ហ្សកដាណូ ព្រុយណូ (Giordano Bruno) វីរបុរសនៃការត្រិះរិះពិចារណាត្រូវទទួលទណ្ឌកម្ម

យ៉ាងខ្លោចផ្សាអស់រយៈពេល៧ឆ្នាំ ហើយនៅទីបំ-
ផុត ត្រូវគេយកទៅដុតទាំងរស់នៅខែកុម្ភៈ ឆ្នាំ
១៦០០ ដោយការវិនិច្ឆ័យរបស់តុលាការអាំងគី-
ស៊ីស្យុង។

# ឥ

**ឥរិយាបថនិយម**
អ. behaviorism
បារ. behaviorisme (m.)

ទ្រឹស្តីដែលអះអាងថា ឥរិយាបថមនុស្សនិងសត្វអាចត្រូវបានបកស្រាយក្នុងលក្ខខណ្ឌមួយ ដោយមិនគិតអំពីគំនិតឬអារម្មណ៍ និងអះអាងថា ចិត្តវិបល្លាស (psychological disorders) គេអាចព្យាបាលបានតាមរយៈការផ្លាស់ប្តូរគំរូឥរិយាបថផ្សេងៗ។ ក្នុងន័យទូលាយ ឥរិយាបថនិយម គឺជាទស្សនៈដែលយល់ថា ឥរិយាបថគឺជាមូលដ្ឋានក្នុងការយល់ដឹងអំពីបាតុភូតចិត្ត។

(ពាក្យនេះ គេប្រើនៅក្នុងទស្សនវិជ្ជាអំពីចិត្ត)

**ឥរិយាបថស្ថាប័ន**
អ. organizational behavior
បារ. comportement organisationnel

វិស័យមួយនៃការសិក្សាដោយអង្កេតលើផលប៉ះពាល់ដែលកើតចេញពីឥរិយាបថរបស់បុគ្គលម្នាក់ៗ ក្រុមនីមួយៗ និង រចនាសម្ព័ន្ធនានានៅក្នុងស្ថាប័នមួយ។ វិស័យនៃការសិក្សានេះជាប់ពាក់ព័ន្ធជាមួយមុខវិជ្ជាជាច្រើនរួមមាន សង្គមវិទ្យា ចិត្តវិទ្យា ទំនាក់ទំនង ការគ្រប់គ្រង ទ្រឹស្តីស្ថាប័ន និង ធនធានមនុស្សវិទ្យា។ លើសពីនេះទៀត វាក៏អាចសំដៅទៅរកស្ថាប័នវិទ្យាឬវិទ្យាសាស្ត្រស្ថាប័នទៀតផង។ ឥរិយាបថស្ថាប័នមានឫសគល់នៅក្នុងចិត្តវិទ្យាឧស្សាហកម្ម និង ចិត្តវិទ្យាស្ថាប័ន។

# ៦

**ឯកទេវនិយម** លទ្ធិ ជំនឿ ឬ សាសនាដែលជឿថាមានអាទិទេពតែមួយគត់ដូចមានក្នុងសាសនាជ្វីប (Judaism) សាសនាគ្រិស្ត និង សាសនាអ៊ិស្លាម។

អ. monotheism

បារ. monothéisme (m.)

**ឯកអគ្គទេវនិយម** បច្ចេកសព្ទរបស់ ម៉ាក មូល័រ (Max Müller) សំដៅដល់លទ្ធិមួយដែលអនុញ្ញាតឱ្យមានអត្ថិភាពអាទិទេពច្រើន ប៉ុន្តែលទ្ធិនេះបានអះអាងថា មានអាទិទេពតែមួយអង្គគត់ដែលជាអ្នកដឹកនាំកំពូលរបស់ពួកអាទិទេពទាំងនោះ ហើយអាទិទេពអង្គនោះសក្តិសមនឹងទទួលបានភាពស្មោះត្រង់ ការគោរព និង ការស្តាប់បង្គាប់ពីអាទិទេពទាំងឡាយ។ ឯក-អគ្គទេវនិយមជាការសម្រុះសម្រួលរវាងពហុទេវ-និយមដែលជឿថាមានអាទិទេពច្រើននិងឯកទេវ-និយមដែលជឿថាអាទិទេពមានតែមួយអង្គគត់។ ទស្សនវិទូសាសនាខ្លះចាត់ទុកឯកអគ្គទេវនិយមជាដំណាក់កាលកណ្តាលក្នុងការអភិវឌ្ឍពីពហុទេវនិយមទៅជាឯកទេវនិយម។ តាម តាលីហ្វែរ៉ូ (Taliaferro) «ឯកអគ្គទេវនិយម គឺជាការទទួលស្គាល់អាទិទេពតែមួយសម្រាប់គោលបំណងឧទ្ទិសនិងបូជាដោយ

អ. henotheism

បារ.hénothéisme (m.)

មិនបដិសេធនូវអត្ថិភាពនៃអធិការៈដទៃទៀតទេ»។

( ពាក្យនេះ គេប្រើនៅក្នុងទស្សនវិជ្ជាអំពីសាសនា )